

# ផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៦៧ ដែលរដ្ឋជាសមាជិករួមមាន ព្រុយណេដារ៉ូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

លេខាធិការដ្ឋានអាស៊ាន មានមូលដ្ឋាននៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។

សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទងទៅ ៖
លេខាធិការដ្ឋានអាស៊ាន
ផ្នែកទំនាក់ទំនងសហគមន៍ (CRD)
70A Jalan Sisingamangaraja
Jakarta 12110, Indonesia
Phone: (62 21) 724-3372, 726-2991
Fax: (62 21) 739-8234, 724-3504
E-mail: public@asean.org

ទិន្នន័យកាតាឡុកក្នុងការបោះពុម្ពផ្សាយ
ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
ទីក្រុងហ្សាការតា លេខាធិការដ្ឋានអាស៊ាន ខែ ធ្នូ ឆ្នាំ ២០២២

323.3459
1. អាស៊ាន-ស្ត្រី-ក្របខណ្ឌថ្នាក់តំបន់
2. សមភាពយេនឌ័រ-សិទ្ធិស្ត្រី

ISBN 978-623-5429-14-4 (EPUB)

អាស៊ាន ៖ សហគមន៍ដែលនាំមកនូវឱកាសសម្រាប់ប្រជាជនទាំងអស់

អត្ថបទក្នុងឯកសារបោះពុម្ពផ្សាយនេះអាចត្រូវបានដកស្រង់ ឬព្រីនឡើងវិញដោយសេរី ឱ្យតែមានសេចក្តីថ្លែងអំណរគុណសមស្រប និងផ្ញើច្បាប់ចម្លងឯកសារដែលបានព្រីនឡើងវិញ ទៅផ្នែកទំនាក់ទំនងសហគមន៍ (CRD) នៃលេខាធិការដ្ឋានអាស៊ានដែលមានទីស្នាក់ការនៅទីក្រុងហ្សាការតា។

គាំទ្រដោយ ៖

USAID FROM THE AMERICAN PEOPLE · In partnership with Canada · Ministry of Gender Equality and Family · UN WOMEN

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN PRA on WPS) ត្រូវបានព្រាងឡើងដោយក្រុមប្រឹក្សាស្ត្រីអាស៊ាន សន្តិភាព និងសន្តិសុខ ដែលដឹកនាំដោយគណៈកម្មាធិការស្ត្រីអាស៊ាន (ACW) និងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ាន នៅក្នុង សសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន។ ផែនការសកម្មភាពនេះត្រូវបានសម្រេចដោយក្រុមប្រឹក្សាសង្គម-វប្បធម៌អាស៊ាន (ASCC) និងអនុម័តដោយថ្នាក់ដឹកនាំ អាស៊ានក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០ និង ៤១ កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២២។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានរៀបចំឡើងក្រោមគម្រោង PROSPECT ដែលទទួលបានមូលនិធិពី USAID និងអង្គការ UN Women ក្រោមការគាំទ្រពីរដ្ឋាភិបាលកាណាដា និងសាធារណរដ្ឋកូរ៉េ។ រូបភាពក្រាហ្វិកនៅលើគម្រប ត្រូវបានរចនាឡើងដោយនាយកដ្ឋានកសាង សន្តិភាព និងកិច្ចការនយោបាយនៃអង្គការសហប្រជាជាតិ។

ព័ត៌មានទូទៅស្តីពីអាស៊ាន អាចរកបានតាមគេហទំព័រអាស៊ាន ៖ www.asean.org

©២០២២ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)
រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា


សេចក្តីសង្ខេប ........ 4

អក្សរកាត់ ........ 6

១.ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ........ 8

១.១ សាវតារ ........ 9

១.២ ក្របខណ្ឌថ្នាក់សកល និងក្របខណ្ឌថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ........ 11

១.២.១ ក្របខណ្ឌថ្នាក់សកល ........ 11

១.២.២ ក្របខណ្ឌថ្នាក់តំបន់ ........ 14

១.៣ ស្ថានភាពនៃការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ៖ វឌ្ឍនភាព បញ្ហាប្រឈម ឱកាស និងអភិក្រមជាយុទ្ធសាស្ត្រ ........ 16

១.៣.១ វឌ្ឍនភាព ........ 16

១.៣.២ បញ្ហាប្រឈម ឱកាស និងអភិក្រមជាយុទ្ធសាស្ត្រ ........ 17

១.៤ សនិទានភាពសម្រាប់ផែនការសកម្មភាពតំបន់អាស៊ាន ........ 18

១.៥ ដំណើរការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ........ 19

១.៦ យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ........ 20

តារាងស្តីពីការការពារ ........ 21

តារាងស្តីពីការចូលរួម ........ 25

តារាងស្តីពីការទប់ស្កាត់ ........ 29

តារាងស្តីពីការសង្គ្រោះ និងស្តារឡើងវិញ ........ 34

តារាងស្តីពីការអនុវត្ត ការសម្របសម្រួល ការរាយការណ៍ និងការពិនិត្យតាមដាន និងវាយតម្លៃ ........ 37

២.ព័ត៌មានបន្ថែម ........ 40

២.១ ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ ការសម្របសម្រួល ការរាយការណ៍ និងការពិនិត្យតាមដាន និងវាយតម្លៃ ........ 41

២.១.១ គោលការណ៍ណែនាំសម្រាប់ការអនុវត្ត ........ 41

២.១.២ ស្ថាប័នអនុវត្ត តួនាទី និងការទទួលខុសត្រូវ ........ 42

២.២ ការពិនិត្យតាមដាន ការរាយការណ៍ និងការវាយតម្លៃ ........ 45

ឧបសម្ព័ន្ធ ១ ៖ សមាជិកនៃក្រុមប្រឹក្សាស្ត្រីអាស៊ាន សន្តិភាព និងសន្តិសុខ ........ 46

ឧបសម្ព័ន្ធ ២ ៖ សមាជិកនៃក្រុមការងារបច្ចេកទេសរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ........ 48

# សេចក្តីសង្ខេប

ជាយូរមកហើយដែលការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ត្រូវបានចាត់ទុកជាកត្តាសំខាន់ក្នុងការសម្រេចបានសន្តិភាព និងវិបុលភាពប្រកបដោយនិរន្តរភាពក្នុងតំបន់អាស៊ាន។ រដ្ឋជាសមាជិកអាស៊ានបន្តប្តេជ្ញាសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងការការពារសិទ្ធិស្ត្រីយ៉ាងពេញលេញ ក៏ដូចជាបន្តផ្តោតការយកចិត្តទុកដាក់លើការរក្សាសន្តិភាពក្នុងតំបន់ ដោះស្រាយការព្រួយបារម្ភផ្នែកសន្តិសុខជារួម និងលើកកម្ពស់ការអភិវឌ្ឍ និងវិបុលភាពសម្រាប់ប្រជាជនទាំងអស់។ រដ្ឋជាសមាជិក អាស៊ានចាត់ទុកការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (RPA WPS) ជាជំហានដ៏សំខាន់មួយឆ្ពោះទៅសម្រេចបាននូវការប្តេជ្ញាចិត្តទាំងនេះ។ ផែនការសកម្មភាពនេះមានគោលបំណងកៀរគរតំបន់អាស៊ានទាំងមូលឱ្យពន្លឿនការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីលើកកម្ពស់សន្តិភាព និងសន្តិសុខប្រកបដោយនិរន្តរភាពសម្រាប់ប្រជាជនទាំងអស់។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ផ្អែកលើការចូលរួមផ្នែកនយោបាយនៅក្នុងតំបន់អាស៊ាន ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក លើបញ្ហាដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជាសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងតំបន់អាស៊ាន (២០០៤) សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការលុបបំបាត់អំពើហិង្សាលើកុមារក្នុងតំបន់អាស៊ាន (២០១៣) និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (២០១៥)។ ដើម្បីបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួន ថ្នាក់ដឹកនាំអាស៊ានបានអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន នៅអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ កាលពីខែ វិច្ឆិកា ឆ្នាំ២០១៧។ កិច្ចសន្ទនាថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីការពង្រឹងតួនាទីរបស់ស្ត្រីដើម្បីសន្តិភាព និងសន្តិសុខប្រកបដោយនិរន្តរភាព ដែលត្រូវបានរៀបចំឡើងក្នុងខែកញ្ញា ឆ្នាំ២០២០ បានបញ្ជាក់សារជាថ្មីអំពីការតាំងចិត្តរបស់អាស៊ានក្នុងការធានាសមាហរណកម្មស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងគោលនយោបាយ និងក្របខណ្ឌថ្នាក់តំបន់នៅទូទាំងសហគមន៍ទាំង៣ របស់អាស៊ាន ៖ សហគមន៍នយោបាយ-សន្តិសុខ សហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គម-វប្បធម៌។ ការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាអនុសាសន៍មួយក្នុងចំណោម អនុសាសន៍សំខាន់ៗនៃការសិក្សាស្រាវជ្រាវក្នុងតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានធ្វើឡើងក្នុងឆ្នាំ២០២១ ក្រោមជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងអង្គការ UN Women។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ កើតចេញពីដំណើរការពិគ្រោះយោបល់ និងឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែង និងជាតុចូលរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធចម្រុះដែលធ្វើ ការងារស្តីពីសិទ្ធិស្ត្រី សមភាពយេនឌ័រ សន្តិភាព និងសន្តិសុខ នៅទូទាំងតំបន់អាស៊ាន។ ដំណើរការបែប បរិយាបន្នជាផ្នែកសំខាន់មួយនៃការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ អាស៊ានគាំទ្រទាំង ស្រុងចំពោះទស្សនៈនៃការសម្រេចបានសន្តិភាពប្រកបដោយនិរន្តរភាព និងបរិយាបន្ន ដូចដែលលោក E. Phanthavong អគ្គលេខាធិការរងនៃសហគមន៍សង្គម-វប្បធម៌អាស៊ាន បានថ្លែងថា "បច្ចុប្បន្នគោលការណ៍ស្នូលនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានភាពពាក់ព័ន្ធខ្លាំងជាងពេលណាៗទាំង អស់។ វិបត្តិកូវីដ-១៩ បានបញ្ជាក់ឡើងវិញនូវមេរៀន ដែលទទួលបានពីវិបត្តិថ្មីមួយផ្សេងទៀត ដើម្បី រិះរក និងសម្រេចឱ្យបាននូវដំណោះស្រាយប្រកបដោយនិរន្តរភាព សម្រាប់បញ្ហាសង្គមដ៏ស្មុគស្មាញ អ្វីដែលសំខាន់គឺត្រូវតែបញ្ចូលនូវទស្សនៈយេនឌ័រ ដើម្បីស្វែងយល់ពីផលប៉ះពាល់ និងបង្កើតការឆ្លើយតបប្រកបដោយបរិយាបន្ន សម្រាប់ការស្តារឡើងវិញ និងបង្កើនភាពធន់របស់សហគមន៍ និងប្រជាជាតិទាំងឡាយ[1]"។ ជាការពិត អ្នកដែលមិនត្រូវបានរាប់បញ្ចូល និងគ្របដណ្តប់ដោយគំនិតផ្តួចផ្តើមឆ្លើយតបនឹងជំងឺរាតត្បាត ច្រើនតែជាអ្នកឆ្លងជំងឺ[2] ដែលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានលើសន្តិសុខ និងវិបុលភាពសម្រាប់ប្រជាជនទាំងអស់។ នេះក៏ជាការពិតផងដែរ សម្រាប់បញ្ហាសន្តិសុខផ្សេងទៀត ដូចជាជម្លោះ អំពើហិង្សាជ្រុលនិយម និងការគំរាមកំហែងលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត៖ អ្នកដែលមិនបានចូលរួម ក្នុងការដោះស្រាយបញ្ហាទាំងនេះ នឹង មិនចាត់ទុកថាបានរួមចំណែកដល់ការសម្រេចបានសន្តិភាពប្រកបដោយនិរន្តរភាពទេ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ កត់សម្គាល់តួនាទីចាំបាច់របស់ប្រជាជនគ្រប់រូប រួមទាំងស្ត្រី បុរស យុវជន សង្គមស៊ីវិល និងអ្នកដែលស្ថិតនៅជួរមុខនៃការដោះស្រាយជម្លោះ និងគ្រោះអាសន្ន ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខឱ្យបានជោគជ័យ។ ការលើកឡើងពី

---

1 Remarks during the first meeting of the Expanded Advisory Group on Women, Peace and Security in ASEAN. See: https://asean.org/asean-develops-regional-plan-of-action-to-advance-women-peace-and-security-agenda/

2 ភស្តុតាងបង្ហាញថា អ្នកដែលត្រូវបានគ្របដណ្តប់ដោយវិធានការសុខភាពសាធារណៈ ដើម្បីប្រយុទ្ធប្រឆាំងការឆ្លងរាលដាលជំងឺកូវីដ-១៩ មិនសូវឆ្លង និងចម្លងវីរុសកូរ៉ូណាឡើយ។ សូមមើល ឧ. https://med.stanford.edu/news/all- news/2021/09/surgical-masks-covid-19.html ។

វិសមភាព ការប្រឆាំងនឹងការរើសអើង និងការបង្កើនប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមស្តីពីសន្តិភាព និងសន្តិសុខ នឹងរំលេចអត្ថប្រយោជន៍នៃស្ត្រី សន្តិភាព និងសន្តិសុខ នៅទូទាំងសង្គមទាំងមូល និងហួសពីវិស័យសន្តិសុខ។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បែកចេញជា ៦ ផ្នែក។ ផ្នែកទី ១ ផ្តល់ទិដ្ឋភាពរួមស្តីពីកត្តាបរិបទពាក់ព័ន្ធ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ កត់សម្គាល់ភាពត្រួតគ្នា និងភាពប្រសព្វគ្នានៃការគំរាមកំហែង និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ និងត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីដែលកំពុងលេចឡើង ដូចជា ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ[3] ជំងឺរាតត្បាត និងអំពើហិង្សាជ្រុលនិយម។ ផ្នែកទី ២ ពិភាក្សាពីក្របខណ្ឌថ្នាក់សកល និងក្របខណ្ឌតំបន់អាស៊ានសំខាន់ៗ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ផ្អែកលើក្របខណ្ឌថ្នាក់សកលដែលមានស្រាប់ និងគំនិតផ្តួចផ្តើមថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន និងខិតខំបង្កើនឥទ្ធិពលនៃការងារជាបន្តបន្ទាប់នេះ ក៏ដូចជាលុបបំបាត់គម្លាត។ ផ្នែកទី ៣ កំណត់រកគម្លាតទាំងនេះតាម រយៈការបង្ហាញពីទិដ្ឋភាពរួមនៃវឌ្ឍនភាព បញ្ហាប្រឈម និងឱកាសដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។ សនិទានភាព និងគោលបំណងសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានលើកមកពិភាក្សាក្នុងផ្នែកទី ៤ ហើយទិដ្ឋភាពរួមនៃដំណើរការរៀបចំផែនការថ្នាក់តំបន់នេះ មានរៀបរាប់លម្អិតក្នុងផ្នែកទី ៥។ ផ្នែកសេសសល់នៃផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រៀបរាប់ពីក្របខណ្ឌផ្អែកតាមលទ្ធផលសម្រាប់ការអនុវត្តដែលលម្អិតពី៖ (១) សកម្មភាពអាទិភាពដែលគួរអនុវត្ត (២) លទ្ធផលរំពឹងទុក[4]ពីសកម្មភាពទាំងនេះ និង (៣) លទ្ធផលចុងក្រោយដែលផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ចង់សម្រេចបាន។

តារាងសកម្មភាពអាទិភាពចែកចេញជា ៤ តារាងផ្សេងៗគ្នា ដោយតារាងនីមួយៗដែលបង្ហាញពី សសរស្តម្ភសំខាន់ៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ការការពារ ការចូលរួម ការទប់ស្កាត់ និងការសង្គ្រោះ និងស្តារឡើងវិញ)។ តារាងទី ៥ ផ្តោតលើការអនុវត្តការសម្របសម្រួល ការរាយការណ៍ និងការពិនិត្យតាមដាន និងវាយតម្លៃ។ ការរៀបចំតារាងទាំងនេះមានគោលបំណងតម្រែតម្រង់កិច្ចខិតខំប្រឹងប្រែងនានាដើម្បីធានាថា ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានដាក់បញ្ចូលក្នុងកិច្ចខិតខំប្រឹងប្រែង និងគំនិតផ្តួចផ្តើមទាំងអស់ សំដៅលើកកម្ពស់សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។

គោលបំណងចម្បងនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺការផ្តល់ការណែនាំច្បាស់លាស់ សម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅទូទាំងតំបន់ អាស៊ាន។ ផែនការនេះនឹងផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ធានាថា ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ នឹងឆ្លើយតបទៅនឹងអាទិភាពសន្តិភាព និងសន្តិសុខនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង តថភាពជាក់ស្តែងផ្អែកលើភស្តុតាង។ អាស៊ានបានអនុវត្តជាយូរមកហើយនូវអភិក្រមបែបនវានុវត្តន៍ស្តីពីសន្តិភាព និងសន្តិសុខសម្រាប់ប្រទេសនីមួយៗ ដែលជារឿយៗ ដឹកនាំដោយស្ត្រី។ គោលបំណងមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនេះ គឺគូសបញ្ជាក់ពីការអនុវត្តល្អបំផុតទាំងនេះដើម្បីបំផុសការអនុវត្តកាន់តែទូលំទូលាយក្នុងករណីពាក់ព័ន្ធ និងគាំទ្រដល់ការបង្កើតទំនាក់ទំនងដែលផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមករវាងគំនិតផ្តួចផ្តើមថ្មីៗក្នុងប្រទេសនីមួយៗ និងអភិក្រមថ្នាក់ជាតិ និងអភិក្រមថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ មានឧទាហរណ៍ជាច្រើនដែលបង្ហាញអំពីការ អនុវត្តអភិក្រមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងភាពជាដៃគូក្នុងតំបន់អាស៊ានប្រកបដោយជោគជ័យ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខិតខំគាំទ្រដល់ការអនុវត្តដែលមានប្រសិទ្ធភាពទាំងនេះ និងជំរុញឱ្យមានការសម្រេចបានវឌ្ឍនភាពពិតប្រាកដសម្រាប់ស្ត្រី បុរស យុវជន កុមារ និងអ្នកដែលមកពីក្រុមងាយរងគ្រោះ នៅទូទាំងតំបន់អាស៊ាន។

---

3 ពាក្យ "គ្រោះមហន្តរាយ" ក្នុងផែនសកម្មភាពតំបន់អាស៊ាន សំដៅលើភ័យវិបត្តិ និងព្រឹត្តិការណ៍បរិស្ថានជាច្រើន ដូចជា ការហៀរកំពប់ប្រេង ទឹកជំនន់ ព្យុះសង្ឃរា រញ្ជួយដី។ល។ ដែលអាចបង្កឡើងដោយធម្មជាតិ និង/ឬមនុស្ស។ សម្រាប់ឯកសារយោង និងការពិភាក្សាបន្ថែម សូមមើល ASEAN Agreement on Disaster Management and Emergency Response 2021-2025។

4 ផ្នែកទី ២ នៃឯកសារនេះ ដែលផ្តល់ការពិភាក្សាបន្ថែមស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ កំណត់និយមន័យពាក្យ ដូចជា "លទ្ធផលចុងក្រោយ" និង "លទ្ធផលរំពឹងទុក" ដែលត្រូវបានប្រើប្រាស់ក្នុងតារាងសកម្មភាពអាទិភាព និងពិភាក្សាផងដែរពីជំហានបន្ទាប់សម្រាប់ការរៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃកាន់តែគ្រប់ជ្រុងជ្រោយ។

# អក្សរកាត់

| | |
|---|---|
| AADMER | កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបបន្ទាន់ |
| ACDM | គណៈកម្មាធិការអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ |
| ACMW | គណៈកម្មាធិការអាស៊ានសម្រាប់ការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកម្មករទេសន្តរប្រវេសក៍ |
| ACTIP | អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| ACSC | សន្និសីទអាស៊ានស្តីពីសង្គមស៊ីវិល |
| ACW | គណៈកម្មាធិការស្ត្រីអាស៊ាន |
| ACWC | គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| AICHR | គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស |
| AMMTC | កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន |
| AMS | រដ្ឋជាសមាជិកអាស៊ាន |
| APF | វេទិកាប្រជាជនអាស៊ាន |
| APSC | សហគមន៍នយោបាយ-សន្តិសុខអាស៊ាន |
| ARF | វេទិកាតំបន់អាស៊ាន |
| ASCC | សហគមន៍សង្គម-វប្បធម៌អាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ានអាគ្នេយ៍ (អាស៊ាន) |
| ASEAN-IPR | វិទ្យាស្ថានអាស៊ានស្តីពីសន្តិភាព និងការសម្រុះសម្រួល |
| ASEAN-UN POA | ផែនការសកម្មភាពអាស៊ាន-អង្គការសហប្រជាជាតិ ឆ្នាំ ២០២១-២០២៥ |
| ASEC | លេខាធិការដ្ឋានអាស៊ាន |
| AGMSF | ក្របខណ្ឌយុទ្ធសាស្ត្រអាស៊ានសម្រាប់ការបញ្ជ្រាបយេនឌ័រ |
| AWEN | បណ្តាញសហគ្រិនស្ត្រីអាស៊ាន |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រី |
| CSO | អង្គការសង្គមស៊ីវិល |
| DDR | ការដកអាវុធ រំសាយកងទ័ព និងសមាហរណកម្ម |

| | |
|---|---|
| **DRR** | ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ |
| **EU** | សហភាពអឺរ៉ុប |
| **EVAW** | ការលុបបំបាត់អំពើហិង្សាលើស្ត្រី |
| **GBV** | អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ |
| **JS** | សេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន |
| **NAP** | ផែនការសកម្មភាពជាតិ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **OECD** | អង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច |
| **PROSPECT** | ភាពជាដៃគូសម្រាប់បង្កើនប្រសិទ្ធភាពក្នុងតំបន់ជាមួយ សហគមន៍នយោបាយ-សន្តិសុខអាស៊ាន និង សហគមន៍សង្គម-វប្បធម៌អាស៊ាន |
| **RAN-P3AKS** | ផែនការសកម្មភាពជាតិស្តីពីការបង្កើនភាពអង់អាច និងការការពារស្ត្រី និងកុមារក្នុងជម្លោះសង្គម (ឥណ្ឌូនេស៊ី) |
| **RPA WPS** | ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ |
| **SFDRR** | ក្របខណ្ឌសេនដាយ (Sendai) សម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ |
| **SGBV** | អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ |
| **SDG** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **SOMTC** | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន |
| **SSR** | កំណែទម្រង់វិស័យសន្តិសុខ |
| **TIP** | ការជួញដូរមនុស្ស |
| **TOR** | លក្ខខណ្ឌយោង |
| **UNDPO** | នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ |
| **UNSCR** | សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| **VAW** | អំពើហិង្សាលើស្ត្រី |
| **WG-CT** | ក្រុមការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្ម |
| **WPS** | ស្ត្រី សន្តិភាព និងសន្តិសុខ |



# ១. ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ

## ១.១ សាវតារ

សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) រៀបរាប់ពីក្របខណ្ឌមូលដ្ឋានសម្រាប់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងជះឥទ្ធិពល លើ សសរស្តម្ភទាំង ៤ នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ ការចូលរួម ការការពារ ការទប់ស្កាត់ និងការសង្គ្រោះ និងស្តារឡើងវិញ។ បន្ទាប់ពីត្រូវបានអនុម័តជាងពីរទសវត្សរ៍កន្លងមក របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បានជំរុញឱ្យមានកិច្ចខិតខំប្រឹងប្រែងនានាដើម្បីជានាឱ្យមានការទទួលស្គាល់ការរួមចំណែកដ៏សំខាន់របស់ស្ត្រីដល់សន្តិភាព និងសន្តិសុខ និងលើកកម្ពស់ការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងស្ថាប័ន និងដំណើរការសន្តិភាព និងសន្តិសុខទាំងអស់ រួមទាំងក្នុងមុខតំណែងជាអ្នកដឹកនាំ។ របៀបវារៈនេះក៏បានទាក់ទាញឱ្យមានការផ្តោតការយកចិត្តទុកដាក់លើភាពចាំបាច់ក្នុងការការពារយ៉ាងពេញលេញនូវសិទ្ធិរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបាននូវសន្តិភាព និងសន្តិសុខផង ដែរ។ ចំណុចនេះមិនត្រឹមតែរួមបញ្ចូលវិធានការដើម្បី "ការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ជាពិសេសអំពើរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទ" ក្នុងពេលមានជម្លោះប្រដាប់អាវុធ (UNSCR 1325) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលការការពារយ៉ាងពេញលេញនូវសិទ្ធិរបស់ស្ត្រីក្នុងពេលមានសន្តិភាព ក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ និងក្នុងពេលសង្គ្រោះ និងស្តារឡើងវិញទៀតផង។

ការសន្មតមួយក្នុងចំណោមការសន្មតសំខាន់ៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីឱ្យមានគោលនយោបាយសន្តិភាព និងសន្តិសុខ រួមទាំងការអនុវត្តប្រកបដោយប្រសិទ្ធភាពផងដែរ របៀបវារៈនេះត្រូវកំណត់ និងឆ្លើយតបទៅនឹងតម្រូវការ និងបទពិសោធន៍ផ្សេងៗរបស់ស្ត្រី និងបុរស រួមទាំងតម្រូវការរបស់អ្នកដែលមកពីក្រុមងាយរងគ្រោះ។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មិនមែនជារបៀបវារៈសម្រាប់តែស្ត្រីនោះទេ ប៉ុន្តែក៏ជារបៀបវារៈសមភាពយេនឌ័រ និងសន្តិភាពដែលខិតខំស្វែងយល់ពីផលប៉ះពាល់មកលើសន្តិសុខរបស់ស្ត្រីគ្រប់រូប និងបុរសដើម្បីជានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពផងដែរ។ ដើម្បីសម្រេចបានសន្តិភាពដែលមាននិរន្តរភាព ចាំបាច់ត្រូវយល់កាន់តែច្បាស់ គោរព និងផ្អែកតាមបទពិសោធន៍ និងចំណេះដឹងផ្ទាល់ខ្លួនរបស់ស្ត្រីក្នុងស្ថានភាពមានជម្លោះ។

របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខទូទៅ ដូចជា ជម្លោះប្រដាប់អាវុធ ក៏ដូចជាការគំរាមកំហែងថ្មីៗកំពុងលេចឡើងលើសុខភាព និងសុខុមាលភាព ដូចជា ជំងឺកូវីដ-១៩ និងវិបត្តិសុខភាពផ្សេងទៀត ការប្រែប្រួលអាកាសធាតុ និងការជួញដូរមនុស្ស។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាសន្តិសុខទាំងនេះ និងបញ្ហាសន្តិសុខស្មុគស្មាញផ្សេងទៀត ផ្អែកលើសមត្ថភាពនៃការស្វែងយល់ និងកំណត់តម្រូវការរបស់ប្រជាជនទាំងអស់នៅក្នុងសង្គម ព្រមទាំងជានាឱ្យបាននូវ បរិយាបន្នពេញលេញសម្រាប់ស្ត្រី ដែលជានិច្ចជាកាលគឺជាអ្នកឆ្លើយតបជួរមុខ ហើយក៏ជាអ្នកខិតខំប្រឹងប្រែងដឹងនាំរៀបចំ និងអនុវត្តដំណោះស្រាយនានាផងដែរ[5]។ ក្រៅពីនេះ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ឆ្លុះបញ្ចាំងពីទិដ្ឋភាពសន្តិសុខធំទូលាយហួសពីស្ថានភាពគ្មានជម្លោះ ដើម្បីរួមបញ្ចូលទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គម-វប្បធម៌នៃសន្តិសុខ និងរំលេចភាពប្រទាក់ក្រឡាគ្នានៃទិដ្ឋភាពទាំងនេះ។ ការយល់ច្បាស់ពីសន្តិសុខ ដូចបានរៀបរាប់ខាងលើ ជាមូលដ្ឋានសម្រាប់សសរស្តម្ភទាំង ៤ នៃរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ឧ. សម្រាប់គោលនយោបាយស្តីពីកិច្ចការពារ ចាំបាច់ត្រូវគាំទ្រដល់ លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានឱកាសប្រកបរបរចិញ្ចឹមជីវិត និងសិទ្ធិរបស់ក្មេងស្រីក្នុងការទទួលបានការសិក្សា រួមទាំងក្នុងពេលឆ្លើយតបនឹងស្ថានភាពអាសន្នផ្នែកមនុស្សធម៌។ ក្នុងកិច្ចខិតខំប្រឹងប្រែង ទប់ស្កាត់ជម្លោះ ត្រូវពិចារណាពីកត្តាសង្គម-វប្បធម៌ និងសេដ្ឋកិច្ចដែលជំរុញឱ្យមានអំពើហិង្សា និង អស្ថិរភាព ដោយគិតគូរពីបទពិសោធន៍របស់ស្ត្រី និងបុរស។

ស្ត្រី សន្តិភាព និងសន្តិសុខ ជាអាទិភាពសម្រាប់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) អនុលោមតាមមាត្រា ១ នៃធម្មនុញ្ញអាស៊ាន ដែលចែងថា "ធានាថា ប្រជាជន និងរដ្ឋជាសមាជិកអាស៊ានរស់នៅប្រកបដោយសន្តិភាពជាមួយពិភពលោកទាំងមូល ក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា"។ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះស្ត្រី សន្តិភាព និងសន្តិសុខ ថ្នាក់ដឹកនាំអាស៊ាន បានអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន ក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១ ដែលធ្វើឡើងនៅខែ វិច្ឆិកា ឆ្នាំ ២០១៧។ សេចក្តីថ្លែងការណ៍នេះកត់សម្គាល់ពី សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ សន្តិសុខ និងយុត្តិធម៌ និងលើកទឹកចិត្តឱ្យស្ត្រីចូលរួមយ៉ាងពេញលេញក្នុងដំណើរការសន្តិភាពក្នុងនាមជាអ្នកចរចា អ្នកផ្សះផ្សារ និងអ្នកឆ្លើយតបបឋម។ សេចក្តីថ្លែងការណ៍នេះក៏ទទួលស្គាល់ផងដែរថា ការរក្សាសន្តិភាព និងសន្តិសុខ ទាមទារការផ្តោតការយកចិត្តទុកដាក់លើឱកាសសេដ្ឋកិច្ច ការថែទាំសុខភាព និងវិធានការឆ្លើយតបនឹងជំងឺរាតត្បាត ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ ក៏មានការលើកឡើងពីសារៈសំខាន់នៃការទប់ស្កាត់ផងដែរ ក្នុង

---

5 Ekkaphab Phanthavong, Deputy Secretary-General for the ASEAN Socio-Cultural Community, in his remarks made at the First Meeting of the Expanded Advisory Group on Women, Peace and Security in ASEAN, held virtually on 28 January 2022. See: https://asean.org/asean-develops-regional-plan-of-action-to-advance-women- peace-and-security-agenda/. Also quoted in Integrating the WPS agenda in the ASEAN, prepared by Aurora Javate de Dios and the Philippine Center for Islam and Democracy (PCID), 5 April 2022 in preparation for the ASEAN WPS Advisory Group meeting.

នោះ អាស៊ានប្ដេជ្ញាដោះស្រាយឫសគល់នៃជម្លោះប្រដាប់អាវុធ និងអំពើហិង្សាជ្រុលនិយម រួមទាំងវិសមភាពយេនឌ័រ ការរើសអើង និងភាពក្រីក្រ។ សេចក្ដីថ្លែងការណ៍ដំបូងរបស់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានបញ្ជាក់ឡើងវិញដោយសេចក្ដី ថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានក្នុងឆ្នាំ ២០១៩[6]។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ការពន្លឿនរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ានមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាពិសេសក្នុងស្ថាប័នតាមវិស័យក្រោមសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC) និងសហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC)។ ឧ. ផែនការសកម្មភាពអាស៊ាន- អង្គការសហប្រជាជាតិ (POA) ឆ្នាំ ២០២១-២០២៥[7] ដែលត្រូវបានអនុម័តនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ មានគោលបំណងលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ ជាអភិក្រមពហុភាគីសម្រាប់ការធានាសន្តិភាព និងសន្តិសុខក្នុងតំបន់ និងសកលលោក។ ការបញ្ជ្រាបយេនឌ័រ និងកិច្ចសហការអន្តរ វិស័យ ជាកត្តាសំខាន់សម្រាប់ការពន្លឿនរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅអាស៊ានក្នុងផែនការ សកម្មភាពអាស៊ាន-អង្គការសហប្រជាជាតិ (POA) លើកទី ២[8]។

ដូចការគូសបញ្ជាក់ខាងលើ រដ្ឋជាសមាជិកអាស៊ាន (AMS) បានកត់សម្គាល់ពីសារៈសំខាន់នៃកិច្ចសហការគ្នាឆ្លើយតបនឹងការគំរាមកំហែងទូទៅ និងការគំរាមកំហែងថ្មីៗលើសន្តិសុខ និងបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចឆ្លងដែន ដោយទទួលស្គាល់តួនាទីសំខាន់របស់ស្ត្រី រួមបញ្ចូលទាំងការចូលរួមរបស់ស្ត្រី និងការឆ្លើយតបតាមរបៀបផ្សេងៗ ពាក់ព័ន្ធនឹងអំពើហិង្សា និងអស្ថិរភាពដែលបង្កឱ្យមានផលប៉ះពាល់លើស្ត្រី និងបុរស។

មានភាពជឿនលឿនពាក់ព័ន្ធនឹងសមភាពយេនឌ័រនៅអាស៊ាន និងឧទាហរណ៍នៃការកសាងសន្តិភាពដ៏មានប្រសិទ្ធភាពដោយស្ត្រី និងត្រូវបានកំណត់យកជាការអនុវត្តល្អបំផុត នៅជុំវិញពិភពលោក។ អាស៊ាននឹងប្រើប្រាស់ការអនុវត្តល្អទាំងនេះជាមូលដ្ឋានសម្រាប់ការជំរុញវឌ្ឍនភាពនៃការលើកកម្ពស់សមភាព យេនឌ័រ និងបរិយាបន្ន តាមរបៀបដែលឆ្លើយតបនឹងឱកាស និងបញ្ហាប្រឈមនៃបរិបទជាក់លាក់នៅក្នុងតំបន់ដ៏ចម្រុះនេះ។ ខណៈដែលមានការកត់សម្គាល់ពីភាពចាំបាច់នៃអភិក្រមឆ្លងវិស័យ និងទូទាំងសសរស្ដម្ភរបស់អាស៊ានសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខ[9] និងមានកិច្ចសហការមួយចំនួនក្នុងសហគមន៍ទាំង ៣ របស់អាស៊ានលើបញ្ហានានា ដូចជាការទប់ស្កាត់អំពើហិង្សាជ្រុលនិយម និងការឆ្លើយតបនឹងគ្រោះមហន្តរាយ ចាំបាច់ត្រូវពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងចំណោមយន្តការស្ថាប័នដែលមានភារៈអនុវត្តអភិក្រមនេះ ដើម្បីឈានទៅសម្រេចនូវគោលបំណងដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។

ជំងឺកូវីដ-១៩ និងបញ្ហាសន្តិសុខផ្សេងទៀតដែលកំពុងលេចឡើង ដូចជា ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសបច្ចេកវិទ្យា ការជួញដូរមនុស្ស គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាជ្រុលនិយម បាននាំឱ្យមានការពិនិត្យឡើងវិញលើអត្ថន័យនៃសន្តិសុខនៅក្រៅជម្លោះប្រដាប់អាវុធ។ វិសាលភាពនៃអ្វីដែលបង្កើតបានជាសន្តិសុខ រាប់បញ្ចូលទាំងការគំរាមកំហែងលើសន្តិសុខមនុស្សដែលផ្ទុយពីការពិចារណាលើបញ្ហាសន្តិសុខជាតិទូទៅ[10]។ ក្នុងអំឡុងវិបត្តិកូវីដ-១៩ ដែលបង្កបញ្ហាប្រឈមមួយចំនួនលើសន្តិសុខ របៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខមានភាពពាក់ព័ន្ធជាងពេលណាៗទាំងអស់។ ដូចការគូសបញ្ជាក់ក្នុងការសិក្សាស្រាវជ្រាវក្នុងតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ "ជំងឺកូវីដ-១៩ បានបង្កើនហានិភ័យសម្រាប់ស្ត្រី និងក្មេងស្រី ក្នុងបរិបទមនុស្សធម៌ បរិបទផុយស្រួយ និងបរិបទក្រោយជម្លោះ។ ការរាំងស្ទះដល់កម្មវិធីសំខាន់ៗដែលពាក់ព័ន្ធនឹងសុខភាព មនុស្សធម៌ និងការអភិវឌ្ឍ អាចធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត និងអាចរឹតត្បិតលទ្ធភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសិទ្ធិ សុខភាពផ្លូវភេទ និងបន្តពូជ ជាពិសេសក្នុងករណីដែលប្រព័ន្ធសុខាភិបាលរងបន្ទុកធ្ងន់ធ្ងររួចទៅហើយ ឬភាគច្រើន មិនមានប្រព័ន្ធនេះតែម្ដង[11]។ក្រៅពីនេះ សេចក្ដីរាយការណ៍បង្ហាញថា វិបត្តិកូវីដ-១៩ បានបង្កើនការប្រព្រឹត្តអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ[12] កាត់បន្ថយឱកាសការងាររបស់ស្ត្រី និងនាំឱ្យមានការ

6 See ASEAN Secretariat, Joint Statement on Promoting Women, Peace, and Security in ASEAN, 2017. https://asean.org/wp-content/uploads/2021/01/8.-ADOPTION_Joint-Statement-on-Promoting-Women-Peace-and- Security-in-ASEANACWC-Endorsed_rev2.pdf

7 ផែនការនេះជាផែនការសកម្មភាពទី ២ រវាងអាស៊ាន និងអង្គការសហប្រជាជាតិ និងផ្អែកលើផែនការសកម្មភាពទី ១ (២០១៦-២០២០)។

8 See https://asean.org/wp-content/uploads/2021/09/ASEAN-UN-POA-2021-2025-final.pdf

9 ការអនុវត្តរបៀបវារៈឆ្លងវិស័យស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានកត់សម្គាល់នៅអំឡុងសន្និសីទថ្នាក់តំបន់ស្ដីពីការអនុវត្តរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន កាលពីថ្ងៃទី ២២-២៣ ខែ សីហា ឆ្នាំ ២០១៩ ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដែលរៀបចំឡើងដោយក្រសួងកិច្ចការនារីកម្ពុជា ក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋានអាស៊ាន គណៈកម្មាធិការស្ត្រីអាស៊ាន (ACW) គណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ក្រោមការគាំទ្រពីគម្រោងភាពជាដៃគូ ASEAN-USAID លើកកម្ពស់សហគមន៍នយោបាយ-សន្តិសុខ និងសហគមន៍សង្គម-វប្បធម៌ថ្នាក់តំបន់ (គម្រោង PROSPECT) និងអង្គការ UN Women និងកិច្ចសន្ទនាថ្នាក់រដ្ឋមន្ត្រីអាស៊ានស្ដីពីការពង្រឹងតួនាទីរបស់ស្ត្រីដើម្បីសន្តិភាព និងសន្តិសុខប្រកបដោយនិរន្តរភាព កាលពីខែ កញ្ញា ឆ្នាំ ២០២០។

10 ASEAN, ASEAN Regional Study on Women, Peace and Security, March 2020, available at https://asean.org/book/asean-regional-study-on-women-peace-and-security/.

11 Ibid., p. 9.

12 See for example, UNESCAP, "The Covid 19 Pandemic and Violence Against Women in Asia and Pacific," 23 November 2020. https://www.unescap.org/resources/covid-19-pandemic-and-violence-against-women-asia-and- pacific

កើនឡើងនៃការងារថែទាំ និងការងារតាមផ្ទះដែលមិនទទួលបានប្រាក់ឈ្នួលសម្រាប់ស្ត្រី ក្នុងបរិបទនៃការរក្សាគម្លាតសុវត្ថិភាពសង្គម និងចត្តាឡីស័ក។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ ត្រូវបានរៀបចំឡើងក្នុងអំឡុងវិបត្តិកូវីដ-១៩ និងនៅពេលដែលមិនទាន់មានការយល់ដឹង ឬការវាស់វែងពេញលេញអំពីផលវិបាកនៃវិបត្តិនេះ។ ដូច្នេះ ការអនុវត្តផែនការសកម្មភាពនេះត្រូវធ្វើឡើងឱ្យបានឆាប់រហ័សដោយផ្អែកតាមទិន្នន័យថ្មីៗ និងការស្វែងយល់ពីផលប៉ះពាល់ដ៏ស្មុគស្មាញនៃជំងឺកូវីដ-១៩ និងខុសៗគ្នាលើស្ត្រី បុរស និងក្រុមងាយរងគ្រោះ។

ក្របខណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (២០២០) កំណត់យកសមភាពយេនឌ័រជាអាទិភាពឆ្លងវិស័យ និងគូសបញ្ជាក់ថាគួរធានាការពារសិទ្ធិមនុស្សក្នុងដំណើរការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ ឆ្ពោះទៅរកតំបន់ដែលមានភាពធន់[13]។ មានការកត់សម្គាល់កាន់តែច្រើនឡើងពីភាពចាំបាច់នៃការដឹកនាំរបស់ស្ត្រី និងការដាក់បញ្ចូលស្ត្រីឱ្យបានពេញលេញទៅក្នុងការឆ្លើយតប និងការស្តារឡើងវិញពីវិបត្តិកូវីដ-១៩ នៅថ្នាក់តំបន់។ កិច្ចប្រជុំកំពូលពិសេសអាស៊ានស្តីពីការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុង យុគសម័យឌីជីថល (២០២០) កិច្ចប្រជុំឆ្នាំ ២០២១ របស់សមាជិកសភាស្ត្រីអាស៊ាន នៅមហាសន្និបាត អន្តរសភាអាស៊ាន និងកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី ១ (២០២០) សុទ្ធតែគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការកត់សម្គាល់ និងគាំទ្រពេញទំហឹងដល់ការដឹកនាំរបស់ស្ត្រីនៅពេលដែលតំបន់អាស៊ានឆ្លើយតប និងស្តារឡើងវិញពីវិបត្តិកូវីដ-១៩។ "ថ្នាក់ដឹកនាំអាស៊ានបានទទួលស្គាល់តួនាទី និងការរួមចំណែកដ៏សំខាន់របស់ស្ត្រីដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការរក្សាសន្តិភាព និងសន្តិសុខនៅជុំវិញពិភពលោក និងក្នុងតំបន់ អាស៊ាន។ តួនាទីដ៏សំខាន់របស់ស្ត្រីត្រូវបានបង្ហាញឡើងយ៉ាងច្បាស់ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ព្រោះអ្នកឆ្លើយតបជួរមុខ បុគ្គលិកសង្គមកិច្ច អ្នកជំនាញសុខភាព និងអ្នកស្ម័គ្រចិត្ត ក៏ដូចជាអ្នកថែទាំនៅផ្ទះនៅ ក្នុងសហគមន៍ ភាគច្រើនគឺជាស្ត្រី[14]"។ ទោះជាយ៉ាងណាក្តី ក៏តំណាងរបស់ស្ត្រីនៅតែចំនួនតិចតួចក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅតំបន់អាស៊ាន។ ក្នុងចំណោមក្រុមការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ទាំង ១១ ក្រុម ក្នុងរដ្ឋជាសមាជិកអាស៊ានចំនួន ៨ (ដែលមានទិន្នន័យ) ស្ត្រីមានសមាសភាគតែ ២៥% ប៉ុណ្ណោះ (ឬតិចជាងនេះ)។ ក្នុងចំណោមក្រុមការងារទាំង ១១ ក្រុម មាន ៣ ក្រុមដែលមិនមានសមាសភាពស្ត្រី[15]។

នៅពេលអាស៊ាន និងរដ្ឋជាសមាជិកអាស៊ានសង្កេតមើលបញ្ហាប្រឈមនៅក្នុងតំបន់នាពេលអនាគតដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ និងស្ថានភាពអាសន្នផ្នែក សុខភាពសាធារណៈ ដូចជា ជំងឺរាតត្បាត ជំងឺកូវីដ-១៩ បានផ្តល់មេរៀនសំខាន់ៗមួយចំនួន ដើម្បីធានានូវការដាក់បញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងការឆ្លើយតបដទៃទៀតនាពេលអនាគត។ ក្នុងអំឡុងកិច្ចសន្ទនាថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីការពង្រឹងតួនាទីរបស់ស្ត្រីដើម្បីសន្តិភាព និងសន្តិសុខប្រកបដោយនិរន្តរភាព ដែលបានប្រព្រឹត្តទៅនៅខែ កញ្ញា ឆ្នាំ ២០២០ រដ្ឋមន្ត្រីការបរទេសអាស៊ានបានកត់សម្គាល់ថា ស្ត្រីប្រឈមនឹងហានិភ័យខ្លាំងជាងបុរស តាមរយៈការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបណ្តាលមកពីវិបត្តិកូវីដ-១៩។ ដូច្នេះរដ្ឋមន្ត្រីការបរទេសអាស៊ានបានលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការ ក្នុងការដាក់បញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ "ទៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើ សមាហរណកម្មសេដ្ឋកិច្ចទូទាំងអាស៊ាន និងសម្របសម្រួលការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ដែលជាចំណុចសំខាន់ក្នុងដំណើរការទប់ស្កាត់ ដោះស្រាយ និងស្តារឡើងវិញពីជម្លោះ[16]"។

# ១.២ ក្របខណ្ឌថ្នាក់សកល និងក្របខណ្ឌថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

## ១.២.១ ក្របខណ្ឌថ្នាក់សកល

សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR 1325) ដែលត្រូវបានអនុម័តនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០០ បន្ទាប់ពីការ តស៊ូមតិពីសំណាក់អង្គការស្ត្រី និងសង្គមស៊ីវិល បានបញ្ជាក់ពីភាពចាំបាច់នៃការចូលរួមដោយស្មើភាព និងពេញលេញរបស់ស្ត្រី ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នាដើម្បីរក្សា និងលើកកម្ពស់សន្តិភាព និងសន្តិសុខ។ សេចក្តីសម្រេចនេះក៏អំពាវនាវផងដែរឱ្យរដ្ឋជាសមាជិករបស់អង្គការ សហប្រជាជាតិ បញ្ជ្រាបយេនឌ័រទៅគ្រប់ស្ថាប័ន និងសកម្មភាពទាំងអស់ ពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដើម្បីធានាថា ស្ថាប័ន និងសកម្មភាពទាំងនោះឆ្លើយតបនឹងតម្រូវការផ្សេងៗរបស់ស្ត្រី និងបុរស និងពិចារណាពី

---

13 ASEAN, ASEAN Comprehensive Recovery Framework, November 2020, available at https://asean.org/book/asean-comprehensive-recovery-framework-implementation-plan/

14 Chairman's Press Statement of ASEAN Women Leaders' Summit, "Women's Role in Building a Cohesive, Dynamic, Sustainable and Inclusive ASEAN Community in a Post COVID-19 World." 12 November 2020).

15 See, UNDP and UN Women, COVID-19 Global Gender Response Tracker.

16 Chairman's Press Statement of the ASEAN Ministerial Dialogue on Strengthening Women's role for Sustainable Peace and Security (Ha Noi, 10 September 2020), para 8.

ផលប៉ះពាល់ផ្អែកតាមយេនឌ័រនៃអន្តរាគមន៍ និងកម្មវិធីរបស់ខ្លួន។

ក្រៅពីនេះ សេចក្តីសម្រេចលេខ ១៣២៥ អំពាវនាវឱ្យគ្រប់ភាគីដែលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ចាត់វិធានការពិសេសដើម្បីការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ រួមទាំងការរំលោភបំពានផ្លូវភេទ។ ខណៈដែលជារឿយៗ សេចក្តីសម្រេចលេខ ១៣២៥ ផ្តោតសំខាន់លើសិទ្ធិស្ត្រី និងកិច្ចការពារដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ សេចក្តីសម្រេចនេះក៏បញ្ជាក់ផងដែរពីភាពចាំបាច់នៃការការពារសិទ្ធិស្ត្រីឱ្យបានពេញលេញដោយស្ថាប័នសន្តិភាព និងសន្តិសុខ នៅក្នុងពេលមានសុខសន្តិភាព[17] តាមរយៈកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ និងក្នុងអំឡុងពេលជួយសង្គ្រោះ និងស្តារឡើងវិញ។ គោលបំណងដែលពាក់ព័ន្ធនឹងការចូលរួម ក៏មានលក្ខណៈចម្រុះផងដែរ ដូចជា ការអំពាវនាវឱ្យដាក់បញ្ចូលថ្នាក់ដឹកនាំជាស្ត្រីទៅក្នុងការចរចាសន្តិភាពកម្រិតខ្ពស់ និងគាំទ្រពេញលេញដល់ "គំនិតផ្តួចផ្តើមសន្តិសុខរបស់ស្ត្រីក្នុងមូលដ្ឋាន និងដំណើរការតាមមូលដ្ឋានសម្រាប់ការដោះស្រាយជម្លោះ" (UNSCR, 8b)។

ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងមកនេះ មានការអនុម័តសេចក្តីសម្រេចចំនួន ១០ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[18]។ កាតព្វកិច្ចក្នុងសេចក្តីសម្រេចស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានចាប់ពីថ្នាក់អន្តរជាតិ រហូតដល់ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ក្នុងនាមជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ រដ្ឋជាសមាជិកទាំងអស់មានកាតព្វកិច្ចអនុវត្តតាមសេចក្តីសម្រេចទាំងនេះ។ សេចក្តីសម្រេចទាំងនេះក៏រៀបរាប់ពីកាតព្វកិច្ចសម្រាប់តួអង្គពាក់ព័ន្ធផ្សេងទៀតផងដែរ ដូចជា ក្រុមមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងជម្លោះ អង្គការថ្នាក់តំបន់ និងអង្គការថ្នាក់អនុតំបន់ ទីភ្នាក់ងារអង្គការសហប្រជាជាតិ សង្គមស៊ីវិល ។ល។ សេចក្តីសម្រេចជាច្រើនអំពាវនាវឱ្យមានការពិគ្រោះយោបល់ និងការសម្របសម្រួលកាន់តែច្រើនរវាងភាគីផ្សេងៗ ជាពិសេសរវាងរដ្ឋជាសមាជិក និងសង្គមស៊ីវិល រួមទាំងអង្គការស្ត្រីផងដែរ។ កាតព្វកិច្ចទាំងអស់នោះរួមមានសកម្មភាពជាក់លាក់ដើម្បីទទួលស្គាល់ និងការពារសិទ្ធិរបស់ស្ត្រី និងក្មេងស្រី ក្នុងស្ថាប័ននិងប្រតិបត្តិការរក្សាសន្តិភាព និងសន្តិសុខ រួមទាំងក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ។ សេចក្តីសម្រេចទាំងនេះក៏អំពាវនាវផងដែរឱ្យគ្រប់ភាគីចាត់វិធានការយ៉ាងសកម្មក្នុងការទប់ស្កាត់អំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងបំពេញតម្រូវការរបស់ស្ត្រីក្នុងការទទួលបានសេវាសុខភាព និងសេវាទូលំទូលាយ ដូចជា ឱកាសសេដ្ឋកិច្ចជាដើម។ ក្រៅពីនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរៀបរាប់ពីការប្តេជ្ញាចិត្ត និងវិធានការនានា សម្រាប់លើកកម្ពស់ការចូលរួមយ៉ាងពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងសន្តិភាព និងសន្តិសុខ រួមទាំងក្នុងមុខតំណែងដឹកនាំ។ សេចក្តីសម្រេចទាំងនេះគ្របដណ្តប់លើបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលឆ្លុះបញ្ចាំងពីការគិតគូររបស់ក្រុមប្រឹក្សាសន្តិសុខ និងរដ្ឋជាសមាជិកថាចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរជាច្រើន ដើម្បីពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[19]។

ក្រៅពីសេចក្តីសម្រេចទាំង ១០ នេះ សេចក្តីសម្រេចជាច្រើនផ្សេងទៀតរបស់ក្រុមប្រឹក្សាសន្តិសុខ ផ្តោតលើបញ្ហាជាក់លាក់ដែលពាក់ព័ន្ធនឹងការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា សេចក្តីសម្រេចលេខ ២៥៣៨ (លើកឡើងដោយប្រទេ សឥណ្ឌូនេស៊ី) ស្តីពីយេនឌ័រ និងការរក្សា សន្តិភាព។ សេចក្តីសម្រេចនេះត្រូវបានអនុម័តជាឯកច្ឆនៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០[20] សេចក្តីសម្រេចផ្សេងទៀតផ្តោតលើជម្លោះជាក់លាក់ ប៉ុន្តែក៏បានរួមបញ្ចូលផងដែរនូវការអំពាវនាវឱ្យដាក់បញ្ចូលអាទិភាពស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងប្រតិបត្តិការសន្តិភាព និងសន្តិសុខ និងការឆ្លើយតប[21]។

បន្ទាប់ពីការអនុម័តសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អគ្គលេខាធិការអាស៊ាន និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានគូសបញ្ជាក់ពីភាពចាំបាច់ដែលប្រទេសទាំងអស់ត្រូវអនុវត្តគោលការណ៍នៃសេចក្តីសម្រេចលេខ ១៣២៥ តាមរយៈការបង្កើតផែនការសកម្មភាពជាតិ (NAP) ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អមជាមួយគោលដៅ និងការប្តេជ្ញាចិត្តជាក់ស្តែងសម្រាប់ជាមគ្គុទេសក៍នៃគោលនយោបាយជាតិ និងការបរទេស គោលនយោបាយសម្រាប់ ស្ថាប័ន និងគំនិតផ្តួចផ្តើមនានា។

---

17 ដូចជា "វិធានការដែលធានាការការពារ និងការគោរពសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី ជាពិសេសដោយសារតែវិធានការទាំងនោះពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញ ប្រព័ន្ធបោះឆ្នោត ប៉ូលីស និងតុលាការ" (UNSCR, 8c)។

18 Security Council Resolutions 1325 (2000), 1820 (2008), 1888 (2008), 1889 (2009), 1960 (2010), 2106 (2013), 2122 (2013), 2242 (2015), 2467 (2019), and 2493 (2019).

19 សម្រាប់ការវិភាគស៊ីជម្រៅលើខ្លឹមសារនៃសេចក្តីសម្រេចស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងអនុសាសន៍លេខ ៣០ នៃអនុសញ្ញា CEDAW សូមមើល UN Women, "Guidebook on CEDAW Recommendation No 30 and the UN Security Council Resolutions on Women, Peace and Security," 2015។

20 UN Security Council, Indonesia tabled UNSCR 2538 ដែលជាសេចក្តីសម្រេចដំបូងគេដែលផ្តោតជាពិសេសលើយេនឌ័រ និងការរក្សាសន្តិភាព។ ក្រោយការអនុម័តជាឯកច្ឆ័ននៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០ សេចក្តីសម្រេចនេះ អំពាវនាវឱ្យរដ្ឋសមាជិកទាំងអស់ ស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការថ្នាក់តំបន់ "ពង្រឹងកិច្ចខិតខំប្រឹងប្រែងជាសមូហភាពក្នុងការលើកកម្ពស់ការចូលរួមពេញលេញ ប្រកបដោយប្រសិទ្ធភាព និងអត្ថន័យរបស់ស្ត្រីជាកងកម្លាំង និងស្ត្រីជាជនស៊ីវិលក្នុងប្រតិបត្តិការរក្សាសន្តិភាពនៅគ្រប់កម្រិត និងក្នុងគ្រប់មុខតំណែងទាំងអស់ រួមទាំងក្នុងមុខតំណែងដឹកនាំជាន់ខ្ពស់"។ សេចក្តីសម្រេចនេះក៏លើកឡើងជាច្រើនលើកច្រើនសាពីសារៈសំខាន់នៃគោលនយោបាយមិនអត់អោនរបស់អង្គការសហប្រជាជាតិចំពោះការបៀតបៀនផ្លូវភេទក្នុងបេសកកម្មរក្សាសន្តិភាពផងដែរ។

21 ឧ. សេចក្តីសម្រេចលេខ ២៥៨៩ (ខែ សីហា ឆ្នាំ ២០២២) ដែលពាក់ព័ន្ធនឹងស្ថានភាពក្នុងប្រទេសម៉ាលី គូសបញ្ជាក់ពី "សារៈសំខាន់នៃការចូលរួមពេញលេញ ស្មើភាព និងប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងគ្រប់យន្តការទាំងអស់ ដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងនេះ (ស្តីពីសន្តិភាព និងការសម្រុះសម្រួលក្នុងប្រទេសម៉ាលី) ដើម្បីគាំទ្រ និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងនេះ។

កន្លងមក រដ្ឋជាសមាជិកចំនួន ៩៨ ប្រទេសរបស់អង្គការសហប្រជាជាតិ (៥១%) មានផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងនោះ មានផែនការសកម្មភាពជាតិចំនួន ៣៥ រួមបញ្ចូលទាំងការប្តេជ្ញាផ្តល់កញ្ចប់ថវិកា[22]។ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានប្រទេសចំនួន ១៣ បានអនុវត្តផែនការសកម្មភាពជាតិ។ ពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិដែលនឹងត្រូវបានលើកមកពិភាក្សាបន្ថែមនៅផ្នែកខាងក្រោម រដ្ឋជាសមាជិកអាស៊ានសម្រេចបាននូវ វឌ្ឍនភាពក្នុងការរៀបចំផែនការសកម្មភាពជាតិ និងក្របខណ្ឌគោលនយោបាយជាតិផ្សេងៗទៀត ដើម្បីអនុវត្តសេចក្តីសម្រេចលេខ ១៣២៥។ ទាំងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន សុទ្ធតែមានផែនការសកម្មភាពជាតិ ដែលត្រូវបានព្រាងឡើងក្រោមកិច្ចសហការជាមួយសង្គមស៊ីវិល។ ប្រទេសផ្សេងទៀត ដូចជា កម្ពុជា ម៉ាឡេស៊ី និងវៀតណាម បានធ្វើបច្ចុប្បន្នភាពក្របខណ្ឌគោលនយោបាយជាតិ ដើម្បីគាំទ្រដល់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផងដែរ។

ក្រៅពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ មានក្របខណ្ឌថ្នាក់សកលផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ សេចក្តីប្រកាស និងវេទិកាសកម្មភាពនៅទីក្រុងប៉េកាំង (១៩៩៥) ជាគំនិតផ្តួចផ្តើមដំបូងគេ សម្រាប់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ សេចក្តីប្រកាស និងវេទិកានេះចែងពីការគាំទ្រដល់សសរស្តម្ភសំខាន់ៗទាំងអស់នៃរបៀបវារៈនេះ (ការចូលរួម ការការពារ ការទប់ស្កាត់ និងការសង្គ្រោះ និងស្តារឡើងវិញ) និងអំពាវនាវឱ្យមានសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីស្វែងយល់ពី "ផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ ឬជម្លោះផ្សេងទៀតលើស្ត្រី រួមទាំងស្ត្រីដែលកំពុងរស់នៅក្រោមការគ្រប់គ្រងដោយបរទេស" និងការទទួលស្គាល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ដោយលើកឡើងថាស្ត្រី "ជាកម្លាំងចលករសម្រាប់ការដោះស្រាយជម្លោះ និងការលើកកម្ពស់សន្តិភាពយូរអង្វែងនៅគ្រប់កម្រិត[23]"។ កក្នុងឆ្នាំ ២០១៣ អនុសាសន៍លេខ ៣០ (សិទ្ធិរបស់ស្ត្រីក្នុងការទប់ស្កាត់ជម្លោះ អំឡុងពេលមានជម្លោះ ការស្តារឡើងវិញក្រោយពេលជម្លោះ) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (អនុសញ្ញា CEDAW) ត្រូវបានអនុម័ត [24]។ អនុសាសន៍នេះគ្របដណ្តប់លើអាណត្តិរបស់ អនុសញ្ញានេះដើម្បីលើកឡើងពីស្ថានភាពរបស់ស្ត្រីនៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តជម្លោះ និងតម្រូវឱ្យរដ្ឋនានា ប្រមូលទិន្នន័យពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងរាយការណ៍ពីភាពអនុលោមរបស់រដ្ឋាភិបាលទៅតាមចំណុចដៅរបស់អង្គការសហប្រជាជាតិ។ អនុសាសន៍ទូទៅលេខ៣៧ នៃអនុសញ្ញា CEDAW ផ្តោតលើទិដ្ឋភាពដែលពាក់ព័ន្ធនឹងយេនឌ័រក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព កត់សម្គាល់ថា សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាចំណុចស្នូលនៃសន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈគោលដៅទី ៥ (សមភាពយេនឌ័រ) គោលដៅទី ១០ (ការកាត់បន្ថយវិសមភាព) និងគោលដៅទី ១៦ (សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ) នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ បញ្ហាយេនឌ័រក៏ត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅផ្សេងទៀតនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ"។

ក្រៅពីនេះ ក៏មានក្របខណ្ឌផ្សេងទៀតនៅកម្រិតអន្តរជាតិដូចជា សេចក្តីសម្រេចលេខ ២២៥០ (២០១៥) របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីយុវជន សន្តិភាព និងសន្តិសុខ ដើម្បីធានាថា សន្តិភាព និងសន្តិសុខបានបញ្ចូលយុវជន រួមទាំងស្ត្រីវ័យក្មេង។ លើសពីនេះ មានកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនឡើង ដើម្បីធានាថា ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខដែលពាក់ព័ន្ធ និងរួមបញ្ចូលស្ត្រីពិការ ស្ត្រីវ័យចំណាស់ និងស្ត្រីវ័យក្មេង ក៏ដូចជាស្ត្រីដែលមកពីក្រុមមានតំណាងតិចតួច និងក្រុមងាយរងគ្រោះដទៃទៀត។ ទោះជាយ៉ាងណាក្តី នៅមានការងារជាច្រើនទៀតចាំបាច់ត្រូវបំពេញ ដើម្បីគាំទ្រដល់បរិយាបន្ន ក៏ដូចជាគោលនយោបាយ និងការងារកម្មវិធីឱ្យមានប្រសិទ្ធភាពនៅក្នុងផ្នែកទាំងនេះ។ ទន្ទឹមនឹងនេះ ក៏មានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនឡើងលើភាពចាំបាច់នៃការចូលរួមរបស់បុរស រួមទាំងបុរសវ័យក្មេង ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការបង្កើនការយល់ដឹងពីរបៀបដែលពួកគេរងផលប៉ះពាល់ដោយសារបទដ្ឋានវិសមភាពយេនឌ័រ និងរបៀបដែលពួកគេអាចសហការគ្នាក្នុងការលើកកម្ពស់សមភាពយេនឌ័រផងដែរ។

22 សម្រាប់ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិ សូមចូលទៅកាន់ ៖ https://1325naps.peacewomen.org/.

23 សេចក្តីប្រកាស និងវេទិកាសកម្មភាពទីក្រុងប៉េកាំង (១៩៩៥)។ សូមមើល ឌ. កថាខណ្ឌ ១២, ២៣, ៤៤, ១០៦ ដែលលើកឡើងដោយផ្ទាល់ពីគោលដៅស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ កិច្ចប្រជុំពិសេស +៥ របស់មហាសន្និបាតនាទីក្រុងប៉េកាំង ក៏លើកឡើងជាថ្មីពីការប្តេជ្ញាចិត្តទាំងនេះផងដែរ ដូចគ្នានឹងសេចក្តីប្រកាសទីក្រុងវិនហុក និងផែនការសកម្មភាពណាមីបៀស្តីពីការបញ្ជ្រាបទស្សនៈយេនឌ័រក្នុងប្រតិបត្តិការសន្តិភាពពហុវិស័យ។ កិច្ចប្រជុំទាំង ២ នេះសុទ្ធតែបានធ្វើឡើងមុនការអនុម័តសេចក្តីសម្រេចលេខ ១៣២៥។ សម្រាប់ការពិភាក្សាបន្ថែមទៀត សូមចូលទៅកាន់ ៖ UN's IANWGE (Inter-Agency Network on Women and Gender Equality), "From the Charter to Security Council Resolution 1325," https://www.un.org/womenwatch/ianwge/taskforces/wps/history.html.

24 រដ្ឋសមាជិកអាស៊ានទាំង ១០ ប្រទេសបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដល់អនុសញ្ញា CEDAW ដែលជាក្របខណ្ឌគតិយុត្តិអន្តរជាតិដ៏សំខាន់សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។ អនុសាសន៍ទូទៅនេះអនុវត្តចំពោះស្ថានភាពក្នុងពេលមានជម្លោះ និងស្ថានភាពក្រោយពេលមានជម្លោះ ដើម្បីដោះស្រាយតម្រូវការ និងបញ្ហាប្រឈមជាក់លាក់របស់ស្ត្រីក្នុងបរិបទទាំងនេះ ដូចជា អំពើហិង្សា លទ្ធភាពទទួលបានសេវាសង្គមមូលដ្ឋាន ដូចជា សុខភាព (រួមទាំងសុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ) និងការអប់រំ។ អនុសញ្ញានេះផ្តល់ការណែនាំស្តីពីកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការយកចិត្តទុកដាក់ខ្ពស់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម/បទល្មើសប្រឆាំងស្ត្រីដោយតួអង្គមិនមែនរដ្ឋ។ ក្រៅពីនេះ អនុសញ្ញា CEDAW ចែងពីសេចក្តីណែនាំជាយុទ្ធសាស្ត្រសម្រាប់ការធ្វើសកម្មភាពដោយផ្អែកតាមការប្តេជ្ញាចិត្តទូលំទូលាយ ដូចមានរៀបរាប់ក្នុង UNSCR 1325 ហើយគណៈកម្មាធិការ CEDAW ស្នើឱ្យរដ្ឋភាគីរាយការណ៍ពីក្របខណ្ឌគតិយុត្តិ គោលនយោបាយ និងកម្មវិធីដែលពួកគេបានអនុវត្តដើម្បីធានាការការពារសិទ្ធិមនុស្សរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើមទប់ស្កាត់ជម្លោះ គំនិតផ្តួចផ្តើមក្នុងពេលមានជម្លោះ និងគំនិតផ្តួចផ្តើមក្រោយពេលមានជម្លោះ។

### ១.២.២ ក្របខណ្ឌថ្នាក់តំបន់

អាស៊ានប្តេជ្ញាសម្រេចឱ្យបាននូវសមភាពយេនឌ័រជាយូរមកហើយ ដូចការបញ្ជាក់ដោយសេចក្តីប្រកាសឆ្នាំ ១៩៨៨ ស្តីពីការលើកកម្ពស់ស្ត្រីក្នុងតំបន់អាស៊ាន និងសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងតំបន់អាស៊ាន (២០០៤)។ ឯកសារថ្នាក់តំបន់ផ្សេងៗទៀតបានចែងពីការប្តេជ្ញាចិត្តទូលំទូលាយក្នុងការសម្រេចឱ្យបាននូវសមភាពយេនឌ័រ ដូចជា សេចក្តីប្រកាសទីក្រុងហាណូយស្តីពីការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់ស្ត្រី និងកុមារអាស៊ាន (២០១០) និងសេចក្តីប្រកាសអាស៊ានស្តីពីការអនុវត្តចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (២០១៧)។

ការបោះជំហានដ៏សំខាន់មួយដែលពាក់ព័ន្ធនឹងការដាក់បញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ គឺនៅឆ្នាំ ២០១៧ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១។ សេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងតំបន់អាស៊ាន (JS) ត្រូវបានធ្វើឡើងក្រោមការដឹកនាំរបស់ គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ក្រោមការពិគ្រោះយោបល់ជាមួយ គណៈកម្មាធិការស្ត្រីអាស៊ាន (ACW) និងវិទ្យាស្ថានសន្តិភាព និងការសម្រុះសម្រួល អាស៊ាន (ASEAN-IPR)។

សេចក្តីថ្លែងការណ៍នោះបានរួមបញ្ចូលនូវការប្តេជ្ញាចិត្តសំខាន់ៗជាច្រើន ដូចជា ការអំពាវនាវដោយរដ្ឋជាសមាជិកអាស៊ានទាំង១០ប្រទេសឱ្យ "លើកកម្ពស់សមភាពយេនឌ័រ និងកាត់បន្ថយវិសមភាពរវាងបុរស និងស្ត្រីនៅក្នុងសង្គមរបស់យើង" និង "ប្តេជ្ញាជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខឱ្យបានទូលំទូលាយ"។ សេចក្តីថ្លែងការណ៍នោះក៏បានអំពាវនាវផងដែរឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ "ជំរុញការដាក់បញ្ចូលនូវទស្សនៈយេនឌ័រទៅក្នុងគំនិតផ្តួចផ្តើម និង យុទ្ធសាស្ត្រទប់ស្កាត់ជម្លោះទាំងអស់ និងធានាឱ្យមានការចូលរួមយ៉ាងពេញលេញរបស់ស្ត្រីក្នុងដំណើរការសន្តិភាព ដូចជា ការទប់ស្កាត់ជម្លោះ និងដំណើរការស្តាបនាឡើងវិញក្រោយពេលជម្លោះ និងដំណើរការស្តារឡើងវិញ[25]"។ ក្រៅពីនេះក៏មានការកត់សម្គាល់ពីភាពចាំបាច់ក្នុងការ "កសាងសមត្ថភាពរបស់ស្ត្រីឱ្យក្លាយជាអ្នកកសាងសន្តិភាព ក្នុងនាមជាអ្នកសម្រុះសម្រួល អ្នកចរចា និង/ឬអ្នកឆ្លើយតបបឋម នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន" និង "ទាញប្រយោជន៍ពីតួនាទីរបស់អង្គការអន្តររដ្ឋាភិបាលថ្នាក់តំបន់ និងដៃគូអភិវឌ្ឍន៍ក្នុងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ"។

ចាប់តាំងពីការអនុម័តសេចក្តីថ្លែងការណ៍រួម នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៧ វាបានក្លាយជាមូលដ្ឋានសម្រាប់គំនិតផ្តួចផ្តើមជាច្រើន ដូចជា កិច្ចសន្ទនាលើកទីមួយរវាងអាស៊ាន និងប្រទេសអូស្ត្រាលីស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានធ្វើឡើងក្នុងទីក្រុង Melbourne ប្រទេសអូស្ត្រាលី (២០១៨) សេចក្តី ថ្លែងការណ៍រួមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងវេទិកាតំបន់អាស៊ាន (ARF) (២០១៩) កិច្ចប្រជុំពិសេសរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងយុគសម័យឌីជីថល (២០២០) និងកិច្ចសន្ទនាថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (២០២០)។

ក្រៅពីនេះ មានកិច្ចខិតខំប្រឹងប្រែងបង្កើតស្ថាប័នថ្នាក់តំបន់ ដើម្បីជំរុញឱ្យមានការពិចារណាបន្ថែម និងការដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខ និងបង្កើនសមត្ថភាព ដូចជា ការដាក់បញ្ចូលរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងវិសាលភាពការងាររបស់ក្រុមការងារបច្ចេកទេសទទួលបន្ទុកកិច្ចការពារ យេនឌ័រ និងបរិយាបន្ន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយអាស៊ាន (ACDM) និងកិច្ចពិភាក្សាសម្របសម្រួលផ្ទៃក្នុង និងកិច្ចប្រជុំរវាងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ និងគណៈកម្មាធិការស្ត្រីអាស៊ាន។ ស្ថាប័នផ្សេងទៀតក្នុងតំបន់អាស៊ាន បានបង្កើតយន្តការផ្សេងៗដែលពាក់ព័ន្ធនឹងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) តាមរយៈក្រុមការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្ម និងការជួញដូរមនុស្ស និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន តាមរយៈក្រុមការងារជំនាញផ្នែកប្រតិបត្តិការរក្សា សន្តិភាព[26] ។ក្នុងកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី ១ ក្នុងឆ្នាំ ២០២០ ថ្នាក់ដឹកនាំអាស៊ានបានបញ្ជាក់ឡើងវិញពីភាពចាំបាច់នៃកិច្ចសហការអន្តរវិស័យ និងការគាំទ្រយ៉ាងទូលំទូលាយ និងការទាញប្រយោជន៍ពីយន្តការដែលដឹកនាំដោយអាស៊ាន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការ អនុវត្តការប្តេជ្ញាចិត្តថ្នាក់តំបន់ ក្នុងការពន្លឿនសមភាពយេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និង របៀប វារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ក្នុងឆ្នាំ ២០១៨ ដើម្បីគាំទ្រដល់ការអនុវត្តសេចក្តីថ្លែងការណ៍រួមឆ្នាំ ២០១៧ និងរំលេចមុខងារមួយក្នុងចំណោមមុខងារផ្សេងៗទៀតរបស់អាស៊ានក្នុងការកៀរគរអ្នកជំនាញ ដើម្បីគាំទ្រដល់រដ្ឋជា សមាជិកលើបញ្ហាដែលពាក់ព័ន្ធនឹងការទប់ស្កាត់ជម្លោះ ការដោះស្រាយជម្លោះ និងការផ្សះផ្សារ ក្រុមបណ្តាញស្ត្រីអាស៊ានស្តីពីសន្តិភាព (The ASEAN Women for Peace Registry) បានបង្កើតឡើងក្រោមវិទ្យាស្ថានសន្តិភាព និងការសម្រុះសម្រួលអាស៊ាន (ASEAN-IPR)។

---

25 Joint Statement on Promoting Women, Peace and Security in ASEAN, 2017.

26 សម្រាប់ព័ត៌មានបន្ថែមស្តីពីសសរស្តម្ភសហគមន៍អាស៊ាន ស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ានដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ សូមមើលផ្នែក ៣.៣ ក្នុងការសិក្សាក្នុងតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

សន្និសីទថ្នាក់តំបន់លើកទី ១ របស់អាស៊ានស្តីពីការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២២ ដល់ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ សន្និសីទថ្នាក់តំបន់នេះ ជាវេទិកាពហុភាគី និងពហុវិស័យដំបូងបង្អស់ដែលដឹកនាំដោយអាស៊ាន សម្រាប់កិច្ចពិភាក្សាជារួមលើការបកស្រាយរបស់អាស៊ានស្តីពីអត្ថន័យនៃស្ត្រី សន្តិភាព និងសន្តិសុខ វឌ្ឍនភាពលើផ្នែកសំខាន់ៗ ដូចជា ស្ត្រីក្នុងការកសាងសន្តិភាព ជម្រើសសេដ្ឋកិច្ច និងរបរចិញ្ចឹមជីវិតក្រោយជម្លោះ និងអនុសាសន៍សម្រាប់ការពន្លឿនស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។ អនុសាសន៍សំខាន់មួយដែលបានមកពីសន្និសីទនោះ គឺការសិក្សាថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីបង្កើនការយល់ដឹងពីការបកស្រាយអត្ថន័យស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅទូទាំងតំបន់អាស៊ាន រួមទាំងភាពពាក់ព័ន្ធ របស់របៀបវារៈនេះ ជាមួយសហគមន៍ទាំង ៣ របស់អាស៊ាន៖ សហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC)។ ទន្ទឹមនឹងមានសន្និសីទថ្នាក់តំបន់ អាស៊ានក្នុងឆ្នាំ ២០១៩ រដ្ឋមន្ត្រីការបរទេសនៃវេទិកាតំបន់អាស៊ាន (ARF) ដែលចូលរួមដោយរដ្ឋជាសមាជិកទាំង ១០ និងដៃគូសន្ទនារបស់អាស៊ាន បានអនុម័តសេចក្តី ថ្លែងការណ៍រួមស្តីពីការលើកកម្ពស់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងវេទិកានេះ រួមទាំងមានការប្តេជ្ញា "បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការសង្គមស៊ីវិល និងបណ្តាញរបស់ស្ត្រី" ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ សេចក្តីថ្លែងការណ៍រួមនៃវេទិកាតំបន់អាស៊ាន ត្រូវបានចាត់ទុកជាភស្តុតាងបញ្ជាក់ពីការដឹងឮជារួម និងស្មារតីសមូហភាពក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន និងដៃគូសន្ទនាចំពោះរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន[27]។

សន្និសីទថ្នាក់តំបន់នេះបាននាំទៅរកការបង្កើតក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលមានការចូលរួមដោយតំណាងមកពីគណៈកម្មាធិការស្ត្រីអាស៊ាន និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ។ ក្រុមប្រឹក្សានេះទទួលបានការគាំទ្រពីគម្រោងភាពជាដៃគូ ASEAN-USAID លើកកម្ពស់សហគមន៍នយោបាយ-សន្តិសុខ និងសហគមន៍សង្គម-វប្បធម៌ថ្នាក់តំបន់ (គម្រោង PROSPECT) និងអង្គការ UN Women ហើយមានតួនាទីត្រួតពិនិត្យការសិក្សានៅក្នុងតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ គម្រោង "រៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ" ត្រូវបាន អនុម័តដោយគណៈកម្មាធិការស្ត្រីអាស៊ាន ដែលជាស្ថាប័នអាស៊ានដឹកនាំការងារនេះ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២១។

តាមការគូសបញ្ជាក់ខាងលើ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា មាតិកាសំខាន់ៗ ភាសានិងការប្តេជ្ញាចិត្ត និងរចនាសម្ព័ន្ធស្ថាប័ន។ ក្របខណ្ឌទាំងនេះផ្តល់មូលដ្ឋានដ៏រឹងមាំសម្រាប់អាស៊ានក្នុងការប្រែក្លាយនូវការប្តេជ្ញា ពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់ ទៅជាសកម្មភាពពិតប្រាកដ។

ខាងក្រោមនេះជាក្របខណ្ឌសំខាន់ៗមួយចំនួននៅថ្នាក់តំបន់ ដែលត្រូវបានលើកឡើងថាមានភាពពាក់ព័ន្ធ ជាពិសេសក្នុងការជះឥទ្ធិពលលើផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (RPA WPS)៖

- ផែនការសកម្មភាពតំបន់អាស៊ានស្តីពីការបញ្ឈប់អំពើហិង្សាលើស្ត្រី (២០១៧)
- ក្របខណ្ឌយុទ្ធសាស្ត្រតំបន់អាស៊ានស្តីពីការបញ្ជ្រាបយេនឌ័រ (២០២១-២០២៥)
- ក្របខណ្ឌតំបន់អាស៊ានស្តីពីការការពារ យេនឌ័រ និងបរិយាបន្នក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ (២០២១-២០២៥)
- ចក្ខុវិស័យអាស៊ាន ឆ្នាំ ២០២៥ ៖ សហគមន៍នយោបាយ សហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គម-វប្បធម៌ (២០១៥)
- សេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន (២០១៧)
- ផែនការសកម្មភាពអាស៊ានដើម្បីទប់ស្កាត់ និងប្រឆាំងការកើនឡើងនៃការរើសអើសពូជសាសន៍ និងអំពើហិង្សាជ្រុលនិយម (២០១៩-២០២៥)
- ក្របខណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ជាពិសេសការអំពាវនាវឱ្យបញ្ជ្រាបយេនឌ័រទៅក្នុងការឆ្លើយតប និងការស្តារឡើងវិញពីវិបត្តិកូវីដ-១៩) (២០២០)
- ផែនទីបង្ហាញផ្លូវកិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែនអាស៊ាន (២០២១)
- ផែនសកម្មភាពអាស៊ាន-អង្គការសហប្រជាជាតិ (២០២១-២០២៥)
- អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (២០១៥)

---

27 ASEAN Regional Study on Women, Peace and Security, March 2021, p. 40.

## ១.៣ ស្ថានភាពនៃការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ៖ វឌ្ឍនភាព បញ្ហាប្រឈម ឱកាស និងអាទិភាពជាយុទ្ធសាស្ត្រ

### ១.៣.១ វឌ្ឍនភាព

តាំងពីឆ្នាំ ២០១៧ មក មានសន្ទុះគួរឱ្យកត់សម្គាល់ក្នុងតំបន់អាស៊ាន ពាក់ព័ន្ធនឹងការពន្លឿន វឌ្ឍនភាពឆ្ពោះទៅរកការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចមានបង្ហាញនៅក្នុងការសិក្សាថ្នាក់ តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានចេញផ្សាយក្នុងឆ្នាំ ២០២១។ វឌ្ឍនភាពទាំងនោះ រួមមានដូចជា ៖

- ការពង្រឹងការឯកភាព និងក្របខណ្ឌក្នុងតំបន់ស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ (ដូចជា សេចក្តីថ្លែងការណ៍រួមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន និងក្របខណ្ឌជារួមផ្សេងទៀតដែលបានលើកមកពិភាក្សាខាងលើ)។ សហគមន៍ទាំង៣ របស់អាស៊ាន (សហគមន៍នយោបាយ-សន្តិសុខ សហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គម-វប្បធម៌) សុទ្ធតែបានចូលរួមពន្លឿនយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ដូច្នេះវាបានផ្តល់មូលដ្ឋានសម្រាប់ការបង្កើនការបញ្ជ្រាបតាមស្ថាប័ន និងសមាហរណកម្មថ្នាក់តំបន់ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ការរួមចំណែកកាន់តែច្រើនឡើងពីសំណាក់កងទ័ព និងប៉ូលិសជាស្ត្រីដែលមកពីរដ្ឋជាសមាជិកអាស៊ាននៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- ការកើនឡើងនូវចំនួនស្ត្រីដែលបម្រើការក្នុងស្ថាប័នអនុវត្តច្បាប់[28]
- ការរៀបចំផែនការសកម្មភាពជាតិ និងក្របខណ្ឌគោលនយោបាយជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ក្នុងឆ្នាំ ២០១០ ប្រទេសហ្វីលីពីន ជាប្រទេសទីមួយនៅក្នុងតំបន់អាស៊ានដែលបានប្រកាសអនុវត្តផែនការសកម្មភាពជាតិ ចំណែកប្រទេសឥណ្ឌូនេស៊ីគឺជាប្រទេសទី ២ ដែលបានប្រកាសផែនការសកម្មភាពជាតិក្នុងឆ្នាំ ២០១៤។ ប្រទេសហ្វីលីពីនបានពិនិត្យឡើងវិញលើផែនការសកម្មភាពជាតិលើកទី ១ ហើយក្នុងឆ្នាំ ២០១៤ (ក្រោយការពិគ្រោះយោបល់ជាបន្តបន្ទាប់) ប្រទេសនេះបានបន្ថែមចំណុចសកម្មភាព និងសូចនាករសម្រាប់ផែនការសកម្មភាពជាតិលើកទី២។ ហ្វីលីពីនបានប្រកាសអនុវត្តជាផ្លូវការ នូវផែនការសកម្មភាពជាតិលើកទី២ (២០១៧-២០២២) ក្នុងឆ្នាំ២០១៧។ ហ្វីលីពីនជាប្រទេសទីមួយក្នុងតំបន់ដែលបានកែសម្រួលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅតាមបរិបទក្នុងប្រទេស ដូចជា នៅ Bangsamoro Autonomous Region in Muslim Mindanao (BARMM) តាមរយៈការបង្កើត និងអនុវត្តនូវផែនការសកម្មភាពថ្នាក់តំបន់ BARMM ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ប្រទេសឥណ្ឌូនេស៊ីខិតខំបញ្ជ្រាបរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់ជាតិ តាមរយៈសង្គម ឬ RAN P3AKS (២០១៤-២០១៩)[29]។ ក្នុងឆ្នាំ ២០២១ ឥណ្ឌូនេស៊ីបានអនុម័តផែនការសកម្មភាពជាតិលើកទី ២ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (២០២០-២០២៥) ក៏ដូចជាផែនការសកម្មភាពជាតិសម្រាប់ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើហិង្សាជ្រុលនិយមដែលនាំទៅរកអំពើភេរវកម្ម (RAN-PE) (២០២០-២០២៤)។
- គោលនយោបាយជាតិក្នុងរដ្ឋជាសមាជិកអាស៊ានជាច្រើន គាំទ្រដល់សសរស្តម្ភ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ប្រទេសថៃបានដាក់ចេញនូវវិធានការ និងគោលការណ៍ណែនាំស្តីពីស្ត្រី និងការលើកកម្ពស់សន្តិភាព និងសន្តិសុខ ដោយមានការគាំទ្រពីអង្គការ UN Women[30]។ ផែនការសកម្មភាពយេនឌ័រសម្រាប់ស្ថាប័នអនុវត្តច្បាប់ ត្រូវបានព្រាងក្នុងប្រទេសកម្ពុជា។ ផែនការសកម្មភាពនេះពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត។ ប្រទេសមីយ៉ាន់ម៉ាបានអនុម័តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការលើកកម្ពស់ស្ត្រី (២០១៣-២០២២)។ ច្បាប់ស្តីពីសមភាពយេនឌ័រ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៦ នៅប្រទេសវៀតណាម ធានាសិទ្ធិស្មើភាពរបស់ស្ត្រី និងអំពាវនាវឱ្យមានយុទ្ធសាស្ត្រយេនឌ័រ សម្រាប់ក្រសួងនីមួយៗ។ ក្រៅពីនេះវៀតណាមបានអនុម័ត យុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រក្នុងឆ្នាំ ២០១០ (២០១១-២០២០) និងក្នុងឆ្នាំ ២០២១ (២០២១-២០៣០)។
- ការកើនឡើងនៃការបញ្ជ្រាបយេនឌ័រដោយរដ្ឋជាសមាជិកអាស៊ាន ទៅក្នុងបញ្ហាសន្តិសុខ និង បទពិសោធន៍គ្រប់ជ្រុងជ្រោយតាមរយៈការដាក់បញ្ចូលចក្ខុវិស័យបរិយាបន្នយេនឌ័រទៅក្នុងបញ្ហាសន្តិសុខថ្មីៗនៅថ្នាក់តំបន់ ដូចជា ការជួញដូរមនុស្ស

28 See, UNODC, UN Women, InterPol, Women in Law Enforcement in the ASEAN Region, available at https://asiapacific.unwomen.org/en/digital-library/publications/2020/08/women-in-law-enforcement-in-the-asean- region.

29 Ministry of Foreign Affairs of the Republic of Indonesia, "Twenty Years of Women, Peace and Security Agenda: Indonesian Women Continue to Contribute to World Peace," 23 October 2020.

30 ព័ត៌មានបន្ថែមសម្រាប់គោលនយោបាយជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការស្ទង់មតិពេញលេញស្តីពីសមិទ្ធផល និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន សូមអាន ៖ ASEAN Regional Study on WPS។

ការគ្រប់គ្រង និងឆ្លើយតបនឹងគ្រោះ មហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពបន្ទាន់ផ្នែកសុខភាពសាធារណៈ។

ដូចការពិភាក្សាលម្អិតក្នុងការសិក្សាថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខណៈដែលរដ្ឋជាសមាជិកចូលរួមគ្រប់ផ្នែកទាំងអស់នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រដ្ឋជាសមាជិកជាច្រើនបានផ្តោតសំខាន់លើផ្នែកផ្សេងៗ។ រដ្ឋជាសមាជិកមួយចំនួន ដូចជាឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន ផ្តោតសំខាន់លើតួនាទីរបស់ស្ត្រីក្នុងការទប់ស្កាត់ជម្លោះ រួមមានការទប់ស្កាត់ និងការប្រឆាំងអំពើហិង្សាជ្រុលនិយម។ ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម បង្កើនការចូលរួមរបស់ស្ត្រីក្នុងការរក្សាសន្តិភាព ខណៈដែលប្រទេសហ្វីលីពីន ផ្តោតសំខាន់លើតួនាទីស្នូលរបស់ស្ត្រីក្នុងដំណើរការកសាងសន្តិភាព។

## ១.៣.២ បញ្ហាប្រឈម ឱកាស និងអន្តរាគមន៍ជាយុទ្ធសាស្ត្រ

របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គួរផ្តល់មូលដ្ឋានព័ត៌មានដល់ការឆ្លើយតបនឹងការព្រួយបារម្ភផ្នែកសន្តិសុខទាំងអស់ក្នុងតំបន់អាស៊ាន។ ក្នុងបរិបទនៃវិបត្តិកូវីដ-១៩ អាស៊ានគួរទាញប្រយោជន៍ពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីទប់ស្កាត់ជម្លោះ និងអសន្តិសុខប្រកបដោយប្រសិទ្ធភាព និងធានាឱ្យមានការចូលរួមរបស់ស្ត្រី និងបំពេញតម្រូវការរបស់ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។ ការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើន លើការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏អាចជួយដោះស្រាយអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រក្នុងបរិបទនៃជម្លោះ និងវិបត្តិ និងបញ្ជ្រាបយេនឌ័រទៅក្នុងការទប់ស្កាត់ជម្លោះ និងវិបត្តិបានផងដែរ[31]។

នៅមានយុទ្ធសាស្ត្រទូលំទូលាយ និងវិធីជាច្រើនទៀត សម្រាប់ការសម្រេចបានរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ដែលស៊ីសង្វាក់គ្នានឹងបញ្ហាប្រឈមក្នុងសតវត្សទី ២១ ៖

- ធានាការចូលរួមរបស់ស្ត្រីក្នុងការត្រៀមខ្លួន និងការឆ្លើយតបនឹងបញ្ហា និងការព្រួយបារម្ភផ្នែកសន្តិសុខទូទៅ ក៏ដូចជាបញ្ហា និងការព្រួយបារម្ភផ្នែកសន្តិសុខដែលកំពុងលេចឡើង ដូចជា ការស្តារឡើងវិញពីវិបត្តិកូវីដ-១៩ ការគំរាមកំហែងលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងការរៀបចំផែនការបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ។
- លើកកម្ពស់អភិក្រមទូទាំងសង្គមសម្រាប់កំណែទម្រង់អភិបាលកិច្ច និងការតាក់តែងគោលនយោបាយស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ និងការយល់ដឹងទូលំទូលាយពីអត្ថប្រយោជន៍នៃអភិបាលកិច្ចបែបបរិយាបន្នសម្រាប់ការធានាសន្តិសុខ និងសន្តិភាព។
- បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងការបង្កើតឱ្យមានសន្តិភាព ការរក្សាសន្តិភាព និងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព ដោយធានាថា ស្ត្រីចូលរួមយ៉ាងពេញលេញក្នុងនាមជាដៃគូស្មើភាពតាំងពីដំណាក់កាលដំបូងក្នុងដំណើរការសន្តិភាព និងដំណើរការនយោបាយនីមួយៗដែលគាំទ្រដោយអង្គការសហប្រជាជាតិ។
- ធានាថា កិច្ចខិតខំប្រឹងប្រែងអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បានបំពេញតម្រូវការរបស់ស្ត្រី និងបុរសគ្រប់រូប រួមទាំងអ្នកដែលងាយប្រឈមនឹងការផាត់ចេញ ឬភាពងាយ រងគ្រោះកាន់តែខ្លាំងដោយសារអាយុ ពូជសាសន៍ ប្រាក់ចំណូល យេនឌ័រ វណ្ណៈ សាសនា ជាតិពន្ធុ ឬដើមកំណើតសង្គម ការបាត់បង់ទីលំនៅ ស្ថានភាពអាពាហ៍ពិពាហ៍ ពិការភាព ឬកត្តាផ្សេងទៀត។
- បង្កើនការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងបរិបទមនុស្សធម៌-ការអភិវឌ្ឍ-សន្តិភាព ដើម្បីលើកឡើងពីកត្តាដែលអាចបង្កឱ្យមានជម្លោះ និងការត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយតាមរយៈយុទ្ធសាស្ត្រ និងអភិក្រមដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

## ខាងក្រោមនេះជាអន្តរាគមន៍មួយចំនួន ៖

ទីមួយ ការប្រែក្លាយការប្តេជ្ញាចិត្តទៅជាការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់តំបន់ និងថ្នាក់ប្រទេស ជាគន្លឹះក្នុងការសម្រេចបាននូវការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងដំណើរការសន្តិភាព និងសន្តិសុខ និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ តាមរយៈគំនិតផ្តួចផ្តើមដែលទទួលបានជោគជ័យនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ រដ្ឋជាសមាជិកអាស៊ានអាចយកលំនាំតាមការអនុវត្តល្អ និង មេរៀនក្នុងតំបន់ ដើម្បីលើកកម្ពស់ការកែសម្រួលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ សម្រាប់ការ អនុវត្តក្នុងប្រទេសរបស់ខ្លួន នៅពេលឆ្លើយតបនឹងបញ្ហាប្រឈមពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ[32]។

ទីពីរ ការបង្កើនសមត្ថភាពស្ថាប័នសម្រាប់ការវិភាគស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការឆ្លើយតបនៅថ្នាក់តំបន់ និងថ្នាក់ប្រទេស រួម

31 "Findings," ASEC's Presentation on WPS Initiatives in ASEAN.

32 "Findings," ASEAN Regional Study on WPS, p. 2.

ទាំងការបង្កើនកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីឱ្យកិច្ចខិតខំប្រឹងប្រែងក្នុងប្រទេសផ្តល់មូលដ្ឋានព័ត៌មានដល់អតិក្រមថ្នាក់តំបន់ ជាកត្តាសំខាន់សម្រាប់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ សេចក្តីថ្លែងការណ៍រួម បានអំពាវនាវឱ្យ "ស្ថាប័នពាក់ព័ន្ធរបស់អាស៊ានសហការគ្នាលើកកម្ពស់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន"។ កិច្ចសហការថ្នាក់តំបន់អាចជួយឱ្យមានវឌ្ឍនភាពលើគោលដៅសំខាន់ៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាកត់សម្គាល់សមត្ថភាព និងផលប្រយោជន៍នៅថ្នាក់ជាតិ។

ទីបី វត្តមានយ៉ាងច្រើននៃអង្គការសង្គមស៊ីវិលក្នុងតំបន់អាស៊ាន និងភាពចម្រុះនៃឱកាសអំណោយផលសម្រាប់ការចូលរួមយ៉ាងសកម្ម និងបរិយាបន្នរបស់អង្គការទាំងនេះ ជាឱកាសផង និងជាបញ្ហាប្រឈមផង សម្រាប់ការរៀបចំ និងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ការជំរុញការចូលរួម និងកិច្ចសន្ទនាបែបស្ថាបនាជាមួយសង្គមស៊ីវិល មានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ការសិក្សាក្នុងតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ លើកឡើងថា "ភាពជាដៃគូរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ជាចំណុចស្នូលនៃភាពជោគជ័យសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋជាសមាជិកអាស៊ានក្នុងការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ និងជាគំរូវិជ្ជមានមួយសម្រាប់អាស៊ាន តាមរយៈសន្និសីទសង្គមស៊ីវិលអាស៊ាន និងវេទិកា ប្រជាជនអាស៊ាន។ ការកៀរគររដ្ឋាភិបាល វិស័យសន្តិសុខ អ្នកជំនាញផ្នែកសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល ឱ្យផ្តោតការយកចិត្តទុកដាក់លើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន អាចបង្កើនភាពជាដៃគូ និងអភិបាលកិច្ចពហុភាគី ដើម្បីធានាភាពជោគជ័យនៃគោលនយោបាយ[33]"។

ទីបួន ការបង្កើតឱកាសកាន់តែធំទូលាយសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិភាព និងសន្តិសុខរួមទាំងការចូលរួមក្នុងសន្តិសុខ និងការការពារប្រទេស មានសារៈសំខាន់ណាស់សម្រាប់ការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាពិសេសក្នុងករណីដែលចំនួនស្ត្រីនៅមានកម្រិតទាប។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនក្នុងការបង្កើនការចូលរួមរបស់ស្ត្រី ជាពិសេសក្នុងឋានន្តរស័ក្តិខ្ពស់ៗ និងក្នុងមុខតំណែងដឹកនាំ[34]។ការចូលរួមរបស់ស្ត្រីយុវវ័យក្នុងវិបត្តិសន្តិសុខដែលកំពុងលេចឡើង ដូចជា ការប្រែប្រួលអាកាសធាតុ និងវិស័យឌីជីថលក៏ចាំបាច់ផងដែរសម្រាប់ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខដោយជោគជ័យ។

ទីប្រាំ ការវិភាគកន្លងមក (ទាំងក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅជុំវិញពិភពលោក) ស្តីពីបញ្ហាប្រឈមក្នុងការសម្រេចវឌ្ឍនភាពជាក់លាក់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ លើកឡើងថា ចាំបាច់ត្រូវបង្កើនការដឹកនាំ ការយល់ដឹង និងការចូលរួមរបស់បុរសក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ "ការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ឬគំនិតផ្តួចផ្តើមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផ្សេងទៀតដែលដឹកនាំដោយអាស៊ាន អាចត្រួសត្រាយផ្លូវ សម្រាប់ការជំរុញការចូលរួមរបស់បុរសក្នុងនាមជាជើងឯកនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[35]។ "ការអភិវឌ្ឍជើងឯក និងតស៊ូមតិក្នុងចំណោមអ្នកដឹកនាំជាបុរសត្រូវតែជាអាទិភាពចម្បងសម្រាប់ផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងអ្នកគាំទ្រលើផែនការសកម្មភាពនេះ[36]"។ អ្នកវិភាគលើកឡើងថា នៅជុំវិញពិភពលោក នៅតែមានការយល់ខុសពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ និងចាត់ទុកថាវាជា "បញ្ហារបស់ស្ត្រី" និងជាបញ្ហាដែលត្រូវដោះស្រាយដោយស្ត្រី។ ដូច្នេះចាំបាច់ត្រូវបង្កើនសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលនៅគ្រប់កម្រិតឱ្យបានយល់ថាតើស្ត្រី សន្តិភាព និងសន្តិសុខ មានសារៈសំខាន់ដូចម្តេចសម្រាប់អភិបាលកិច្ចដែលមានប្រសិទ្ធភាព និងសន្តិភាពដែលមាននិរន្តរភាព។

ទីប្រាំមួយ ស្ត្រីនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវា និងឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ប៉ុន្តែស្ត្រីមិនត្រូវបានជំរុញឱ្យចូលរួម ឬពិគ្រោះយោបល់ក្នុងគោលនយោបាយ និងការរៀបចំផែនការពាក់ព័ន្ធនឹងការទប់ស្កាត់ ការឆ្លើយតប ឬការស្តារឡើងវិញ ឬត្រូវបានជ្រើសរើសឱ្យបំពេញតួនាទីដឹកនាំឡើយ។ កិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងស្តារឡើងវិញ ចាប់ពីជំងឺរាតត្បាតរហូតដល់ការគ្រប់គ្រង និងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងវិបត្តិ គួរពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់តំបន់[37]។

## ១.៤ សនិទានភាពសម្រាប់ផែនការសកម្មភាពតំបន់អាស៊ាន

អាស៊ានប្តេជ្ញាសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប។ ផែនការសកម្មភាព

---

33 "Findings," ASEAN Regional Study on WPS, p. 2.

34 "Findings," ASEC's Presentation on WPS Initiatives in ASEAN.

35 ASEAN Regional Study on Women, Peace and Security, March 2021, p. 41.

36 Ibid.

37 ASEAN Regional Study on Women, Peace and Security, March 2021, p. 41 and ASEC's Presentation on WPS Initiatives in ASEAN.

តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានបង្កើតឡើងដើម្បីទាញប្រយោជន៍ពីឆន្ទៈនយោបាយដ៏ខ្លាំងក្លានេះ ក៏ដូចជាភាពជោគជ័យកន្លងមក (ទាំងក្នុងតំបន់ និងក្នុងរដ្ឋជាសមាជិកអាស៊ាន) ដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ដើម្បីបង្កើនវឌ្ឍនភាពនៃការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងសម្រេចឱ្យបានលទ្ធផល។ ផែនការសកម្មភាពនេះឆ្លុះបញ្ចាំងពីចក្ខុវិស័យរបស់អាស៊ានក្នុងការប្តេជ្ញាឆ្ពោះទៅជាសហគមន៍បរិយាបន្នដែលលើកកម្ពស់គុណភាពជីវិត ផ្តល់លទ្ធភាពប្រកបដោយសមធម៌ដល់ប្រជាជនទាំងអស់ក្នុងការទទួលបានឱកាស និងគាំទ្រដល់ការការពារសិទ្ធិមនុស្ស។ កិច្ចសន្ទនាថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីការពង្រឹងតួនាទីរបស់ស្ត្រីដើម្បីសន្តិភាព និងសន្តិសុខប្រកបដោយនិរន្តរភាព ដែលបានធ្វើឡើងក្នុងខែ កញ្ញា ឆ្នាំ ២០២០ បញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការធានាសមាហរណកម្មស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងគោលនយោបាយ និងក្របខណ្ឌតំបន់ទូទាំងសហគមន៍ទាំង ៣ របស់អាស៊ាន ៖ សហគមន៍នយោបាយ-សន្តិសុខ សហគមន៍សេដ្ឋកិច្ច និង សហគមន៍សង្គម-វប្បធម៌។
ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានគោលបំណង[38]៖

- លើកកម្ពស់ការបញ្ជ្រាបយេនឌ័រក្នុងការកសាងសន្តិភាព ដំណើរការសន្តិភាព ការទប់ស្កាត់ និងការដោះស្រាយជម្លោះ និងការស្តារឡើងវិញ ដោយអនុលោមតាមការអនុវត្តសេចក្តីថ្លែងការណ៍រួម និងធានាថា ស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានដាក់បញ្ចូលក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីក្នុងតំបន់អាស៊ាន។
- ផ្តល់ក្របខណ្ឌបែបនិយាមនៅថ្នាក់តំបន់ដើម្បីកំណត់អាទិភាព និងសកម្មភាពជាយុទ្ធសាស្ត្រ ក្នុងគោលបំណងបង្កើនកម្លាំងផ្សារភ្ជាប់រវាងកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងកិច្ចខិតខំប្រឹងប្រែងថ្នាក់ប្រទេស ដើម្បីពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។
- ផ្តល់អភិក្រមចម្រុះ និងសមស្របសម្រាប់បញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខដែលកំពុងលេចឡើងថ្មី ដូចជា យន្តការសម្របសម្រួលការអនុវត្តដែលលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងទូទាំងសសរស្តម្ភអាស៊ាន។
- គាំទ្រដល់រដ្ឋជាសមាជិកអាស៊ានក្នុងការកែសម្រួលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខសម្រាប់ការអនុវត្តក្នុងប្រទេសនីមួយៗ[39] និងការកំណត់អាទិភាពពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពជាតិ និងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធនៅថ្នាក់ប្រទេស។
- លើកកម្ពស់កិច្ចសហការក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន ពង្រឹងការរៀនសូត្រ ការផ្លាស់ប្តូរចំណេះដឹង និងការកសាងសមត្ថភាពនៅថ្នាក់តំបន់ តាមរយៈស្ថាប័នតាមវិស័យរបស់អាស៊ាន ដែលខិតខំពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជាស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ វិទ្យាស្ថានសិក្សាស្រាវជ្រាវជាដើម។
- កសាងការយល់ដឹងដើម្បីបង្កើនភាពម្ចាស់ការលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងចំណោមអ្នកតាក់តែងគោលនយោបាយ ក្រសួង និងសង្គមស៊ីវិល តាមរយៈការបង្កើនសមត្ថភាពក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីដោះស្រាយបញ្ហាសន្តិសុខថ្មីៗ ដូចជា ជំងឺរាតត្បាត សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងអាកាសធាតុ មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងការបាត់បង់ទីលំនៅ ។ល។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងក្លាយជាក្របខណ្ឌគោលនយោបាយទូលំទូលាយ សម្រាប់ជាត្រីវិស័យ និងជាកម្លាំងចលករជំរុញការប្តេជ្ញាចិត្តនៅថ្នាក់តំបន់ ផ្តល់ជាជម្រើស និងការអនុវត្តជាច្រើននៅថ្នាក់ជាតិ ការគាំទ្រពីតួអង្គក្នុងតំបន់ និងអន្តរជាតិ ដូចជា អង្គការ សហប្រជាជាតិ និងដៃគូសន្ទនា។ ផែនការសកម្មភាពនេះផ្អែកលើការគាំទ្រយ៉ាងច្រើនពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ដូចមានឆ្លុះបញ្ចាំងក្នុងសេចក្តីថ្លែងការណ៍រួមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និង ឯកសារថ្នាក់តំបន់ផ្សេងទៀត ក៏ដូចជាធានាវឌ្ឍនភាពជាក់លាក់ និងអាចវាស់វែងបានសម្រាប់សសរស្តម្ភទាំងបួនដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។

## ១.៥ ដំណើរការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

ការពិចារណាដ៏សំខាន់មួយក្នុងការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺការធានានូវភាពពាក់ព័ន្ធនឹងសហគមន៍ទាំង ៣ របស់អាស៊ាន និងធានាថា សសរស្តម្ភទាំងនេះមានភាពម្ចាស់ការលើខ្លឹមសារ និងការប្តេជ្ញាចិត្តក្នុងផែនការសកម្មភាពនោះ។ ដំណើរការនេះចូលរួមដោយស្ថាប័នតាមវិស័យចម្រុះរបស់អាស៊ាន ដែលត្រួតពិនិត្យលើកិច្ចសហប្រតិបត្តិការថ្នាក់

---

38 Joint Presentation on Development of RPA WPS in ASEAN-FINAL, 28 January 2022.

39 ការចុះបញ្ជីស្ត្រីអាស៊ានដើម្បីសន្តិភាព ជាធនធានសម្រាប់ការទាញប្រយោជន៍ពីជំនាញរបស់ស្ត្រីដែលធ្វើការងារពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ដើម្បីលើកកម្ពស់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខដោយផ្អែកតាមបរិបទមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

តំបន់លើសមភាព យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ការការពារ ឧក្រិដ្ឋកម្មឆ្លងដែន សិទ្ធិមនុស្ស ការគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌។

ដែលសំខាន់ផងដែរនោះគឺការទទួលបានជាតុចូល និងការសម្របសម្រួលកិច្ចពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងអង្គការស្ត្រី ក៏ដូចជាការធ្វើយ៉ាងណាឱ្យបន្សីគ្នានឹងអាទិភាពជាតិ។ ជុំវិញការអនុវត្តផែនការសកម្មភាពនេះ យន្តការសម្របសម្រួលនឹងមានការបង្កើតជាសូចនាករ និងការប្រមូលទិន្នន័យសម្រាប់ការពិនិត្យតាមដាន និងការរាយការណ៍ពីវឌ្ឍនភាពបន្ថែមទៀត ក្រោមការគាំទ្ររបស់អង្គការ UN Women ដល់អាស៊ានលើទិន្នន័យ និងស្ថិតិស្តីពីយេនឌ័រ។

ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ មាន តួនាទីត្រួតពិនិត្យការរៀបចំផែនការសកម្មភាពតំបន់អាស៊ាន និងដឹកនាំទិសដៅយុទ្ធសាស្ត្រនៃផែនការសកម្មភាពនេះ។ ក្រុមប្រឹក្សានេះរួមមានតំណាងមកពីគណៈកម្មាធិការស្ត្រីអាស៊ាន និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ។ ក្រោយមក ក្រុមប្រឹក្សានេះរួមបញ្ចូលនូវស្ថាប័នតាម វិស័យចំនួន ១១ បន្ថែមទៀតដែលស្ថិតក្នុងសហគមន៍ទាំង ៣ របស់អាស៊ាន ដើម្បីជួយតម្រង់ទិសនៃការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានជាអាទិ៍ កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រី បណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN) វិទ្យាស្ថានសន្តិភាព និងការសម្រុះសម្រួលអាស៊ាន (ASEAN-IPR) ក្រុមការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្ម (WG-CT) នៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) និងក្រុមការងារទទួលបន្ទុកកិច្ចការពារ យេនឌ័រ និងបរិយាបន្ន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយអាស៊ាន (ACDM)។ កម្ពុជាដែលបានធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ ២០២២ ក៏បានធ្វើជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផងដែរ និងជាប្រទេសឈានមុខគេមួយលើការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ គម្រោង "រៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ឬ ASEAN RPA on WPS" ត្រូវបានអនុម័តដោយគណៈកម្មាធិការ អាស៊ានស្តីពីស្ត្រី ដែលជាស្ថាប័នអាស៊ានដឹកនាំការងារនេះ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២១។

ការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ផ្អែកតាមការប្រជុំពិភាក្សាផ្នែកបច្ចេកទេស និងកិច្ចប្រជុំប្រមូលគំនិត។ កិច្ចប្រជុំពិភាក្សា និងកិច្ចប្រជុំប្រមូលគំនិតទាំងនេះបានប្រមូលជាតុចូល និងជំរុញឱ្យមានការពិភាក្សាក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន អង្គការសហប្រជាជាតិ និងដៃគូសន្ទនា តំណាងមកពីសង្គមស៊ីវិល ក្រុមស្ត្រី និងក្រុមយុវជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ និងវិទ្យាស្ថានស្រាវជ្រាវក្នុងតំបន់អាស៊ាន។ ដំណើរការ និងខ្លឹមសារដ៏សំខាន់នេះ ក៏ផ្អែកតាមមេរៀនដែលត្រូវបានចែករំលែកពីតំបន់ផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តយន្តការស្ត្រី សន្តិភាព និង សន្តិសុខផងដែរ។

## ១.៦ យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ

តារាងខាងក្រោមដែលបង្ហាញពីសកម្មភាពអាទិភាពសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ចែកជា ៤ តារាងផ្សេងគ្នាដោយតារាងនីមួយៗគ្របដណ្តប់លើសសរស្តម្ភសំខាន់ៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ ការការពារ ការចូលរួម ការទប់ស្កាត់ និងការសង្គ្រោះ និងស្តារឡើងវិញ។

លទ្ធផលចុងក្រោយមួយ[40] ត្រូវបានបញ្ជាក់សម្រាប់សសរស្តម្ភនីមួយៗ លើកលែងតែការទប់ស្កាត់ ដែលមានលទ្ធផលចុងក្រោយ ២ ៖ លទ្ធផលចុងក្រោយទី១ ផ្តោតលើការដាក់បញ្ចូលស្ត្រីយ៉ាងពេញលេញទៅក្នុងគំនិតផ្តួចផ្តើមទប់ស្កាត់ការគំរាមកំហែងលើសន្តិភាព និងសន្តិសុខ (ដូចជាកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ ជម្លោះ) ហើយលទ្ធផលចុងក្រោយទី២ ផ្តោតសំខាន់លើការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ។

លទ្ធផលរំពឹងទុកសំដៅលើលទ្ធផលសម្រេចបានដែលមានលក្ខណៈរូបីយ៍ និងអាចវាស់វែងបានដែលមិនហួសពីសមត្ថភាពរបស់ទីភ្នាក់ងារអនុវត្ត។ សកម្មភាពអាទិភាពដែលបានកំណត់ក្នុងតារាងនីមួយៗ ជាគំនិតផ្តួចផ្តើមជាក់លាក់ដែលត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលរំពឹងទុកជាក់លាក់។ ក្របខណ្ឌនេះគឺសមហេតុផល និងផ្អែកលើលទ្ធផល៖ សកម្មភាពនានាដែលខិតខំសម្រេចឱ្យបានលទ្ធផលរំពឹងទុក ដែលមានគោលដៅបង្កើតជាលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលចុងក្រោយបញ្ជាក់ពីអ្វីដែលត្រូវវាស់វែងដើម្បីតាមដានវឌ្ឍនភាពនៃការសម្រេចបានលទ្ធផលចុងក្រោយនេះ។

40 ផ្នែកទី ២ នៃឯកសារនេះកំណត់និយមន័យពាក្យ ដូចជា "លទ្ធផលចុងក្រោយ" និង "លទ្ធផលរំពឹងទុក" ដែលគេប្រើប្រាស់ក្នុងតារាងសកម្មភាពអាទិភាពដែលត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាពតំបន់អាស៊ាន និងពិភាក្សាផងដែរពីជំហានបន្ទាប់សម្រាប់ការគូសបញ្ជាក់ពីផែនការពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ។

## តារាងស្តីពីការការពារ

លទ្ធផលយុទ្ធសាស្ត្រទី ១ ៖ ការការពារសិទ្ធិរបស់ស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងស្ត្រី និងក្មេងស្រីដែលមកពីក្រុមជួបការលំបាក ក្នុងគោលនយោបាយ ការអនុវត្ត និងស្ថាប័នដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដូចជា ការការពារស្ត្រី និងក្មេងស្រីពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹង យេនឌ័រ ក្នុងពេលមានជម្លោះ ក្រោយពេលជម្លោះ ក្នុងការកសាងសន្តិភាព និងស្ថានភាពមនុស្សធម៌[41]

សូចនាករលទ្ធផលចុងក្រោយ ៖

- ចំណាយសរុប និងសមាមាត្រ[42] នៃគម្រោង និងគំនិតផ្តួចផ្តើមដែលទទួលបានមូលនិធិដើម្បី គាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទពាក់ព័ន្ធនឹងយេនឌ័រ ក្នុងពេលមានជម្លោះ ក្រោយពេលមានជម្លោះ ក្នុងការកសាងសន្តិភាព និងក្នុងស្ថានភាពមនុស្សធម៌ ដូចជា ព័ត៌មានសមស្របស្តីពីសុខភាព ការគាំទ្រផ្នែកចិត្តសង្គម ចន្លោះសុវត្ថិភាព ការថែទាំសុខភាព និងសេវាសំខាន់ៗ។
- ចំនួនរដ្ឋជាសមាជិកអាស៊ានដែលមានក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌកម្មវិធី ដូចជា ផែនការសកម្មភាពជាតិ និងការគាំទ្រផ្នែកថវិកា ដើម្បីដាក់បញ្ចូលការការពារសិទ្ធិស្ត្រី និងក្មេងស្រីទៅក្នុងគំនិតផ្តួចផ្តើមសន្តិភាព និងសន្តិសុខ។
- ចំនួនរដ្ឋជាសមាជិកអាស៊ានដែលមានយន្តការសម្របសម្រួលឆ្លើយតបនឹងយេនឌ័រ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដែលទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ ពាក់ព័ន្ធនឹងយេនឌ័រ ការកាត់បន្ថយបញ្ហាប្រឈម និងភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រីក្នុងអំឡុងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ និងស្ថានភាពមានជម្លោះ។
- ចំនួនយន្តការដែលមានស្រាប់ សម្រាប់ការពិនិត្យតាមដាន ទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី ក្នុងគោលនយោបាយ ក៏ដូចជាស្ត្រីដែលបម្រើការក្នុងកងកម្លាំងប្រដាប់អាវុធ និងប៉ូលិស (រួមទាំងអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត) និងតាមដានរបាយការណ៍ស្តីពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដែលពាក់ព័ន្ធនឹងកងកម្លាំងប្រដាប់អាវុធ ប៉ូលិស និងបុគ្គលិកផ្សេងទៀតដែលបម្រើការក្នុងវិស័យសន្តិភាព និងសន្តិសុខ។

លទ្ធផលរំពឹងទុក ១.១ ៖ រដ្ឋជាសមាជិកអាស៊ានបង្កើនសមត្ថភាពក្នុងការបង្កើត និងអនុវត្តបទបញ្ញត្តិ គោលនយោបាយ និងវិធានការដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងបំពេញតម្រូវការរបស់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដូចជាក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសារជម្លោះ ស្ថានភាពសង្គ្រោះបន្ទាន់ និងស្ថានភាពមនុស្សធម៌។

សកម្មភាពអាទិភាព ១.១.១ ៖ ធានាការទទួលខុសត្រូវចំពោះជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រដែលបានកើតឡើងក្នុងអំឡុងពេល និងក្រោយពេលមានជម្លោះ គ្រោះ មហន្តរាយ និងស្ថានភាពអស្ថិរភាព តាមរយៈដំណើរការផ្លូវច្បាប់ និងដំណើរការតុលាការ និងយន្តការយុត្តិធម៌អន្តរកាល[43] ដោយមានការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីក្នុងដំណើរការទាំងនេះ និងធានាថា ជនរងគ្រោះអាចទទួលបានដំណោះស្រាយ សំណងជំងឺចិត្ត និងសំណងផ្សេងទៀត (នៅថ្នាក់ជាតិ)[44]។

Continued

41 ការដោះស្រាយអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានលើកឡើងក្នុងខ្លឹមសារនៃសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន (២០១៧) ក៏ដូចជាសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅវេទិកាតំបន់អាស៊ាន (២០១៩)។ មានការលើកឡើងពី "ក្រុមងាយរងគ្រោះ" ព្រោះគោលដៅរួមមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺការបង្កើតឱ្យមានគោលនយោបាយ និងគំនិតផ្តួចផ្តើមស្តីពីសន្តិភាព និងសន្តិសុខដើម្បីកត់សម្គាល់ទាំងភេទ (ស្រី/ប្រុស) និងកត្តាផ្សេងទៀតដែលបង្កផលប៉ះពាល់លើបទពិសោធន៍របស់បុគ្គលដែលចូលរួមក្នុងដំណើរការ និងស្ថាប័នសន្តិភាព និងសន្តិសុខ និងគួរត្រូវបានពិចារណានៅពេលរៀបចំ និងអនុវត្តការឆ្លើយតបនឹងបញ្ហាសន្តិសុខ។ អភិក្រមប្រសព្វគ្នាសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខ ទទួលស្គាល់ថា ស្ត្រី និងបុរសអាចមានបទពិសោធន៍ តម្រូវការ និងការព្រួយបារម្ភខុសគ្នាពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដោយសារអថេរជាច្រើន និងរបៀបដែលអថេរទាំងនេះ "ប្រសព្វគ្នា" នឹងអថេរផ្សេងទៀត ដែលជាញឹកញាប់ បង្កឱ្យមានទម្រង់ចម្រុះនៃការលំបាក និងការផាត់ចេញ។ អថេរទាំងនេះមានដូចជា ពូជសាសន៍ វណ្ណៈ ជាតិពន្ធុ យេនឌ័រ ពិការភាព សាសនា អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពជាជនជាតិដើមភាគតិច ស្ថានភាពទេសន្តរប្រវេសន៍ និងកត្តាផ្សេងទៀត។

42 គួរយល់ថា ការលើកឡើងពី "សមាមាត្រ" ពាក់ព័ន្ធនឹងកាលៈទេសៈ ស្ថានភាព និងក្របខណ្ឌពេលវេលាជាក់លាក់ ដែលគ្របដណ្តប់លើការវាយតម្លៃ (សូមមើល ឧ. EU Action Plan on Women, Peace and Security, 2019-2024)។

43 ភាសានេះបន្សុីគ្នានឹងផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។

44 សកម្មភាពអាទិភាពនេះត្រូវបានអំពាវនាវក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។

| |
|---|
| សកម្មភាពអាទិភាព ១.១.២ ៖ កសាងសមត្ថភាពរបស់អ្នកឆ្លើយតបជួរមុខ (ឧ. ប៉ូលិស កងទ័ព បុគ្គលិកសង្គមកិច្ច កងរក្សាសន្តិភាព-ល-។) ដែលធ្វើការក្នុងវិស័យសន្តិភាព និងសន្តិសុខ ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដូចជា តាមរយៈការបណ្ដុះបណ្ដាល (ការបណ្ដុះបណ្ដាលស្ដីពីយេនឌ័រ ការបណ្ដុះបណ្ដាលអ្នកនៅកៀកកិតនឹងស្ថានការណ៍ "កិច្ចសន្ទនាយេនឌ័រ" ការសម្ដែងតួ និងលំហាត់សម ដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ)។ |
| សកម្មភាពអាទិភាព ១.១.៣ ៖ អនុវត្តសកម្មភាពនៅថ្នាក់ជាតិ ដោយផ្អែកលើទិន្នន័យស្ដីពីអ្វីដែលត្រូវការចាំបាច់បំផុតនៅថ្នាក់មូលដ្ឋាន និងឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុតក្នុងការផ្ដល់សេវា បទបញ្ញត្តិ និងកំណែទម្រង់ដែលពាក់ព័ន្ធនឹងគោលនយោបាយ ដើម្បីបង្កើនការផ្ដល់សេវាឆ្លើយតបពហុវិស័យ និងមានការសម្របសម្រួល ក្នុងគោលបំណងទប់ស្កាត់ និងដោះស្រាយអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹង យេនឌ័រ តាមរយៈប្រព័ន្ធគាំទ្ររួមមួយ។ ផ្ដល់លទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ ជំនួយផ្លូវច្បាប់ និងកិច្ចគាំពារសង្គម និងសេវានានា ដូចជា ការពិគ្រោះយោបល់ និងយន្តការ "មិត្តជួយមិត្ត" ដោយមានការបែងចែកធនធាននៅថ្នាក់ជាតិ។ |
| សកម្មភាពអាទិភាព ១.១.៤ ៖ គាំទ្រដល់ការបណ្ដុះបណ្ដាល/កម្មវិធីដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ ដើម្បីកសាងសមត្ថភាពរបស់អ្នកឆ្លើយតបបឋម ក្នុងគោលបំណងផ្ដល់ការផ្សព្វផ្សាយដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ នៅពេលមានការស្នើសុំពីជនរងគ្រោះ ដើម្បីធានាថា សមាជិកគ្រួសារយល់ពីសិទ្ធិរបស់ស្ត្រី និងក្មេងស្រី និងក្នុងករណីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ កាត់បន្ថយការមាក់ងាយ និងផ្ដល់លទ្ធភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងក្រុមគ្រួសាររបស់ពួកគេ ក្នុងការទទួលបានការគាំទ្រ និងសេវានានា។ |
| សកម្មភាពអាទិភាព ១.១.៥ ៖ ផ្ដល់ចន្លោះសុវត្ថិភាព ដូចជា ជម្រកសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងបង្កើនសមត្ថភាពរបស់ប៉ូលិស និងអ្នកពាក់ព័ន្ធ ក្នុងការបញ្ជូនអតិថិជនទៅកាន់ចន្លោះសុវត្ថិភាពទាំងនេះ និងការពារសន្តិសុខរបស់ពួកគេ។ |
| សកម្មភាពអាទិភាព ១.១.៦ ៖ កសាងសមត្ថភាព និងពង្រីកបណ្ដាញ/ឱកាសសម្រាប់អង្គការសង្គម ស៊ីវិល និងអង្គការស្ត្រី ដើម្បីធ្វើការជាមួយភាគីពាក់ព័ន្ធក្នុងជួររដ្ឋាភិបាល លើការគ្រប់គ្រង និងអនុវត្ត បណ្ដាញ និងយន្តការបញ្ជូនជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ។ |
| សកម្មភាពអាទិភាព ១.១.៧ ៖ កំណត់រកបញ្ហាប្រឈមរបស់ជនរងគ្រោះ ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានយុត្តិធម៌ ដូចជា ការយល់ដឹងផ្នែកច្បាប់[45] ការលំបាកផ្នែកហិរញ្ញវត្ថុ បញ្ហាភាសា ការរកបានមេធាវីដែលទទួលការបណ្ដុះបណ្ដាលស្ដីពីបញ្ហាអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងលទ្ធភាពចូលដល់ក្រុមសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងការគាំទ្រផ្លូវច្បាប់។ |
| សកម្មភាពអាទិភាព ១.១.៨ ៖ បង្កើនសមត្ថភាពក្នុងការប្រមូល និងវិភាគទិន្នន័យ (ដោយគោរពអនាមិកភាព និងគិតគូរពីភាពឯកជន) ស្ដីពីឧប្បត្តិហេតុអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងការផ្ដល់សេវាពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីផ្ដល់មូលដ្ឋានព័ត៌មាន និងតាមដានវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីនានា។ |
| សកម្មភាពអាទិភាព ១.១.៩ ៖ បង្កើតយន្តការដាក់លាក់ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទូទាំង សសរស្តម្ភ និងពហុវិស័យក្នុងតំបន់អាស៊ាន ដើម្បីដោះស្រាយហានិភ័យខ្ពស់នៃការកើតមានអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ក្នុងស្ថានភាពសង្គ្រោះបន្ទាន់ និងស្ថានភាពមនុស្សធម៌ និងតំបន់មានជម្លោះ និងអស្ថិរភាព[46]។ |

Continued

45 ការយល់ដឹងផ្នែកច្បាប់ ជាពាក្យដែលសំដៅលើការយល់ដឹងរបស់បុគ្គលម្នាក់ៗអំពីបញ្ហាដែលពាក់ព័ន្ធនឹងច្បាប់ ដូចជា សិទ្ធិទទួលបានការការពារក្នុងផ្លូវច្បាប់ សិទ្ធិមានមេធាវី និងតំណាង និងសិទ្ធិទទួលបានយុត្តិធម៌។

46 ដូចអនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ទំ. ២ និងក្របខណ្ឌតំបន់អាស៊ានស្ដីពីការការពារ យេនឌ័រ និងបរិយាបន្នដែលត្រូវបានអនុម័ត និងប្រកាសផ្សព្វផ្សាយដោយ ACDM ក្នុងឆ្នាំ ២០២២។

| |
|---|
| សកម្មភាពអាទិភាព ១.១.១០ ៖ ដាក់បញ្ចូលការរៀបចំកម្មវិធីស្តីពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ទៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការដោះស្រាយបញ្ហាសន្តិសុខថ្មីៗដែលកំពុងលេចឡើង ដូចជាការទប់ស្កាត់អំពើហិង្សាជ្រុលនិយម ការប្រែប្រួលអាកាសធាតុ ការបាត់បង់ទីលំនៅ ឧក្រិដ្ឋកម្ម ឆ្លងដែន រួមទាំងការជួញដូរមនុស្ស និងបទល្មើសបច្ចេកវិទ្យា និងបញ្ហាអសន្តិសុខផ្សេងទៀត។ |
| សកម្មភាពអាទិភាព ១.១.១១ ៖ ចែករំលែកការអនុវត្តល្អបំផុត និងករណីសិក្សាក្នុងចំណោមរដ្ឋជាសមាជិកអាស៊ានស្តីពីសេវាចម្រុះ ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដូចជា យុទ្ធនាការកសាងការយល់ដឹងជាសាធារណៈដើម្បីកាត់បន្ថយការមាក់ងាយ និងការរើសអើងជនរងគ្រោះ និងផ្តោតលើបញ្ហា ដូចជា ការរៀបការរំលោភកុមារ ការរៀបការកូនក្មេង និងការរៀបការដោយបង្ខំដែលកាន់តែមានភាពជ្រាលជ្រៅដោយសារជម្លោះ និងបញ្ហាសន្តិសុខ។ ស្វែងរកឱកាសចាប់ដៃគូជាមួយបណ្តាញផ្សព្វផ្សាយ ដើម្បីកសាងការយល់ដឹង និងគាំទ្រដល់គោលបំណងទាំងនេះ។ |
| សកម្មភាពអាទិភាព ១.១.១២ ៖ ចងក្រងសាវតាករណីរបស់បុរស និងស្ត្រីដែលជាភ្នាក់ងារផ្លាស់ប្តូរ និងជាអ្នកដឹកនាំក្នុងការទប់ស្កាត់ និងដោះស្រាយអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ និងក្រោមកិច្ចសហការជាមួយបណ្តាញផ្សព្វផ្សាយ។ |
| សកម្មភាពអាទិភាព ១.១.១៣ ៖ ប្រកាសអនុវត្តកម្មវិធីដើម្បីប្រើប្រាស់បច្ចេកវិទ្យាឌីជីថលថ្មីៗ ក្នុងគោលបំណងជំរុញវឌ្ឍនភាពលើគោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ លុបបំបាត់ការបែងចែកយេនឌ័រក្នុងប្រព័ន្ធឌីជីថល ទាញប្រយោជន៍ពីឱកាស (ដូចជា ការតាមដានអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ) និងកាត់បន្ថយហានិភ័យ (ដូចជា ការទប់ស្កាត់ និងការដោះស្រាយការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត និងការស្អប់ខ្ពើមស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត និងការការពារឯកជនភាព និងទិន្នន័យផ្ទាល់ខ្លួន)។ |
| |
| លទ្ធផលរំពឹងទុក ១.២ ៖ បង្កើនសមត្ថភាពរបស់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ានក្នុងការលើកកម្ពស់ការការពារ និងការធានាសិទ្ធិស្ត្រី និងក្មេងស្រី និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងបរិបទដែលរងផលប៉ះពាល់ដោយសារជម្លោះ ក៏ដូចជាក្នុងពេលសង្គ្រោះបន្ទាន់ ការឆ្លើយតបផ្នែកមនុស្សធម៌ និងអសន្តិសុខ។ |
| សកម្មភាពអាទិភាព ១.២.១ ៖ ដាក់បញ្ចូលចក្ខុវិស័យសេដ្ឋកិច្ចទៅក្នុងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[47]។ ធានាការការពារ និងការទ្រទ្រង់របេចិញ្ចឹមជីវិតរបស់ស្ត្រី ជាពិសេសក្នុងបរិបទគ្រោះ មហន្តរាយ ជម្លោះ និងវិបត្តិ និងរិះរកឱកាសសម្រាប់ឱ្យវិស័យឯកជនលើកកម្ពស់គោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ប្រកបដោយប្រសិទ្ធភាព។ |
| សកម្មភាពអាទិភាព ១.២.២ ៖ កំណត់តម្រូវការ និងផ្តល់ការគាំទ្រដល់ស្ត្រី និងក្មេងស្រីដែលត្រូវធ្វើ កិច្ចការថែទាំ ដែលជាញឹកញាប់ មានការកើនឡើងក្នុងអំឡុងពេលបណ្តេញចេញពីទីលំនៅ ក្នុងពេលមានជម្លោះ អសន្តិសុខ គ្រោះមហន្តរាយ វិបត្តិសុខភាពសាធារណៈ និងវិបត្តិសេដ្ឋកិច្ច[48] ក៏ដូចជាគាំទ្រ និងទទួលស្គាល់ការទទួលខុសត្រូវរួមរបស់ស្ត្រី និងបុរសក្នុងការថែទាំកុមារ ចាស់ជរា និងអ្នកផ្សេងទៀតដែលត្រូវការការថែទាំ (ដូចជា អ្នកមានជំងឺ ឬអ្នកមានពិការភាពធ្ងន់ធ្ងរ)។ |
| សកម្មភាពអាទិភាព ១.២.៣ ៖ បញ្ជ្រាបបញ្ហាយេនឌ័រ[49] ទៅក្នុងការផ្តល់សេវាថែទាំសុខភាព (រួមទាំងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ) ដូចជា ក្នុងស្ថានភាពសង្គ្រោះបន្ទាន់ និងស្ថានភាពមនុស្សធម៌។ កសាងសមត្ថភាពរបស់អ្នកឆ្លើយតបជួរមុខដើម្បីឱ្យពួកគេយល់ និងផ្តល់សេវាថែទាំសុខភាពដែលគិតគូរពីវប្បធម៌ និងសមស្របតាមវប្បធម៌ ដល់ស្ត្រីជាជនជាតិភាគតិច យុវជន ចាស់ជរា ស្ត្រីមានពិការភាពជាដើម ក្នុងពេលមានជម្លោះ អសន្តិសុខ និងអំពើហិង្សា។ |
| សកម្មភាពអាទិភាព ១.២.៤ ៖ លើកកម្ពស់សិទ្ធិរបស់ក្មេងស្រី និងស្ត្រីក្នុងការទទួលបានការអប់រំ និងភាពអាចទទួលបានឱកាសអប់រំ (ការបណ្តុះបណ្តាលផ្នែកឌីជីថល វិជ្ជាជីវៈ ការសិក្សាអប់រំ) ដល់អ្នកដែលប្រឈមនឹងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗ និងការបណ្តេញចេញពីទីលំនៅ។ |

Continued

47 ASEAN Report on Women, Peace and Security, p. 28.

48 "កត់សម្គាល់ និងឱ្យតម្លៃការងារថែទាំ និងកិច្ចការផ្ទះសម្បែងដែលមិនទទួលបានប្រាក់ឈ្នួល តាមរយៈគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចគាំពារសង្គម និងការលើកកម្ពស់ការទទួលខុសត្រូវរួមក្នុងគ្រួសារ និងផ្ទះសម្បែង ទៅតាមភាពសមស្របក្នុងប្រទេស" (ASEAN Regional Plan of Action on the Elimination of Violence Against Women (EVAW), p. 10)។

49 See ASEAN Gender Mainstreaming Strategic Framework, 2021-2025.

| |
|---|
| សកម្មភាពអាទិភាព ១.២.៥ ៖ រិះរកវិធីដាក់បញ្ចូលសមភាពយេនឌ័រ និងគោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងកម្មវិធីសិក្សាអប់រំ ដើម្បីកសាងការយល់ដឹងពីបញ្ហាទាំងនេះ និងបង្កើនការយល់ដឹងពីរបៀបអនុវត្តគោលបំណងនៃសន្តិភាព ការយល់ដឹង និងសមភាព ក្នុងដែនសមត្ថកិច្ចនីមួយៗ (ឧ. កម្រិតគ្រួសារ និងសហគមន៍មូលដ្ឋាន ក៏ដូចជាក្នុងកម្មវិធីបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដូចជា មហាវិទ្យាល័យយោធា)។ |
| សកម្មភាពអាទិភាព ១.២.៦ ៖ ក្រោមការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល កំណត់យន្តការជាក់លាក់សម្រាប់ការជួបប្រជុំ និងការចូលរួមជាមួយសង្គមស៊ីវិល ដូចជា អង្គការយុវជន និងអង្គការសាសនា និងផ្តល់ឱកាសសម្រាប់ការចូលរួមដោយអង្គការសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធនឹងសិទ្ធិស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីផ្តល់ធាតុចូលដល់គំនិតផ្តួចផ្តើមសន្តិភាព និងសន្តិសុខរបស់ រដ្ឋាភិបាល និងអាស៊ាន[50]។ |
| សកម្មភាពអាទិភាព ១.២.៧ ៖ កំណត់ជំហានចាំបាច់ និងរៀបចំផែនការដើម្បីគាំទ្រដល់ការពិគ្រោះយោបល់ជាមួយសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន (រដ្ឋាភិបាល វិស័យសន្តិសុខ អ្នកជំនាញផ្នែកសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល) ដើម្បីលើកកម្ពស់សកម្មភាពរួម និងមានប្រសិទ្ធភាព ក្នុងចំណោមអ្នកតាក់តែងគោលនយោបាយ អ្នកអនុវត្តន៍ ស្ថាប័នសិក្សាស្រាវជ្រាវ-ល- ស្តីពីការការពារសិទ្ធិស្ត្រី[51]។ |
| |
| លទ្ធផលរំពឹងទុក ១.៣ ៖ វិស័យសន្តិសុខ (ដូចជា កងទ័ព និងប៉ូលិស) កំណត់វិធីបង្កើនការបញ្ជ្រាបយេនឌ័រ និងការការពារសិទ្ធិស្ត្រីទៅក្នុងការឆ្លើយតបរបស់ខ្លួនទៅនឹងបញ្ហាសន្តិសុខទូទៅ និងបញ្ហា សន្តិសុខថ្មីៗ។ |
| សកម្មភាពអាទិភាព ១.៣.១ ៖ កសាងសមត្ថភាពរបស់ស្ថាប័នសន្តិសុខរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធ ក្នុងការដាក់បញ្ចូល និងបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងការអនុវត្តរបស់ពួកគេ ដោយផ្អែកតាមទេពកោសល្យ បទពិសោធន៍ ចំណេះដឹង និងជំនាញរបស់បុរស និងស្ត្រី។ |
| សកម្មភាពអាទិភាព ១.៣.២ ៖ បង្កើតឱ្យមានការវាយតម្លៃយេនឌ័រក្នុងស្ថាប័ន ដូចជា ការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីក្នុងប្រតិបត្តិការសន្តិភាព ដើម្បីស្វែងយល់ពីបញ្ហាប្រឈម និងឧបសគ្គដែលរារាំងការដាក់បញ្ចូលស្ត្រីឱ្យបានពេញលេញ និងប្រកបដោយអត្ថន័យទៅក្នុងវិស័យសន្តិសុខ និងកំណត់រកគម្លាតក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យសន្តិសុខ។ |
| សកម្មភាពអាទិភាព ១.៣.៣ ៖ កំណត់អត្ថប្រយោជន៍នៃការបង្កើតអង្គភាពយេនឌ័រក្នុងស្ថាប័នសន្តិសុខ |
| សកម្មភាពអាទិភាព ១.៣.៤ ៖ បំពាក់បំប៉ន និងបណ្តុះបណ្តាលតួអង្គក្នុងវិស័យសន្តិសុខ ដូចជា ប៉ូលិស និងកងកម្លាំងប្រដាប់អាវុធ និងអ្នកផ្តល់សេវាជួរមុខផ្សេងទៀត ដើម្បីការពារសិទ្ធិស្ត្រី ក៏ដូចជាវាយតម្លៃ និងស្វែងយល់ពីតម្រូវការរបស់ស្ត្រីដែលអាចមានហានិភ័យ ឬការព្រួយបារម្ភជាក់លាក់ ដូចជា ស្ត្រីជាជនជាតិភាគតិច ស្ត្រីមានពិការភាព ស្ត្រីចំណាស់ យុវជន និងកុមារដែលមិនមានអ្នករួមដំណើរជាមួយ ពលករទេសន្តរប្រវេសក៍[52] ស្ត្រីបាត់បង់ទីលំនៅ និងស្ត្រីជាជនភៀសខ្លួន ក្នុងគោលបំណងធានាសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងការបង្កើនភាពអង់អាចដល់ពួកគេ ដូចជា ក្នុងស្ថានភាពផុយស្រួយ និង ស្ថានភាពដែលរងផលប៉ះពាល់ដោយសារជម្លោះ។ |

50 ដូចការកត់សម្គាល់ដោយ "សេចក្តីសន្និដ្ឋានដែលបានព្រមព្រៀង" សម្រាប់គណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ៦៦ (២០២២) ចាំបាច់ត្រូវអនុវត្តជំហាននានាដើម្បីការពារសិទ្ធិ និងសុវត្ថិភាពរបស់តួអង្គសង្គមស៊ីវិល។ គណៈកម្មការនេះសម្រេច "គាំទ្រដល់តួនាទីដ៏សំខាន់របស់តួអង្គសង្គមស៊ីវិលក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ស្ត្រីគ្រប់រូប" និង "ចាត់វិធានការការពារតួអង្គទាំងនោះ រួមទាំងស្ត្រីដែលជាអ្នកការពារសិទ្ធិមនុស្ស...ពីការរំលោភបំពាន និងការបៀតបៀនលើពួកគេ ដូចជា ការគំរាមកំហែង ការបៀតបៀន អំពើហិង្សា និងការសងសឹក" (UN Economic and Social Council, CSW 66, 29 March 2022)។

51 ASEAN Report on WPS, p. 2.

52 សម្រាប់ការកត់សម្គាល់ពីចំនួនយ៉ាងច្រើននៃពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ាន សូមមើល ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers adopted in 2007, Declaration on Migrant Worker Rights (2009), ASEAN Regional Conference of Senior Officials on Strengthening the Protection and Empowerment of Women Migrant Workers in Manila on 13-14 November 2014 and the ASEAN Consensus On The Protection And Promotion Of The Rights Of Migrant Workers (2017).

## តារាងស្តីពីការចូលរួម

| |
|---|
| លទ្ធផលយុទ្ធសាស្ត្រទី ២ ៖ ការចូលពេញលេញ ប្រកបដោយអត្ថន័យ និងស្មើភាពរបស់ស្ត្រីក្នុងស្ថាប័ន អង្គការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ រួមទាំងក្នុងមុខតំណែងដឹកនាំ |
| សូចនាករលទ្ធផលចុងក្រោយ ៖<br>• ចំនួន និងសមាមាត្រនៃអាសនៈដែលកាន់កាប់ដោយស្ត្រី រួមទាំងស្ត្រីមកពីក្រុមជនជាតិភាគតិច និងក្រុមងាយរងគ្រោះ[53] នៅក្នុង ក) រដ្ឋសភា និង ខ) រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាក្នុងមុខតំណែងគ្រប់គ្រង[54]។<br>• ចំនួន និងសមាមាត្ររបស់ស្ត្រីក្នុងស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ាន ដោយមានការលើកឡើងជាក់លាក់ពីស្ត្រីដែលកាន់មុខតំណែងដឹកនាំ និងមុខតំណែងជាន់ខ្ពស់ ដូចជា ប្រធានបេសកកម្មការទូត និងគណៈប្រតិភូអាស៊ាន ក៏ដូចជាបុគ្គលិកអាស៊ានដែលចូលរួមក្នុងកិច្ចប្រជុំ បេសកកម្ម និងប្រតិបត្តិការអង្គការសហប្រជាជាតិ និងកិច្ចប្រជុំ បេសកកម្ម និងប្រតិបត្តិការថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ផ្សេងទៀត។ ចំណុចនេះគួររួមបញ្ចូល (ប្រសិនបើអាច) ការរាយការណ៍ពីទិន្នន័យពាក់ព័ន្ធនឹងភាពចម្រុះ ដែលគោរពការព្រួយបារម្ភពីឯកជនភាព[55]។<br>• ចំនួនរដ្ឋជាសមាជិកអាស៊ានដែលអនុម័តគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីគាំទ្រការចូលរួម និងការដឹកនាំរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តស្តីពីសន្តិភាព និងសន្តិសុខ[56]។<br>• ចំនួន និងភាគរយនៃអ្នកផ្សះផ្សារ អ្នកចរចា អ្នកជំនាញបច្ចេកទេស និងហត្ថលេខីជាស្ត្រី ក្នុងដំណើរការសន្តិភាពសំខាន់ៗក្នុងរដ្ឋជាសមាជិកអាស៊ាន[57] ដូចជា បេសកកម្មសន្តិភាព និងបេសកកម្មស្វែងរកការពិត និងយុត្តិធម៌ ក៏ដូចជាក្នុងដំណើរការសន្តិភាពក្រៅផ្លូវការ ដែលចូលរួមដោយអាស៊ាន និងរដ្ឋជាសមាជិកអាស៊ាន ដោយមានការលើកឡើងជាក់លាក់ពីស្ត្រីដែលកាន់មុខតំណែងដឹកនាំ។ |
| |
| លទ្ធផលរំពឹងទុក ២.១ ៖ បង្កើនសមត្ថភាពក្នុងការធានាភាពជាតំណាងរបស់ស្ត្រី និងការចូលរួមយ៉ាងពេញលេញ និងស្មើភាពរបស់ស្ត្រីនៅថ្នាក់តំបន់ និងថ្នាក់ជាតិ និងក្នុងមុខតំណែងដឹកនាំសំខាន់ៗនៅក្នុងសសរស្តម្ភរបស់អាស៊ាន ស្ថាប័នតាមវិស័យ និងអង្គភាពពាក់ព័ន្ធរបស់អាស៊ាន[58]។ |
| សកម្មភាពអាទិភាព ២.១.១ ៖ ពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការជ្រើសរើស និងការរក្សាទុកស្ត្រីក្នុងមុខតំណែង គោលនយោបាយស្តីពីតុល្យភាពរវាងជីវិត និងការងារ និងកំណត់រកឧបសគ្គផ្សេងទៀតក្នុងផ្នែកស្ថាប័ន និងគោលនយោបាយដើម្បីបង្កើនតុល្យភាពយេនឌ័រ ដូចជា ក្នុងមុខតំណែងដឹកនាំក្នុងស្ថាប័ន និងដំណើរការដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខក្នុងអាស៊ាន និងរដ្ឋជាសមាជិក។ ផ្តល់អនុសាសន៍ដោយផ្អែកតាមភស្តុតាង។ |

Continued

53 ចំណុចនេះអាចរួមបញ្ចូលការរាយការណ៍ពីអថេរនានា ដូចជា ពូជសាសន៍ វណ្ណៈ ជាតិពន្ធុ និងកត្តាផ្សេងទៀត ដើម្បីគាំទ្រដល់ភាពចម្រុះ និងបរិយាបន្ន។ ចាំបាច់ត្រូវពិចារណា និងអនុវត្តសកម្មភាពប្រមូលទិន្នន័យប្រកបដោយក្រមសីលធម៌ និងត្រូវចាត់វិធានការការពារសន្តិសុខ និងភាពឯកជន ដូចជា ការរាយការណ៍ដោយស្ម័គ្រចិត្ត និងជាអនាមិកស្តីពីទិន្នន័យដែលពាក់ព័ន្ធនឹងភាពចម្រុះ។

54 ចំណុចនេះបំពេញបន្ថែមលើសូចនាករ ៥.៥.១ និង ៥.៥.២ សម្រាប់គោលដៅទី ៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ ចំណុចដៅ ៥.៥ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ) គឺការ "ធានាការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី និងឱកាសស្មើភាពសម្រាប់ការដឹកនាំនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចចិត្តក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងសាធារណៈ"។

55 សូមមើលលេខយោងទី ១២ ខាងលើ។

56 នៅថ្នាក់ជាតិ សូចនាករនេះអាចពិចារណាបន្ថែមសកម្មភាព/ចំណុចដៅជាក់លាក់ដើម្បីបង្កើនការចូលរួម និងការដឹកនាំរបស់ស្ត្រីដែលមកពីក្រុមងាយរងគ្រោះនិងក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់ ដូចជា ស្ត្រីមានពិការភាព។

57 See some baseline data available for selected countries available at peacemakers.org, and ASEAN-IPR data available at https://asean-aipr.org/asean-women- peace-registry/.

58 ទោះបីជាមានភាពប្រសើរឡើងក៏ដោយ ប៉ុន្តែនៅតែមានគម្លាត និងកង្វះភាពជាតំណាង។ ចាំបាច់ត្រូវចាត់វិធានការជាក់លាក់ដើម្បីធានាភាពជាតំណាង និងបរិយាបន្នក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តផ្លូវការសម្រាប់ស្ត្រីដែលមកពីក្រុមងាយរងគ្រោះនិងក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់។ See, ASEAN Gender Outlook, 1 March 2021, available at https://data.unwomen.org/publications/asean-gender-outlook; and ASEAN Gender Mainstreaming Strategic Framework 2021–2025, available at https://asean.org/wp-content/uploads/2022/01/ASEAN-Gender-Mainstreaming-Strategic-Framework-endorsed-by-AMMW.pdf.

| |
|---|
| សកម្មភាពអាទិភាព ២.១.២ ៖ លើកទឹកចិត្តឱ្យអាស៊ាន និងរដ្ឋជាសមាជិកអនុម័តការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ និងអនុវត្តអនុសាសន៍ដើម្បីដោះស្រាយអតុល្យភាពយេនឌ័រ ក្នុងភាពជាតំណាងតាមស្ថាប័ន និងធានាការចូលរួមយ៉ាងពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រី។ |
| សកម្មភាពអាទិភាព ២.១.៣ ៖ អនុម័តចំណុចដៅដាក់លាក់ (ឧ. សមាមាត្ររបស់ស្ត្រី) ដើម្បី ដោះស្រាយអតុល្យភាពយេនឌ័រក្នុងភាពជាតំណាងតាមស្ថាប័នគ្រប់លំដាប់ថ្នាក់។ |
| សកម្មភាពអាទិភាព ២.១.៤ ៖ បង្កើនការប្រមូលទិន្នន័យ និងការរាយការណ៍ពីចំនួនស្ត្រី និងបុរស (ទិន្នន័យបែងចែកតាមភេទ) ទូទាំងសហគមន៍របស់អាស៊ានទាំងអស់ ស្ថាប័នតាមវិស័យ និងអង្គភាពពាក់ព័ន្ធរបស់អាស៊ាន ដើម្បីលើកកម្ពស់ការដឹកនាំ និងការចូលរួមដោយស្មើភាព។ |
| សកម្មភាពអាទិភាព ២.១.៥ ៖ បង្កើតយន្តការរាយការណ៍ប្រចាំឆ្នាំ ឬប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំស្តីពីតុល្យភាពយេនឌ័រតាមស្ថាប័ន និងការចូលរួមរបស់ស្ត្រី ជាពិសេសក្នុងការធ្វើសេចក្តីសម្រេចចិត្តស្តីពី សន្តិភាព និងសន្តិសុខ។ |
| សកម្មភាពអាទិភាព ២.១.៦ ៖ រៀបចំការបណ្តុះបណ្តាល និងលំហាត់កសាងសមត្ថភាពដើម្បីលើកកម្ពស់ការដាក់បញ្ចូលស្ត្រី និងក្រុមផ្សេងទៀតដែលអាចជួបការលំបាក ទៅក្នុងវិស័យសន្តិភាព និង សន្តិសុខក្នុងសសរស្តម្ភរបស់អាស៊ាន ស្ថាប័នតាមវិស័យ និងអង្គភាពពាក់ព័ន្ធរបស់អាស៊ានឱ្យបានពេញលេញ។ កំណត់បទដ្ឋាន និងការអនុវត្តដែលគួរកែប្រែ និងអភិក្រមថ្មីៗសម្រាប់ការអនុវត្តដើម្បីបង្កើនភាពជាតំណាងរបស់អ្នកដែលមកពីក្រុមជនជាតិភាគតិច និងក្រុមងាយរងគ្រោះ និងបង្កើនតុល្យភាពយេនឌ័រ ដូចជាក្នុងមុខតំណែងដឹកនាំ។ |
| សកម្មភាពអាទិភាព ២.១.៧ ៖ ធានាការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់គោលនយោបាយស្តីពីការជ្រើសរើស ការរក្សាទុកស្ត្រីក្នុងមុខតំណែង និងការដំឡើងឋានៈ និងការស្ទង់មតិនៅពេលចាកចេញពីកម្មវិធី ដើម្បីធានាការដាក់បញ្ចូលស្ត្រីបានពេញលេញ និងឱកាសរបស់ស្ត្រីក្នុងស្ថាប័នវិស័យសន្តិសុខ។ |
| សកម្មភាពអាទិភាព ២.១.៨ ៖ ចងក្រងមេរៀន និងការអនុវត្តល្អនៅទូទាំងរដ្ឋជាសមាជិកអាស៊ានទាំងអស់ ដូចជា មេរៀន និងការអនុវត្តល្អដែលបានកំណត់ពីសមាសភាគរងនៃការដឹកនាំរបស់ស្ត្រីក្នុងកម្មវិធីកសាងសមត្ថភាពទប់ទល់នឹងគ្រោះមហន្តរាយរបស់អាស៊ាន។ |
| |
| លទ្ធផលរំពឹងទុក ២.២ ៖ អង្គការដែលធ្វើការពាក់ព័ន្ធនឹងស្ត្រី អង្គការដែលធ្វើការពាក់ព័ន្ធនឹងយុវជន និងក្រុមសង្គមស៊ីវិលផ្សេងទៀត អាចចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការពិគ្រោះយោបល់ រៀបចំផែនការ អនុវត្ត និងវាយតម្លៃរបស់អាស៊ាន ដើម្បីឆ្លុះបញ្ចាំងកាន់តែប្រសើរពីចក្ខុវិស័យ និងតម្រូវការរបស់ស្ត្រី និងក្មេងស្រីនៅក្នុងតំបន់ និងធានាការចូលរួមរបស់ស្ត្រីប្រកបដោយសមធម៌ និងបរិយាបន្ន។ |
| សកម្មភាពអាទិភាព ២.២.១ ៖ ប្រមូល និងវិភាគទិន្នន័យដើមគ្រាស្តីពីបរិយាបន្ន និងការចូលរួមរបស់អង្គការដែលធ្វើការពាក់ព័ន្ធនឹងស្ត្រីក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីអាស៊ានស្តីពីសន្តិភាព និងសន្តិសុខ (ក្នុងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗ)។ |
| សកម្មភាពអាទិភាព ២.២.២ ៖ អនុវត្តជាប្រព័ន្ធនូវការប្រមូល ការវិភាគ និងការបោះពុម្ពផ្សាយទិន្នន័យជាប្រចាំស្តីពីការចូលរួមរបស់ស្ត្រី និងអង្គការដែលធ្វើការពាក់ព័ន្ធនឹងស្ត្រី ក្នុងការបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីអាស៊ានស្តីពីសន្តិភាព និងសន្តិសុខ (បញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗ)។ |
| សកម្មភាពអាទិភាព ២.២.៣ ៖ កំណត់រកក្រុម និងស្ត្រី ដែលមានតំណាងតិចតួច និងធានានូវបណ្តាញចូលរួម ឧបករណ៍ និងគោលការណ៍ណែនាំដែលមានប្រសិទ្ធភាព និងបរិយាបន្ន (រួមទាំងគោលការណ៍ណែនាំស្តីពីប្រព័ន្ធឌីជីថល) សម្រាប់សង្គមស៊ីវិលស្ត្រីដែលរងផលប៉ះពាល់ដោយសារវិបត្តិ និងជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ដូចជា ស្ត្រីមានពិការភាព ស្ត្រីមកពីក្រុមភាសាភាគតិច និងក្រុមជនជាតិភាគតិច ។ល។ |

Continued

| |
|---|
| សកម្មភាពអាទិភាព ២.២.៤ ៖ បង្កើតគោលនយោបាយជាក់លាក់ យន្តការស្ថាប័ន និងផែនការការងារដែលទទួលបានមូលនិធិ (រួមទាំងចំណុចដៅ) សម្រាប់ការពិគ្រោះយោបល់ជាប្រចាំជាមួយសង្គមស៊ីវិល និងបណ្តាញផ្សេងទៀត ដូចជាកិច្ចប្រជុំប្រចាំឆ្នាំ និង/ឬដំណើរការពិគ្រោះយោបល់តាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីប្រមូលធាតុចូលសម្រាប់ដាក់នៅក្នុងគោលនយោបាយ និងកម្មវិធីសន្តិភាព និងសន្តិសុខ។ ស្វែងរកលទ្ធភាពបង្កើនការដាក់បញ្ចូលអង្គការសង្គមស៊ីវិលជាអង្គភាពដែលចងសម្ព័ន្ធភាពជាមួយអាស៊ានឬអ្នកផ្សះផ្សារជាស្ត្រីដែលចងសម្ព័ន្ធភាពជាមួយអាស៊ាន។ |
| សកម្មភាពអាទិភាព ២.២.៥ ៖ គាំទ្រដល់បណ្តាញថ្នាក់ជាតិ និងបណ្តាញថ្នាក់តំបន់នៃអង្គការដែលធ្វើការពាក់ព័ន្ធនឹងស្ត្រី/អង្គការសង្គមស៊ីវិលដែលមានឯកទេសតាមមូលបទដែលពាក់ព័ន្ធ (ការបញ្ឈប់អំពើហិង្សាលើស្ត្រី ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ/មនុស្សធម៌ ។ល។) ដើម្បីលើកឡើងដោយស៊ីសង្វាក់គ្នាអំពីភាពងាយរងគ្រោះរបស់ប្រជាជន នៅមុនពេល ក្នុងពេល និងក្រោយពេលវិបត្តិ តាមរយៈការបន្ត និងការផ្សារភ្ជាប់កិច្ចខិតខំប្រឹងប្រែងក្នុងវិស័យសន្តិភាព វិស័យមនុស្សធម៌ និងវិស័យអភិវឌ្ឍន៍។ |
| សកម្មភាពអាទិភាព ២.២.៦ ៖ កំណត់ជំហានចាំបាច់ក្នុងការបង្កើតសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីកំណត់រក និងចែករំលែកការអនុវត្តល្អ និងមេរៀនទូទាំងសសរស្តម្ភនានា និងខិតខំបង្កើនភាពជាដៃគូ និងអភិបាលកិច្ចពហុភាគី ដើម្បីឱ្យការអនុវត្តគោលនយោបាយទទួលបានជោគជ័យ[59]។ |
| សកម្មភាពអាទិភាព ២.២.៧ ៖ លើកកម្ពស់ការចូលរួមរបស់គ្រួសារ សហគមន៍ អង្គការសាសនា បណ្តាញផ្សព្វផ្សាយ និងវិស័យឯកជនក្នុងការបង្កើនការចូលរួម និងការដឹកនាំរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើមដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ នៅថ្នាក់តំបន់ និងថ្នាក់ជាតិ។ |
| សកម្មភាពអាទិភាព ២.២.៨ ៖ ជំរុញការចូលរួមរបស់បណ្តាញផ្សព្វផ្សាយ ក៏ដូចជានាយកដ្ឋានទំនាក់ទំនងសាធារណៈ និងនាយកដ្ឋានផ្សព្វផ្សាយក្នុងស្ថាប័នអាស៊ាន និងរដ្ឋាភិបាល ដើម្បីជំរុញភាសាដែលមាន "យុត្តិធម៌យេនឌ័រ" នៅពេលរាយការណ៍ពីសន្តិភាព និងសន្តិសុខ និងបង្កើនភាពលេចធ្លោរបស់បុរស និងស្ត្រីដែលចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ក្នុងការគាំទ្រដល់អាទិភាពស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា តាមរយៈគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល។ |
| |
| លទ្ធផលរំពឹងទុក ២.៣ ៖ អ្នកកសាងសន្តិភាពជាស្ត្រី (ក្នុងនាមជាអ្នកផ្សះផ្សារ អ្នកចរចា និង/ឬអ្នកឆ្លើយតបបឋម) មានឱកាស និងសមត្ថភាពកាន់តែច្រើនក្នុងការចូលរួមនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ |
| សកម្មភាពអាទិភាព ២.៣.១ ៖ កសាងសមត្ថភាពរបស់បណ្តាញស្ត្រីស្តីពីសន្តិភាព ( the ASEAN Women for Peace Registry ) និង/ឬបណ្តាញអ្នកផ្សះផ្សារ និងអ្នកចរចាសន្តិភាពជាស្ត្រីនៅថ្នាក់តំបន់ ដូចជា ការកំណត់តម្រូវការបណ្តុះបណ្តាល និងការបង្កើតវគ្គបណ្តុះបណ្តាល និងកម្មវិធីសិក្សាដែលមានស្តង់ដារក្នុងផ្នែកមូលបទផ្សេងៗ ដែលពាក់ព័ន្ធនឹងការកសាងសន្តិភាព ការទប់ស្កាត់ជម្លោះ ការដោះស្រាយ និងស្តារឡើងវិញ រួមទាំងជំនាញឌីជីថល។ |
| សកម្មភាពអាទិភាព ២.៣.២ ៖ ទាញប្រយោជន៍ និងពង្រីកជំនាញក្នុងតំបន់អាស៊ាន ជាមួយអ្នកកសាងសន្តិភាពជាស្ត្រី តាមរយៈការចងក្រងសាវតាររបស់អ្នកកសាងសន្តិភាពជាស្ត្រីនៅថ្នាក់តំបន់ និងថ្នាក់ប្រទេស និងការចងក្រងករណីសិក្សា និងមេរៀនពីស្ត្រីទាំងនោះ ដើម្បីយកទៅចែករំលែកនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ |
| សកម្មភាពអាទិភាព ២.៣.៣ ៖ បង្កើត និង/ឬពង្រីកបញ្ជីឈ្មោះដែលបានឆ្លងកាត់ការពិនិត្យផ្ទៀងផ្ទាត់ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ ពោលគឺបញ្ជីឈ្មោះស្ត្រីដែលបានទទួលការបណ្តុះបណ្តាល និងមានគុណវុឌ្ឍិសម្រាប់ការផ្សះផ្សារ និងការចរចាសន្តិភាព។ |
| |
| លទ្ធផលរំពឹងទុក ២.៤ ៖ ស្ត្រីអាចចូលរួមប្រកបដោយអត្ថន័យ និងពេញលេញក្នុងស្ថាប័នវិស័យ សន្តិសុខរបស់រដ្ឋជាសមាជិកអាស៊ាន ដូចជា កងកម្លាំងប្រដាប់អាវុធ និងប៉ូលិស រួមទាំងក្នុងមុខតំណែងដឹកនាំ និងមានសមត្ថភាពកាន់តែច្រើនក្នុងការដាក់ពង្រាយកងរក្សាសន្តិភាពជាស្ត្រីនៅគ្រប់ជាន់ថ្នាក់ ជាពិសេសក្នុងមុខតំណែងដឹកនាំ។ |

Continued

59 ស្នើឡើងដោយ ASEAN Report on WPS, p.2 and 4.

| |
|---|
| សកម្មភាពអាទិភាព ២.៤.១ ៖ លើកទឹកចិត្តឱ្យរដ្ឋជាសមាជិកអាស៊ានកំណត់ចំណុចដៅសម្រាប់សមាមាត្ររបស់ស្ត្រី ដើម្បីបង្កើនតុល្យភាពយេនឌ័រនៅគ្រប់កម្រិតក្នុងស្ថាប័នវិស័យសន្តិសុខអាស៊ានរបស់រដ្ឋជាសមាជិកអាស៊ាន និងពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការជ្រើសរើស ការរក្សាទុកស្ត្រីក្នុងមុខតំណែង ការដាក់ពង្រាយ និងការដំឡើងឋានៈ និងការអនុវត្តនានាដើម្បីគាំទ្រដល់សមភាពយេនឌ័រក្នុងការពង្រឹងការអនុវត្តច្បាប់ កងកម្លាំងប្រដាប់អាវុធ និងក្នុងការដាក់ពង្រាយកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ[60]។ |
| សកម្មភាពអាទិភាព ២.៤.២ ៖ ធ្វើការជាមួយរដ្ឋជាសមាជិកអាស៊ានដើម្បីកំណត់វិធីជាក់លាក់ក្នុងការប្រើប្រាស់សេចក្តីណែនាំ និងជំនាញពហុវិស័យ និងទូទាំងសសរស្តម្ភសម្រាប់រដ្ឋជាសមាជិកអាស៊ាន ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសន្តិសុខជាតិ និងបង្កើនតុល្យភាពយេនឌ័រ ជាពិសេសការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិសុខ (ដូចជា យោធា និងការអនុវត្តច្បាប់) ដើម្បីដោះស្រាយទាំងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗ ដូចជា ឧក្រិដ្ឋកម្មឆ្លងដែន ការគ្រប់គ្រងព្រំដែន[61] និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ |
| សកម្មភាពអាទិភាព ២.៤.៣ ៖ ខិតខំបង្កើនការប្រមូល និងការវិភាគទិន្នន័យបែងចែកតាមយេនឌ័រស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិសុខដើម្បី ប្រមូលទិន្នន័យដើមគ្រា ពិនិត្យតាមដានវឌ្ឍនភាព និងផ្តល់មូលដ្ឋានព័ត៌មានដល់អន្តរាគមន៍គោលដៅនៅថ្នាក់តំបន់ និងថ្នាក់ប្រទេសទៅតាមភាពសមស្រប[62]។ |
| សកម្មភាពអាទិភាព ២.៤.៤ ៖ បង្កើនបណ្តាញ និងវេទិកាថ្នាក់តំបន់សម្រាប់ឱ្យរដ្ឋជាសមាជិកអាស៊ានចែករំលែកបទពិសោធន៍ និងការអនុវត្តល្អបំផុតដែលពាក់ព័ន្ធនឹងការបង្កើនតុល្យភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិសុខ (គោលនយោបាយជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ការបណ្តុះបណ្តាល យេនឌ័រក្នុងវិស័យការពារជាតិ និងប៉ូលិស ការប៉ាន់ប្រមាណរបាំងយេនឌ័រ។ល។) |
| សកម្មភាពអាទិភាព ២.៤.៥ ៖ ប៉ាន់ប្រមាណបណ្តាញបច្ចុប្បន្ន ដែលប្រើប្រាស់ដោយស្ត្រីក្នុងវិស័យ សន្តិសុខ (ប៉ូលិស យោធា ការការពារជាតិ ការរក្សាសន្តិភាព ។ល។) និងកំណត់រកបណ្តាញបន្ថែម និងឱកាសហ្វឹកហ្វឺនដែលអាចត្រូវការចាំបាច់ និងឱកាសសម្រាប់ការលើកកម្ពស់ការដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិសុខ ដោយខិតខំទាញប្រយោជន៍ពីជំនាញរបស់បណ្តាញទាំងនេះ និងកំណត់វិធីដែលបុរសអាចបន្តគាំទ្រដល់ការដឹកនាំ និងភាពជោគជ័យរបស់ស្ត្រីក្នុងវិស័យសន្តិសុខ។ |
| សកម្មភាពអាទិភាព ២.៤.៦ ៖ ជំរុញការប្រើប្រាស់ភាសាដែលមាន "យុត្តិធម៌យេនឌ័រ[63]" ក្នុងវិស័យសន្តិសុខ និងភាពជាតំណាងរបស់បុរស និងស្ត្រីក្នុងយុទ្ធនាការជ្រើសរើស និងឯកសារផ្សព្វផ្សាយជា សាធារណៈផ្សេងទៀត ដើម្បីបង្ហាញពីបុរស និងស្ត្រីគំរូដែលធ្វើការងារក្នុងគ្រប់ផ្នែកនៃវិស័យសន្តិភាព និងសន្តិសុខ តាមរយៈការចងក្រងសាវតារស្ត្រីដែលកាន់មុខតំណែងដឹកនាំ និងការដាក់បញ្ចូលបុរស និងស្ត្រីដែលមកពីក្រុមពូជសាសន៍ និងក្រុមជាតិពន្ធុផ្សេងៗ។ |

60 The ASEAN Concept Paper on Enhancing Support Mechanism for ASEAN Women ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២២ រៀបរាប់ពីគំនិតផ្តួចផ្តើមដើម្បីគាំទ្រដល់អ្នករក្សាសន្តិភាពជាស្ត្រីក្នុងតំបន់អាស៊ាន។

61 សូមមើល ASEAN Border Management Cooperation Roadmap ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០២១ ដើម្បីកែលម្អគោលនយោបាយ និងបង្កើនកិច្ចសហការក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែននៅតាមព្រំដែន។ ឯកសារនេះក៏គូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីក្នុងការពង្រឹងការអនុវត្តច្បាប់ផងដែរ។

62 See, data available in Interpol, UNODC and UN Women, Women in Law Enforcement in the ASEAN region, available at https://asiapacific.unwomen.org/en/digital-library/publications/2020/08/women-in-law-enforcement-in-the-asean-region.

63 ភាសាដែលមានយុត្តិធម៌យេនឌ័រ មានគោលបំណងកាត់បន្ថយផ្នត់គំនិត និងការរើសអើង ដូចជា តាមរយៈការប្រើពាក្យ "police officer" ជំនួសឱ្យពាក្យ "policeman" និងមិនប្រើតែសព្វនាម "he"។

## តារាងស្តីពីការទប់ស្កាត់

លទ្ធផលយុទ្ធសាស្ត្រទី ៣ ៖ ស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ាន ដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកដល់ការទប់ស្កាត់ជម្លោះនៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតលើសន្តិភាព និង សន្តិសុខ ដោយមានគោលការណ៍នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាចំណុចស្នូលនៃសកម្មភាពទាំងនេះ។

សូចនាករលទ្ធផលចុងក្រោយ ៖

- ចំនួនក្របខណ្ឌជាតិ និងក្របខណ្ឌកម្មវិធីដែលពាក់ព័ន្ធនឹងការទប់ស្កាត់ជម្លោះ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតលើសន្តិភាព និងសន្តិសុខ[64] ដែលលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ អមជាមួយនឹងយន្តការគណនេយ្យភាព និងការបែងចែកធនធាន។
- ភាគរយនៃកិច្ចព្រមព្រៀងសន្តិភាពដែលមានបទបញ្ញត្តិជាក់លាក់ សម្រាប់ការលើកកម្ពស់ សន្តិសុខ និងស្ថានភាពរបស់ស្ត្រី និងក្មេងស្រី[65]។
- ការកើនឡើងនៃចំនួនកិច្ចសហការ និងភាពជាដៃគូរវាងក្រុមពហុវិស័យ និងអាស៊ានលើវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ យេនឌ័រ និងវិធានការដែលពាក់ព័ន្ធនឹងបរិយាបន្នសង្គម[66]។
- ចំនួនរដ្ឋជាសមាជិកអាស៊ានដែលមានយន្តការជូនដំណឹងជាមុនដែលឆ្លើយតបនឹងយេនឌ័រ ដូចជា ការប្រមូល និងវិភាគទិន្នន័យជាប្រចាំស្តីពីជម្លោះ និងអំពើហិង្សា និងការពិនិត្យតាមដានសូចនាករជម្លោះ និងសូចនាករសន្តិភាព និងសន្តិសុខផ្សេងទៀត ដូចជា ទិន្នន័យពីស្ត្រី បុរស យុវជន និងក្រុមងាយរងគ្រោះដើម្បីគាំទ្រដល់អន្តរាគមន៍ដំបូងៗ និងការកាត់បន្ថយហានិភ័យ។

លទ្ធផលរំពឹងទុក ៣.១ ៖ យន្តការជូនដំណឹងជាមុន និងវិធានការទប់ស្កាត់ជម្លោះ និងហានិភ័យចំពោះសន្តិភាព និងសន្តិសុខ (ដូចជា ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ/ការបណ្តេញចេញពី ទីលំនៅ[67] ការជួញដូរមនុស្ស ជំងឺរាតត្បាត ការគំរាមកំហែងលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាជ្រុលនិយម) មានសមត្ថភាពកាន់តែច្រើនក្នុងការវិភាគ និងយល់ពីតួនាទី បទពិសោធន៍ តម្រូវការ និងផលប៉ះពាល់ផ្សេងៗសម្រាប់ស្ត្រី និងបុរស ជាពិសេសអ្នកដែលមកពីក្រុមងាយរងគ្រោះ។

សកម្មភាពអាទិភាព ៣.១.១ ៖ ធ្វើកិច្ចសហប្រតិបត្តិការបច្ចេកទេសដើម្បីផ្លាស់ប្តូរជំនាញ ការអនុវត្តល្អបំផុត មេរៀន និងបទពិសោធន៍ទូទាំងតំបន់អាស៊ាន (រវាងស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ាន) ក្នុងការបញ្ជ្រាបយេនឌ័រ និងជំរុញការចូលរួមរបស់ស្ត្រី[68] ក្នុងការកសាង សន្តិភាព និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ ដូចជា ការទប់ស្កាត់អំពើហិង្សាជ្រុលនិយម ការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ការទប់ស្កាត់ការគំរាមកំហែងលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត[69] ការជួញដូរមនុស្ស និងការគំរាមកំហែងផ្សេងទៀតលើសន្តិភាព និងសន្តិសុខដែលកំពុងលេចឡើង។

Continued

64 ចំណុចនេះរួមបញ្ចូលយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ការទប់ស្កាត់/ការប្រយុទ្ធប្រឆាំងអំពើហិង្សាជ្រុលនិយម ការប្រែប្រួលអាកាសធាតុ និងហានិភ័យបរិស្ថាន។

65 ចំណុចនេះបន្សុីគ្នានឹងសូចនាករទី ៨ នៃរបាយការណ៍របស់អគ្គលេខាធិការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

66 ចំណុចនេះបន្សុីគ្នានឹងកម្មវិធីការងាររបស់ AADMER ២០២១-២០២៥ (សូចនាករសមិទ្ធកម្មសំខាន់ៗ ៖ សូចនាករទី ២៦)។

67 ចំណុចនេះបំពេញបន្ថែមលើគោលបំណងនៃផែនការការងាររបស់ ACW (២០២១-២០២៥) និងក្របខណ្ឌតំបន់អាស៊ានស្តីពីការការពារ យេនឌ័រ និងបរិយាបន្នក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ (ទំ. ៥) ដែលចែងពីសារៈសំខាន់នៃការធានាការយល់ពី "ទិដ្ឋភាពយេនឌ័រក្នុងហានិភ័យគ្រោះមហន្តរាយ និងការស្តែងឡើងផ្សេងៗគ្នាដោយផ្អែកតាមយេនឌ័រនៃភាពងាយរងគ្រោះ និងការប្រឈមនឹងការគំរាមកំហែង ក៏ដូចជាតម្រូវការស្តារឡើងវិញផ្សេងៗគ្នាដោយផ្អែកតាមយេនឌ័រ។

68 See for example Plan of Action to Implement the Joint Declaration on Comprehensive Partnership between ASEAN and the United Nations (2021-2025), 1.1.9 and Work Plan of the ASEAN Plan of Action to Prevent and Counter the Rise of Radicalisation and Violent Extremism (2019 - 2025).

69 See, ASEAN Cybersecurity Cooperation Strategy 2021-2025 available at https://asean.org/wp-content/uploads/2022/02/01-ASEAN-Cybersecurity-Cooperation-Paper-2021-2025_final-23-0122.pdf.

| |
|---|
| សកម្មភាពអាទិភាព ៣.១.២ ៖ ធ្វើការស្រាវជ្រាវផ្អែកតាមភស្តុតាងដើម្បីកំណត់រក និងលុបបំបាត់គម្លាតក្នុងការយល់ដឹងពីវិធីដែលសកម្មភាពប្រចាំថ្ងៃរបស់ស្ត្រី និងបុរស (រួមទាំងអ្នកដែលមកពីសហគមន៍ជួបការលំបាក) ធ្វើឱ្យមានភាពតានតឹង និងអសន្តិសុខកាន់តែខ្លាំង ឬ (ផ្ទុយទៅវិញ) កាត់បន្ថយហានិភ័យ និងរិះរកវិធីដែលពួកគេត្រូវបានជំរុញឱ្យចូលរួម និងអាចទទួលបានការគាំទ្រ និងចូលរួមបន្ថែមទៀតក្នុងការទប់ស្កាត់អំពើហិង្សា ជម្លោះ អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងហានិភ័យផ្សេងទៀតចំពោះសន្តិសុខមនុស្ស និងបរិស្ថាន។ |
| សកម្មភាពអាទិភាព ៣.១.៣ ៖ បង្កើនការចូលរួម និងភាពជាដៃគូតាមរយៈការប្រើប្រាស់យន្តការជាក់លាក់ ដូចជា ការពិគ្រោះយោបល់តាមកាលកំណត់ជាប្រចាំ (តាមប្រព័ន្ធឌីជីថល និងមធ្យោបាយផ្សេងទៀត)[70]ស្តីពីសំណើគោលនយោបាយ និងកម្មវិធី (ស្តីពីការទប់ស្កាត់) ជាមួយអ្នកផ្សះផ្សារ និងអ្នកកសាងសន្តិភាពជាស្ត្រី អង្គការសង្គមស៊ីវិល និងអង្គការធ្វើការពាក់ព័ន្ធនឹងស្ត្រី រួមទាំងសហគមន៍សាសនាដែលធ្វើការងារពាក់ព័ន្ធនឹងការទប់ស្កាត់ជម្លោះ ការកសាងសន្តិភាព និងការផ្សះផ្សារក្នុងមូលដ្ឋាន[71] ដើម្បីបង្កើនការយល់ដឹងពីតម្រូវការ និងការយល់ឃើញរបស់ស្ត្រី និងគាំទ្រដល់ការចូលរួម និងការដាក់បញ្ចូលមតិយោបល់របស់ស្ត្រីទៅក្នុងការតាក់តែងគោលនយោបាយស្តីពីការទប់ស្កាត់ជម្លោះ និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ផ្សេងទៀតដែលមានលើកឡើងខាងលើ។ |
| សកម្មភាពអាទិភាព ៣.១.៤ ៖ រៀបចំកិច្ចប្រជុំ ឬការពិគ្រោះយោបល់ជាប្រចាំ[72] ជាមួយសហគមន៍ អាស៊ានសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមរដ្ឋាភិបាល វិស័យសន្តិសុខ អ្នកជំនាញខាងសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល រួមទាំងយុវជន ដើម្បីពិនិត្យឡើងវិញ និងគាំទ្រដល់ការដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងគំនិតផ្តួចផ្តើមរបស់អាស៊ាន និងគំនិតផ្តួចផ្តើមរបស់រដ្ឋជាសមាជិកអាស៊ានដែលពាក់ព័ន្ធនឹងការកសាងសន្តិភាព និងការទប់ស្កាត់ជម្លោះ ក៏ដូចជាគោលនយោបាយ និងកម្មវិធីកាត់បន្ថយហានិភ័យផ្សេងទៀត[73]។ |
| |
| លទ្ធផលរំពឹងទុក ៣.២ ៖ គោលនយោបាយស្តីពីការទប់ស្កាត់ជម្លោះ និងការកាត់បន្ថយហានិភ័យ វិធានការ និងកម្មវិធីនានាផ្អែកលើភស្តុតាង គិតគូរពីបរិបទ និងឆ្លើយតបនឹងយេនឌ័រ។ |
| សកម្មភាពអាទិភាព ៣.២.១ ៖ កំណត់ និងលើកឡើងពីតម្រូវការបណ្តុះបណ្តាល និងតម្រូវការកសាងសមត្ថភាពដើម្បីធានាថា អ្នកឆ្លើយតបបឋមទាំងអស់ ក៏ដូចជាអ្នកតាក់តែងគោលនយោបាយ និងអ្នក អនុវត្តដែលធ្វើការងារពាក់ព័ន្ធនឹងការទប់ស្កាត់ជម្លោះ និងការកាត់បន្ថយហានិភ័យ ត្រូវបានបំពាក់បំប៉នសមត្ថភាពក្នុងការធ្វើអន្តរាគមន៍នានា ដើម្បីបំពេញគោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅពេលមានសញ្ញានៃការព្រួយបារម្ភដំបូងៗ ដើម្បីទប់ស្កាត់ការរីកធំឡើងនៃជម្លោះ និងគ្រោះថ្នាក់បន្ថែមទៀត។ |

Continued ▼

70 យន្តការមួយក្នុងចំណោមយន្តការជាក់លាក់ទាំងនេះសម្រាប់ការពិគ្រោះយោបល់ និងការបង្កើតបណ្តាញ ត្រូវបានស្នើឡើងដោយ ASEAN RPA ដែលជាកិច្ចប្រជុំកំពូល/សន្និសីទអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង។ គំនិតផ្តួចផ្តើមនេះត្រូវបានលើកមកពិភាក្សាលម្អិតក្នុងតារាងទី ៥ ដែលផ្តោតសំខាន់លើការអនុវត្ត។

71 See for example, ASEAN Plan of Action to Prevent and Counter the Rise of Radicalisation and Violent Extremism (2019 - 2025), p. 14. "Nurture the capacity of women and civil society groups to engage in prevention of violent extremism and related response efforts, and ensure allocation of funds for resultant initiatives through training and/or workshop activities."

72 ការបង្កើតសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានលើកឡើងក្នុងរបាយការណ៍អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ តារាងទី ៥ ដែលពាក់ព័ន្ធនឹងការអនុវត្ត ពិភាក្សាលម្អិតពីចំណុចនេះ។ សហគមន៍នេះនឹងចូលរួមក្នុងកិច្ចប្រជុំកំពូល/សន្និសីទអាស៊ានដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង ប៉ុន្តែសកម្មភាពអាទិភាព ៣.១.៤ ក៏អំពាវនាវឱ្យមានបណ្តាញទំនាក់ទំនងកាន់តែ "ជាប់លាប់" ដូចជា កិច្ចប្រជុំបែបនិម្មិតសម្រាប់ការសួរសំណួរ ការចែករំលែកព័ត៌មាន និងការពិភាក្សាស្តីពីភាពជោគជ័យ និងវិធីជម្នះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តផងដែរ។ ព័ត៌មានលម្អិតមានបង្ហាញក្នុងតារាងទី ៥ (ការអនុវត្ត និងការសម្របសម្រួល) និងក្នុងផ្នែកទី ២ (ព័ត៌មានបន្ថែម) នៃឯកសារនេះ។

73 ASEAN Report on WPS, p.2.

| |
|---|
| សកម្មភាពអាទិភាព ៣.២.២ ៖ អនុវត្តកម្មវិធីសាកល្បងថ្មីៗ ដូចជា កម្មវិធី "កំសាន្តក្នុងលក្ខណៈអប់រំ" និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈផ្សេងទៀត និងយុទ្ធសាស្ត្រស្វែងរកមតិគាំទ្រ ដើម្បីធានាថា ស្ត្រី និងបុរសគ្រប់រូបយល់ថា ពួកគេមានភាពអង់អាច និងទទួលបានការគាំទ្រក្នុងការរាយការណ៍ពីការព្រួយបារម្ភ និងហានិភ័យផ្នែកសន្តិសុខទៅអាជ្ញាធរ និងមានសមត្ថភាព[74] ក្នុងការកាត់បន្ថយ និង ដោះស្រាយហានិភ័យទៅតាមសមត្ថកិច្ចផ្ទាល់ខ្លួន និងក្នុងការអនុវត្តប្រចាំថ្ងៃ[75] ទៅតាមភាពសមស្រប។ |
| សកម្មភាពអាទិភាព ៣.២.៣ ៖ ស្រាវជ្រាវ និងវិភាគដើម្បីយល់ពីឧបសគ្គរាំងការចូលរួមពេញលេញរបស់ស្ត្រីក្នុងវិធានការកសាងទំនុកចិត្ត ការទូតដើម្បីការទប់ស្កាត់ ការធ្វើឱ្យមានសន្តិភាព ការដោះស្រាយជម្លោះ និងការកសាងសន្តិភាពក្រោយពេលមានជម្លោះនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលរួមបញ្ចូលការវិភាគអថេរប្រសព្វគ្នា ដូចជា អាយុ ពូជសាសន៍ ជាតិពន្ធ ពិការភាព-ល-។ ដើម្បីធានា បរិយាបន្ន និងការឆ្លើយតបនឹង "តម្រូវការចម្រុះរបស់ស្ត្រីគ្រប់រូប[76]"។ ការវិភាគនេះក៏គួរកំណត់រកកត្តាអំណោយផលផងដែរ ពោលគឺការដឹកនាំរឿងរ៉ាវជោគជ័យ និងករណីនៃការចូលរួមប្រកបដោយប្រសិទ្ធភាព និងអត្ថន័យរបស់ស្ត្រី រួមទាំងស្ត្រីដែលមកពីក្រុមជាតិពន្ធ និងក្រុមសាសនាផ្សេងៗ ក្នុងការរៀបចំផែនការគោលនយោបាយ កម្មវិធី និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ និងបង្កើនសន្តិសុខ។ |
| |
| លទ្ធផលយុទ្ធសាស្ត្រទី ៤ ៖ ស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខ យន្តការ និងដំណើរការនានា ទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រដោយជោគជ័យ |
| សូចនាករលទ្ធផលចុងក្រោយ ៖<br>• ចំនួនស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ដូចជា កងកម្លាំងប៉ូលិសក្នុងមូលដ្ឋាន ក្រុមឆ្លើយតបនឹងគ្រោះមហន្តរាយ) ដែលពិនិត្យតាមដាន និង ចងក្រងឯកសារស្តីពីករណីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រដែលបាន រាយការណ៍[77]។<br>• ចំនួនគំនិតផ្តួចផ្តើមនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធនឹងស្ថាប័ន សន្តិភាព និងស្ថាប័នសន្តិសុខ និងដំណើរការដែលផ្តោតលើការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រក្នុងស្ថានភាពមានជម្លោះ និង ស្ថានភាពសង្គ្រោះបន្ទាន់<br>• ចំនួនស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខដែលមានយន្តការជូនដំណឹងជាមុន ពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងគោលការណ៍ណែនាំច្បាស់លាស់ និងអាចចាត់វិធានការបានសម្រាប់អន្តរាគមន៍ដំបូងៗ និងកៀរគរការឆ្លើយតបនឹងសញ្ញាព្រមានដំបូងៗ។ |

Continued ▼

74 ចំណុចនេះបំពេញបន្ថែមលើផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (ទំ. ១៧) ដែលអំពាវនាវឱ្យមានការបង្កើត និងចែកចាយ "ព័ត៌មាន និងឯកសារតស៊ូមតិ ដែលសរសេរជាភាសាក្នុងស្រុក...ស្តីពីរបៀបរាយការណ៍ករណី និងលទ្ធភាពទទួលបាន...យុត្តិធម៌ និងសេវាផ្សេងទៀត។ ឯកសារទាំងនេះគួរមានគោលបំណងកាត់បន្ថយការមាក់ងាយជនរងគ្រោះ លុបបំបាត់ការទទួលយកអំពើហិង្សាលើស្ត្រី និងផ្សព្វផ្សាយពីរឿងរ៉ាវវិជ្ជមាន និងរឿងរ៉ាវបង្កើនភាពអង់អាចរបស់ស្ត្រី និងបុរសដែលជាភ្នាក់ងារនៃការផ្លាស់ប្តូរ"។

75 សកម្មភាពអាទិភាពនេះគាំទ្រដល់ផែនការការងាររបស់គណៈកម្មាធិការស្ត្រីអាស៊ាន ២០២១-២០២៥ (២០២១) ដែលកំណត់យកភាពធន់នឹងអាកាសធាតុ និងគ្រោះមហន្តរាយដែលឆ្លើយតបនឹងយេនឌ័រ ជាចំណុចអាទិភាព ក្រោមចក្ខុវិស័យ ៖ "ក្នុងឆ្នាំ ២០២៥ បង្កើនភាពធន់របស់ស្ត្រី និងក្មេងស្រីក្នុងការដោះស្រាយ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ច ដោយសារការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លង ពង្រឹងទីភ្នាក់ងាររបស់ពួកគេក្នុងការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងចូលរួមក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ការឆ្លើយតប និងការស្តារឡើងវិញ"។

76 ASEAN Regional Plan of Action on the Elimination of Violence against Women (ASEAN RPA on EVAW), p.20

77 ការចងក្រងឯកសារ និងការតាមដានការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ គឺជាកិច្ចការលំបាក។ សូចនាករនេះមានគោលបំណងលើកកម្ពស់ការបង្កើតយន្តការប្រមូលទិន្នន័យប្រកបដោយក្រមសីលធម៌ (គិតគូរពីភាពឯកជន និងការព្រួយបារម្ភផ្នែកសន្តិសុខ) ដើម្បីកសាងសមត្ថភាពក្នុងការតាមដានការរាយការណ៍ពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ។ តាមពិត អន្តរាគមន៍ទប់ស្កាត់អាចទទួលបានជោគជ័យសូម្បីតែនៅពេលដែលអត្រានៃការរាយការណ៍ពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ មានការកើនឡើង (ឧ. ប្រសិនបើមានការយល់ដឹងកាន់តែច្រើនពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងឱកាសសម្រាប់ការរាយការណ៍ដោយសុវត្ថិភាព)។ ដូច្នេះ ការរាយការណ៍ពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រតែម្យ៉ាង មិនមែនជារង្វាស់គ្រប់គ្រាន់ ឬត្រឹមត្រូវលើប្រសិទ្ធភាពនៃអន្តរាគមន៍ទប់ស្កាត់នោះទេ។ គួររិះរកមធ្យោបាយបន្ថែមទៀត (បែបបរិមាណ និងគុណភាព) សម្រាប់ការតាមដានប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមទប់ស្កាត់ និងលើកកម្ពស់ការរៀនសូត្រ និងការកែសម្រួលដោយផ្អែកតាមភស្តុតាង។ មធ្យោបាយផ្សេងទៀតរួមមានការប្រើប្រាស់ការសាកល្បងត្រួតពិនិត្យដោយចៃដន្យ និងបច្ចេកទេស "ផ្គូរផ្គង" ស្ថិតិ (តាមដែលអាចធ្វើទៅបាន) ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់នៃគំនិតផ្តួចផ្តើមទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ (ការសម្រួលដល់ការប្រៀបធៀបរវាងក្រុមដែលស្ថិតក្រោមសកម្មភាពទប់ស្កាត់ និងក្រុមដែលពុំបានទទួលអន្តរាគមន៍)។

| |
|---|
| លទ្ធផលរំពឹងទុក ៤.១ ៖ កំណត់មធ្យោបាយ យន្តការ និងស្រាវជ្រាវ (និងមានប្រព័ន្ធសម្រាប់ការធ្វើបច្ចុប្បន្នភាពទិន្នន័យ) ដើម្បីស្វែងយល់ និងកំណត់រកសញ្ញាព្រមានដំបូងៗ និងឫសគល់នៃអំពើហិង្សា[78]ជាពិសេសអំពើហិង្សាផ្លូវភេទពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងសហគមន៍ និងបរិបទផ្សេងៗ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការធ្វើអន្តរាគមន៍ផ្អែកតាមគោលដៅដែលឆ្លើយតបនឹងយេនឌ័រ សម្រាប់ការដោះស្រាយឫសគល់ទាំងនេះ[79] និងទប់ស្កាត់អំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ ដែលពាក់ព័ន្ធនឹងយេនឌ័រ។ |
| សកម្មភាពអាទិភាព ៤.១.១ ៖ ពិនិត្យឡើងវិញលើគោលនយោបាយ និងច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដើម្បីធានាថា គោលនយោបាយ និងច្បាប់ទាំងនោះគាំទ្រដល់ការធ្វើអន្តរាគមន៍ដែលមានប្រសិទ្ធភាពនៅពេលមានសញ្ញាព្រមានដំបូងៗពីការកើតមានអំពើហិង្សា និងក្នុងការឆ្លើយតបនឹងបទល្មើសដំបូងៗ។ ជំរុញឱ្យមានអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ កាត់បន្ថយនិទណ្ឌភាពសម្រាប់បទល្មើសអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ប្រឆាំងការបណ្តែតបណ្តោយឱ្យមានអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងប្រឆាំងការរើសអើង និងការមាក់ងាយ[80]។ |
| សកម្មភាពអាទិភាព ៤.១.២ ៖ ធានាថាអ្នកដែលធ្វើការងារជួរមុខក្នុងវិស័យសន្តិភាព និងសន្តិសុខ (ដូចជា ប៉ូលិស យោធា បុគ្គលិកសង្គមកិច្ច អ្នកឆ្លើយតបសង្គ្រោះបន្ទាន់) មានសមត្ថភាពក្នុងការកំណត់រកសញ្ញាព្រមានដំបូងៗ រួមទាំងអ្នកដែលធ្វើការ និងរស់នៅក្នុងសហគមន៍មូលដ្ឋាន និងបញ្ជូនករណីនៃការព្រួយបារម្ភ ដើម្បីឱ្យស្ត្រី បុរស កុមារ គ្រួសារ និងអ្នកដែលមកពីក្រុមងាយរងគ្រោះ បានទទួលការគាំទ្រជារួម និងពីវិស័យចម្រុះ ដែលពួកគេត្រូវការ ដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ[81]។ |
| |
| លទ្ធផលរំពឹងទុក ៤.២ ៖ អ្នកឆ្លើយតបបឋម ក៏ដូចជាអ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្ត មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានទិន្នន័យ និងការបណ្តុះបណ្តាលដែលពួកគេត្រូវការដើម្បីធានាថា ស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខ អាចទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដោយមានការគាំទ្រពីសកម្មភាពរបស់ស្ថាប័នពហុវិស័យ គោលនយោបាយ និងបរិយាកាសគតិយុត្តិ ដោយផ្អែកតាមគោលការណ៍ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| សកម្មភាពអាទិភាព ៤.២.១ ៖ បង្កើនការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់ស្ថាប័ន សន្តិភាព និងស្ថាប័នសន្តិសុខ ដូចជា ប្រព័ន្ធតុលាការ ចៅក្រម ប៉ូលិស យោធា និងអ្នកឆ្លើយតបបឋមផ្សេងទៀតស្តីពីសញ្ញាព្រមានដំបូងៗ និងការធ្វើអន្តរាគមន៍ដែលអាច និងគួរធ្វើឡើងដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ទាំងក្នុងពេលមានសន្តិភាព និងក្នុងពេលមានជម្លោះ និងការឆ្លើយតបសង្គ្រោះបន្ទាន់ (ដូចជា ការប្រើប្រាស់ផ្ទះសុវត្ថិភាព ការពង្រឹងការអនុវត្តដីកាហាមឃាត់ បណ្តោះអាសន្ន ការបញ្ជូនទៅរកការប្រឹក្សាយោបល់ និងការគាំទ្រ/ការបណ្តុះបណ្តាលផ្នែកសង្គម និងផ្លូវចិត្ត ដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សាលើស្ត្រី)។ |
| សកម្មភាពអាទិភាព ៤.២.២ ៖ លើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសដើម្បីផ្លាស់ប្តូរជំនាញ ការអនុវត្តល្អបំផុត និងមេរៀនទូទាំងតំបន់អាស៊ាន ស្តីពីការបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពសម្រាប់ការទប់ស្កាត់អំពើហិង្សាផ្លូវភេទ ពាក់ព័ន្ធនឹងយេនឌ័រ កំណែទម្រង់ច្បាប់ និងគោលនយោបាយ និងសេវាគាំទ្រផ្សេងទៀតដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ ពាក់ព័ន្ធនឹងយេនឌ័រ។ កំណត់រកឱកាសពង្រីកកម្មវិធីដែលទទួលបានជោគជ័យ និងបង្កើនវិសាលភាពទូទាំងតំបន់ (ក្នុងករណីសមស្រប) និងបង្កើនការសម្របសម្រួល និងកម្លាំងផ្លូវបរវាងគំនិតផ្តួចផ្តើមពាក់ព័ន្ធក្នុងតំបន់ ដូចជា បណ្តាញអ្នកកសាងសន្តិភាព ដើម្បីធានាដាក់បញ្ចូលទៅក្នុងការងារបង្ការ ទប់ស្កាត់។ |

Continued ▼

78 ឧ. បទដ្ឋានយេនឌ័រ និងការអនុវត្តដែលបង្កគ្រោះថ្នាក់ កត្តាសេដ្ឋកិច្ចសង្គម (ឧ. វិសមភាពយេនឌ័រក្នុងសិទ្ធិដីធ្លី) និងការផាត់ចេញពីសង្គម (ឧ. កង្វះ ឬការបដិសេធមិនផ្តល់ធនធាន សិទ្ធិ ឱកាស ចល័តភាព សេវា។ល។)។

79 ASEAN Regional Plan of Action on the Elimination of Violence against Women (ASEAN RPA on EVAW), p.16.

80 សូមមើល ឧ. ផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (ទំ. ១៧)។ វាជាការសំខាន់ដែលត្រូវធានាថា ការរៀបចំ ការអនុវត្ត និងការពិនិត្យគោលនយោបាយ និងច្បាប់ ផ្អែកលើភស្តុតាង បរិបទ និងគិតគូរពីវប្បធម៌ ដើម្បីធានាការតស៊ូមតិឱ្យមានការផ្លាស់ប្តូរបទដ្ឋានសង្គមវិជ្ជមានឆ្ពោះទៅរកទំនាក់ទំនងបែបអហិង្សា និងប្រកបដោយការគោរព។ អាចលើកឡើងពីចំណុចនេះបន្ថែមទៀតនៅថ្នាក់ជាតិ។

81 ASEAN Regional Plan of Action on the Elimination of Violence against Women (ASEAN RPA on EVAW), p.13-4.

សកម្មភាពអាទិភាព ៤.២.៣ ៖ ពិនិត្យឡើងវិញលើការរៀបចំក្នុងស្ថាប័ននាពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹង ហេដ្ឋារចនាសម្ព័ន្ធយោធា/កងរក្សាសន្តិភាព ក៏ដូចជារចនាសម្ព័ន្ធដែលគេប្រើប្រាស់ក្នុងការឆ្លើយតបផ្នែកមនុស្សធម៌ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ដូចជា ជម្រក មជ្ឈមណ្ឌល និងជំរំជម្លៀស ដើម្បីបង្កើតចន្លោះសុវត្ថិភាព និងធានាថា រចនាសម្ព័ន្ធទាំងនោះប្រមូលធាតុចូល និងឆ្លើយតបនឹងការព្រួយបារម្ភរបស់អ្នកដែលកំពុងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ គិតគូរពីយេនឌ័រ និងទប់ស្កាត់អសន្តិសុខ និងអំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ (ចំណុចនេះរួមបញ្ចូលការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ ភ្លើងបំភ្លឺ ការកំណត់ពេលវេលា និងទីតាំងដែលមានការរក្សាសន្តិសុខ និងការចុះល្បាត សុវត្ថិភាពក្នុងការទទួលបានទឹក និងឥន្ធនៈ (ជាញឹកញាប់ ស្ត្រីជាអ្នកស្វែងរកធនធានទាំងនេះ) ទីតាំងអនាម័យអន្តេវាសិកដ្ឋានសម្រាប់បុរស និងអន្តេវាសិកដ្ឋានសម្រាប់ស្ត្រី ការពិចារណាពីឯកជនភាពជាដើម)។

សកម្មភាពអាទិភាព ៤.២.៤ ៖ បង្កើតមធ្យោបាយប្រមូលទិន្នន័យដែលងាយស្រួលប្រើប្រាស់ និងប្រកបដោយក្រមសីលធម៌ ដើម្បីប្រមូលទិន្នន័យដើមគ្រា (បែងចែកតាមភេទ អាយុ និងអថេរផ្សេងទៀត) ក៏ដូចជាទិន្នន័យក្រោយ "អន្តរាគមន៍" (ក្រោយការអនុវត្តគោលនយោបាយ/អន្តរាគមន៍កម្មវិធី) ស្តីពីអត្រានៃឧប្បត្តិហេតុអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ និងរង្វាស់ផ្សេងទៀតដែលពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ដោយផ្អែកលើការអនុវត្តល្អបំផុតក្នុងការពិនិត្យតាមដាន ការប្រមូល និងការវិភាគទិន្នន័យ។

សកម្មភាពអាទិភាព ៤.២.៥ ៖ ពិនិត្យឡើងវិញលើច្បាប់ បទដ្ឋាន និងវិធានការក្នុងស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខ ដូចជាសេវាប៉ូលិស និងយោធា សម្រាប់ការរាយការណ៍ពីការព្រួយបារម្ភដែលពាក់ព័ន្ធនឹងទំនាក់ទំនងយេនឌ័រដែលបង្កជាបញ្ហា សញ្ញានៃការព្រួយបារម្ភដំបូងៗ និងសញ្ញាព្រមានពីការកើតមានអំពើហិង្សាផ្លូវភេទ ពាក់ព័ន្ធនឹងយេនឌ័រ ទាំងនៅក្នុងស្ថាប័នទាំងនេះ ដែលពាក់ព័ន្ធនឹងការងាររបស់ស្ថាប័នទាំងនេះជាមួយសហគមន៍តាមមូលដ្ឋាន ដៃគូ និងជនស៊ីវិលនៅក្រៅស្ថាប័នទាំងនេះ។ ចំណុចនេះរួមមានការពិចារណាពីនីតិវិធីនៃការរាយការណ៍នៅក្នុងខ្សែសង្វាក់នៃការបញ្ជា និងឱកាសសម្រាប់ការរាយការណ៍នៅក្រៅខ្សែសង្វាក់នៃការបញ្ជា។

សកម្មភាពអាទិភាព ៤.២.៦ ៖ កែប្រែនីតិវិធីសម្រាប់ការស៊ើបអង្កេត និងការឆ្លើយតបនឹងករណីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ក្នុងករណីចាំបាច់ (ផ្អែកលើការពិនិត្យឡើងវិញ និងការសិក្សាពីការអនុវត្តល្អបំផុតជាអន្តរជាតិ ដូចការគូសបញ្ជាក់ក្នុងសកម្មភាពអាទិភាព ៤.២.៥ ខាងលើ)។ ធានាថា វិធានការផ្លូវច្បាប់ និងវិធានការគោលនយោបាយ ការពារសិទ្ធិ និងឯកជនភាពរបស់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធនិងបង្កើតគ្រឿងលើកទឹកចិត្តសម្រាប់ការរាយការណ៍ដែលបន្សុីគ្នានឹងយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ឧ. ផ្តល់ការគាំទ្រ ជាជាងដាក់ទណ្ឌកម្មលើអ្នកដែលរាយការណ៍ពីការបៀតបៀន)។

សកម្មភាពអាទិភាព ៤.២.៧ ៖ កំណត់រកកំណែទម្រង់ច្បាប់ និងកំណែទម្រង់គោលនយោបាយ ក៏ដូចជាសកម្មភាពកសាងសមត្ថភាពដែលត្រូវការចាំបាច់ ដើម្បីធានាថា ស្ថាប័នសន្តិភាព និងស្ថាប័នសន្តិសុខ (ទាំងក្នុងបរិបទនៃប្រតិបត្តិការកសាងសន្តិភាព និងប្រតិបត្តិការរក្សាសន្តិភាព) អាចទប់ស្កាត់អំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត ប្រឆាំងការសាបព្រួសគំនិតស្អប់ខ្ពើមស្ត្រី[82]តាមប្រព័ន្ធអ៊ីនធឺណិត និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ការរករឿងរំខាន និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសការរករឿងរំខាន និងការបៀតបៀនស្ត្រី កុមារ និងអ្នកដទៃទៀតដែលអាចនឹងក្លាយជាគោលដៅ[83]។

សកម្មភាពអាទិភាព ៤.២.៨ ៖ គាំទ្រដល់ការបង្កើតគោលការណ៍ណែនាំសមស្របក្នុងមូលដ្ឋានដែលប្រើប្រាស់ភាសា និងទម្រង់ដែលផ្តល់ភាពងាយស្រួល (អាចបង្ហាញតាមបែបនិម្មិតបានផងដែរ) និងការកសាងសមត្ថភាពក្រោមភាពជាដៃគូជាមួយអ្នកផ្តល់ប្រឹក្សា អ្នកជំនាញផ្នែកអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ អង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន និងស្ថាប័នអនុវត្តច្បាប់ក្នុងមូលដ្ឋានស្តីពី "សញ្ញាព្រមានដំបូងៗពីការកើតមានអំពើហិង្សាផ្លូវភេទ ពាក់ព័ន្ធនឹងយេនឌ័រ ៖ អ្វីដែលត្រូវពិនិត្យរក និងរបៀបឆ្លើយតប" ក៏ដូចជាសន្លឹកព័ត៌មានស្តីពី "អ្វីដែលត្រូវធ្វើប្រសិនបើអ្នកទទួលរង ឬមើលឃើញអំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ឬមានការព្រួយបារម្ភពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ" ដោយប្រើប្រាស់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ សម្រាប់អ្នកដឹកនាំសាសនា និងក្រុមសាសនា អ្នកដឹកនាំសហគមន៍បែបប្រពៃណី និងអ្នកដឹកនាំសហគមន៍ផ្សេងទៀត អង្គការសង្គមស៊ីវិល គ្រូបង្រៀន/អ្នកគ្រប់គ្រងសាលារៀន កងកម្លាំងសន្តិសុខ ប៉ូលិស មន្ត្រីអនុវត្តច្បាប់ និងស្ថាប័នយុត្តិធម៌ ក៏ដូចជាអ្នកដែលធ្វើការងារជួរមុខក្នុងការឆ្លើយតបនឹងវិបត្តិ/ការឆ្លើយតបផ្នែកមនុស្សធម៌/ការឆ្លើយតបសង្គ្រោះបន្ទាន់។

82 គំនិតស្អប់ស្ត្រីសំដៅលើការមិនចូលចិត្ត ការស្អប់ខ្ពើមស្ត្រី និង/ឬមានភាពលម្អៀងខ្លាំងចំពោះស្ត្រី។

83 ចំណុចនេះបំពេញបន្ថែមលើសកម្មភាពដែលមានចែងក្នុងភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងអង្គការសហប្រជាជាតិ (២០២១-២០២៥) ទំ. ២៣។

## តារាងស្តីពីការសង្គ្រោះ និងស្តារឡើងវិញ

លទ្ធផលយុទ្ធសាស្ត្រទី ៥ ៖ បំពេញតម្រូវការរបស់ស្ត្រី និងក្មេងស្រី[84]ក្នុងដំណើរការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយស្ត្រីបានចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យក្នុងដំណើរការទាំងនេះ រួមទាំងក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងមុខតំណែងដឹកនាំ

សូចនាករលទ្ធផលចុងក្រោយ ៖

- ចំនួន/សមាមាត្រនៃគំនិតផ្តួចផ្តើមសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងគំនិតផ្តួចផ្តើមកាត់បន្ថយភាពងាយរងគ្រោះក្នុងពេលមានវិបត្តិដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលលើកឡើងពីតម្រូវការរបស់ស្ត្រី និងក្មេងស្រី ក៏ដូចជាអ្នកដែលមកពីក្រុមងាយរងគ្រោះ និងលើកកម្ពស់សមភាពយេនឌ័រ។
- ចំនួន និងសមាមាត្ររបស់ស្ត្រី បុរស និងអ្នកដែលមកពីក្រុមជួបការលំបាក ដែលចូលរួមក្នុងគោលនយោបាយ និងការរៀបចំផែនការគំនិតផ្តួចផ្តើមសង្គ្រោះនិងស្តារឡើងវិញ នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងមុខតំណែងដឹកនាំ។
- ចំនួនរដ្ឋជាសមាជិកអាស៊ានដែលរាយការណ៍ពីចំណុចដៅ ១ ឬច្រើននៃក្របខណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ[85] ដោយប្រើប្រាស់ទិន្នន័យបែងចែកតាមភេទ។
- ចំនួន និងសមាមាត្រនៃកម្មវិធីសង្គ្រោះ និងស្តារឡើងវិញ រួមទាំងការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់ដែលប្រមូល និងប្រើប្រាស់ទិន្នន័យបែងចែកជាប្រភេទ (ឧ. បែងចែកតាមភេទ អាយុ ពិការភាព និងអថេរផ្សេងទៀត[86]) ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំផែនការ និងការអនុវត្ត។

លទ្ធផលរំពឹងទុក ៥.១ ៖ ការបង្កើត និងអនុវត្តគោលនយោបាយរបស់អាស៊ាន ផ្អែកតាមបទពិសោធន៍ និងអាទិភាពរបស់ស្ត្រី នៅដំណាក់កាលសង្គ្រោះ និងស្តារឡើងវិញ ដូចជា នៅកម្រិតសហគមន៍។

សកម្មភាពអាទិភាព ៥.១.១ ៖ កំណត់រកមធ្យោបាយ និងឧបករណ៍ជាក់លាក់[87] (ដូចជា តារាងត្រួតពិនិត្យការវិភាគផ្អែកតាមយេនឌ័រ និងការស្ទង់មតិដែលគិតគូរពីយេនឌ័រ) សម្រាប់ការស្វែងយល់ពីតម្រូវការរបស់ស្ត្រី និងក្មេងស្រីក្នុងស្ថានភាពក្រោយពេលជម្លោះ និងស្ថានភាពក្រោយការសង្គ្រោះបន្ទាន់ និងធានាការ បណ្តុះបណ្តាល[88] អ្នកឆ្លើយតបបឋម ស្តីពីការប្រើប្រាស់មធ្យោបាយប្រមូលទិន្នន័យដែលគិតគូរពីយេនឌ័រ និងប្រកបដោយក្រមសីលធម៌[89]។

Continued

84 ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាមគ្គុទេសក៍សម្រាប់គោលនយោបាយ និងសកម្មភាពកម្មវិធី ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងក្មេងស្រីទាំងអស់ ក្នុងគោលបំណងសម្រេចចក្ខុវិស័យអាស៊ាននៃការធានា "ឱកាសសម្រាប់ប្រជាជនទាំងអស់" និង "មិនទុកនរណាម្នាក់ចោល"។ ជារួម ឯកសារនេះមិនលើកឡើងពីអថេរដែលបង្ហាញពីគោលជំហរផ្សេងៗរបស់ស្ត្រី និងក្មេងស្រី ពាក់ព័ន្ធនឹងជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយឡើយ (និងឱកាស និងបញ្ហាប្រឈមទាំងអស់ដែលពាក់ព័ន្ធនឹងអថេរទាំងនេះ) ដូចជា ពិការភាព ពូជសាសន៍ វណ្ណៈ ជាតិពន្ធុ យេនឌ័រ សាសនា អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពជាជនជាតិដើមភាគតិច និងស្ថានភាពទេសន្តរប្រវេសន៍។ ទោះជាយ៉ាងណា គួរបង្កើត និងអនុវត្តសកម្មភាពអាទិភាពនីមួយៗដើម្បីស្វែងយល់ និងឆ្លើយតបនឹងសមត្ថភាព និងតម្រូវការចម្រុះរបស់ស្ត្រី និងក្មេងស្រីគ្រប់រូប និងលើកកម្ពស់ការចូលរួម និងការដាក់បញ្ចូលស្ត្រី និងក្មេងស្រីឱ្យបានពេញលេញទៅក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅគ្រប់ដំណាក់កាលទាំងអស់។

85 ជាពិសេស អាទិភាពទី ៤ "ការបង្កើនការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយដើម្បីធានាការឆ្លើយតបដែលមានប្រសិទ្ធភាព និង "ស្ថាបនាឡើងវិញឱ្យកាន់តែប្រសើរ" ក្នុងការស្តារឡើងវិញ ការស្តារលទ្ធភាពពលកម្ម និងការស្ថាបនាឡើងវិញ។

86 ចំណុចនេះគួររួមបញ្ចូលការប្រមូលទិន្នន័យពីក្រុមងាយរងគ្រោះ ប្រកបដោយក្រមសីលធម៌។

87 ASEAN Comprehensive Recovery Framework and Implementation Plan (2020).

88 Included in "Capacity Building" (2.2 Framework of Target Actions) of the ASEAN Regional Framework on Protection, Gender and Inclusion in Disaster Management 2021-2025.

89 ASEAN Comprehensive Recovery Framework and Implementation Plan, p.19.

| |
|---|
| សកម្មភាពអាទិភាព ៥.១.២ ៖ តាមរយៈយន្តការ គោលការណ៍ណែនាំ និងឧបករណ៍ជាក់លាក់ សម្របសម្រួលការពិគ្រោះយោបល់ជាប្រចាំ និងបែបបរិយាបន្ន ជាមួយស្ត្រីមានពិការភាព[90] ក៏ដូចជាយុវជន ចាស់ជរា និងអ្នកផ្សេងទៀតដែលអាចមានអាទិភាព ឬតម្រូវការមួយចំនួន ដើម្បីធានាការចូលរួម និងការដាក់បញ្ចូលពួកគេក្នុងដំណើរការ និងគោលនយោបាយស្តីពីការសង្គ្រោះ និងស្តារឡើងវិញ[91]។ |
| សកម្មភាពអាទិភាព ៥.១.៣ ៖ រិះរកវិធីស្តារនីតិសម្បទា និងធ្វើសមាហរណកម្មឡើងវិញសម្រាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធជាមួយភាគីក្នុងជម្លោះ និងធានាការពិចារណាពីតម្រូវការជាក់លាក់របស់ពួកគេក្នុងដំណើរការដកអាវុធ រំសាយកងទ័ព និងសមាហរណកម្ម ទាំងក្នុងតំបន់អាស៊ាន (ក្នុងករណីពាក់ព័ន្ធ) និងក្នុងពេលដាក់ពង្រាយកងកម្លាំងរក្សាសន្តិភាពនៅក្រៅតំបន់អាស៊ាន។ |
| សកម្មភាពអាទិភាព ៥.១.៤ ៖ ប្រមូលទិន្នន័យបែងចែកតាមភេទ[92] (ទាំងទិន្នន័យដើមគ្រា និងទិន្នន័យក្រោយការធ្វើអន្តរាគមន៍គោលនយោបាយ/កម្មវិធី ទាំងបែបបរិមាណ និងបែបគុណភាព) ដើម្បីយល់ពីប្រសិទ្ធភាពនៃអន្តរាគមន៍ គាំទ្រដល់ការទទួលខុសត្រូវលើលទ្ធផល និងធានាថា គោលនយោបាយ និងកម្មវិធីនានាផ្អែកលើភស្តុតាង និងត្រៀមខ្លួនកែសម្រួលទៅតាមការប្រែប្រួលតម្រូវការ និងស្ថានការណ៍សម្រាប់ស្ត្រី និងបុរស ក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ។ |
| |
| លទ្ធផលរំពឹងទុក ៥.២ ៖ គោលនយោបាយ និងដំណើរការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ត្រូវបានបង្កើតឡើង និងអនុវត្តតាមរយៈដំណើរការពហុវិស័យ ពហុភាគី និងពហុកម្រិត ដោយផ្អែកលើបណ្តាញ និងភាពជាដៃគូ[93] ដើម្បីធានាសង្គតិភាពក្នុងសង្គម បរិយាបន្ន និងការចូលរួមដោយភាគីពាក់ព័ន្ធសំខាន់ៗ។ |
| សកម្មភាពអាទិភាព ៥.២.១ ៖ បង្កើតនិងធានាយន្តការសម្របសម្រួលរវាងស្ថាប័នតាមវិស័យ គណៈកម្មាធិការ មជ្ឈមណ្ឌល និងអង្គភាពផ្សេងៗរបស់អាស៊ាន ក្នុងដំណាក់កាលសង្គ្រោះ និងស្តារឡើងវិញ ដើម្បីអាចបំពេញតម្រូវការផ្សេងៗក្នុងផ្នែកសន្តិសុខ និងសម្រេចបានរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈសកម្មភាពដែលមានការសម្របសម្រួលដែលផ្អែកលើភាពជាដៃគូ និងកម្លាំងផ្គួប[94]។ |
| សកម្មភាពអាទិភាព ៥.២.២ ៖ ផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើភាព និងពេញលេញព្រមទាំងបង្កើត និងពង្រឹងភាពជាដៃគូនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងថ្នាក់សហគមន៍[95]។ បណ្តាញដើម្បីស្ត្រី សន្តិភាព និងសន្តិសុខទាំងនេះ[96] អាចផ្តល់ទិន្នន័យ និងចំណេះដឹង ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងជំនួយជាក់ស្តែងក្នុងការកំណត់អាទិភាព និងបង្កើតគំនិតផ្តួចផ្តើមដើម្បីលើកឡើងពីសសរស្តម្ភ ទាំងអស់នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ការការពារ ការទប់ស្កាត់ ការចូលរួម) ក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ។ |
| |

Continued

90 ASEAN Enabling Masterplan 2021– 2025: Mainstreaming the Rights of Persons with Disabilities (2018) and the Sendai Framework for Disaster Risk Reduction.

91 សម្រាប់ការពិភាក្សាបន្ថែមស្តីពីឧបករណ៍ និងគោលការណ៍ណែនាំជាក់លាក់ដើម្បីធានាការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រី និងក្មេងស្រី សូមមើលសកម្មភាពអាទិភាពក្នុងតារាងស្តីពី "ការចូលរួម"។

92 សូមមើល ឧ. Plan of Action to Implement the Joint Declaration on Comprehensive Partnership between ASEAN and the United Nations (2021-2025), 1.1.17, 3.6.1, and 4.3.6, and the ASEAN Report on WPS, p.9, ASEAN Gender Mainstreaming Strategic Framework, Outcome 2.2.

93 ចំណុចនេះបំពេញបន្ថែមលើគោលដៅនៃក្របខណ្ឌតំបន់អាស៊ានស្តីពីការការពារ យេនឌ័រ និងបរិយាបន្នក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ (២០២១-២០២៥) ដែលអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ "បញ្ជ្រាបក្នុងស្ថាប័ននូវការដឹកនាំរបស់ស្ត្រី កុមារ យុវជន ចាស់ជរា ជនក្រីក្រ និងជនមានពិការភាពក្នុងការត្រៀមខ្លួនទប់ទល់ ការឆ្លើយតប និងការស្តារឡើងវិញពីគ្រោះមហន្តរាយ និងលើកកម្ពស់ការចូលរួមពេញលេញ និងស្មើភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត" (១២)។

94 គំនិតសំខាន់គឺការពង្រឹងភាពពាក់ព័ន្ធទូទាំងគោលបំណងប្រទាក់ក្រឡាគ្នាដែលដើរតួនាទីសំខាន់ក្នុងការសង្គ្រោះ និងស្តារឡើងវិញ ដូចជា ការផ្តល់ជំនួយមនុស្សធម៌បន្ទាន់ទន្ទឹមនឹងការធានាភាពម្ចាស់ការក្នុងមូលដ្ឋានលើគំនិតផ្តួចផ្តើមសមភាពយេនឌ័រ និងការគាំទ្រដល់ការស្តាបនាឡើងវិញដែលក្នុងពេលតែមួយកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ របាយការណ៍អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខស្នើឱ្យមានការបង្កើតសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមរដ្ឋាភិបាល វិស័យសន្តិសុខ អ្នកជំនាញផ្នែកសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខឱ្យបានទូលំទូលាយ និងពហុវិស័យ។

95 របាយការណ៍អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ស្នើឱ្យមានការបង្កើតសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមរដ្ឋាភិបាល វិស័យសន្តិសុខ អ្នកជំនាញផ្នែកសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់ការអនុវត្តស្តីពីស្ត្រី សន្តិភាព និងសន្តិសុខឱ្យបានទូលំទូលាយ និងពហុវិស័យ។

96 ដូចជា អង្គការស្ត្រី សង្គមស៊ីវិល ក្រុមសាសនា ស្ថាប័នសិក្សាស្រាវជ្រាវ និងវិស័យឯកជន។

| |
|---|
| លទ្ធផលរំពឹងទុក ៥.៣ ៖ គោលនយោបាយ និងគំនិតផ្តួចផ្តើមស្តីពីការសង្គ្រោះ និងស្តារឡើងវិញ ឆ្លើយតបនឹងយេនឌ័រ និងគិតគូរពីបរិបទ ដោយមានការលើកឡើងពីតម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរស ហើយសិទ្ធិរបស់ពួកគេត្រូវបានការពារ (រួមទាំងសិទ្ធិរបស់អ្នកដែលមកពីក្រុមងាយរងគ្រោះ)។ |
| សកម្មភាពអាទិភាព ៥.៣.១ ៖ ចូលរួមក្នុងគំនិតផ្តួចផ្តើមជាក់លាក់ដើម្បីបំពេញតម្រូវការ[97]របស់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ ទប់ស្កាត់ការមាក់ងាយ និងធានាថា ជនរងគ្រោះ ដោយសារអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ (ដូចជា ស្ត្រីវ័យក្មេង និងក្មេងស្រី) មិនត្រូវបានធ្វើឱ្យរងគ្រោះជាថ្មី ឬត្រូវបានផាត់ចេញ។ |
| សកម្មភាពអាទិភាព ៥.៣.២ ៖ កំណត់រកហានិភ័យ និងចាត់វិធានការទប់ស្កាត់ការជួញដូរមនុស្ស និងគាំទ្រដល់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវាគាំទ្រដែលត្រូវការចាំបាច់[98] ក្នុងពេលអនុវត្តគំនិតផ្តួចផ្តើមសង្គ្រោះ និង ស្តារឡើងវិញ។ |
| សកម្មភាពអាទិភាព ៥.៣.៣ ៖ លើកកម្ពស់គំនិតផ្តួចផ្តើមដែលផ្អែកតាមភស្តុតាង និងផ្តោតលើការឆ្លើយតបនឹងតម្រូវការដែលប្រែប្រួលឥតឈប់ឈរ ដូចជាការកំណត់ដោយទិន្នន័យ និងភស្តុតាងដែលប្រមូលបានពីសហគមន៍ និងភាពជាដៃគូផ្សេងទៀតដែលមានរៀបរាប់ខាងលើ (លទ្ធផលរំពឹងទុក ៥.១) និងផ្អែកលើបទពិសោធន៍ និងអាទិភាពរបស់ស្ត្រី ក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ។ |
| សកម្មភាពអាទិភាព ៥.៣.៤ ៖ អនុវត្តកម្មវិធីដែលពិចារណាពីតម្រូវការរបស់អ្នកថែទាំ និងអ្នកធ្វើកិច្ចការផ្ទះសម្បែងដែលមិនទទួលបានប្រាក់ឈ្នួលក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ និងលើកកម្ពស់សមភាពយេនឌ័រដែលពាក់ព័ន្ធនឹងភារៈថែទាំ (ឧ. រៀបចំកម្មវិធីដែលរួមបញ្ចូលទាំងឪពុក និងម្តាយ និងគាំទ្រដល់អ្នកថែទាំ (ទាំងពីរភេទ) អ្នកដែលមានបញ្ហាសុខភាព)។ បង្កើនលទ្ធភាពរបស់ឪពុកម្តាយ និងអ្នកថែទាំផ្សេងទៀតក្នុងការទទួលបានរបរចិញ្ចឹមជីវិត និងសកម្មភាពរកប្រាក់ចំណូលក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ ដែលអាចឱ្យពួកគេរក្សាតុល្យភាពរវាងឱកាសទាំងនេះ និងភារៈថែទាំ។ |
| សកម្មភាពអាទិភាព ៥.៣.៥ ៖ រៀបចំកម្មវិធីជាក់លាក់ដែលឆ្លើយតបនឹងយេនឌ័រ និងគិតគូរពីបរិបទ ដើម្បីផ្តល់ការគាំទ្រសមស្របផ្នែកចិត្តសង្គមដល់ជនរងគ្រោះដោយសារជម្លោះ អំពើហិង្សា និងអសន្តិសុខ (រួមទាំងកុមារ និងយុវជន) ដើម្បីដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត និងលុបបំបាត់វដ្តនៃអំពើហិង្សា ដូចជាតាមរយៈការប្រើប្រាស់យុត្តិធម៌ក្នុងការស្តារឡើងវិញ និងមធ្យោបាយដោះស្រាយជម្លោះ ឬការកសាងសន្តិភាព ដើម្បីប្រឆាំងភាពជ្រុលនិយម និងពង្រឹងភាពអត់អោន[99]។ ផ្តល់សេវា និងការគាំទ្រដែលត្រូវការចាំបាច់ ដល់ជនរងគ្រោះ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ ដើម្បីធានាថាការស្តារលទ្ធភាពពលកម្ម និងសមារណកម្មឡើងវិញដោយជោគជ័យក្នុងស្ថានភាពក្រោយពេលជម្លោះ និងស្ថានភាពក្រោយពេលសង្គ្រោះបន្ទាន់។ |
| សកម្មភាពអាទិភាព ៥.៣.៦ ៖ បញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំ និងការផ្តល់សេវាអប់រំ និងសេវាសុខភាព ដូចជា លទ្ធភាពជាប់លាប់ក្នុងការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ[100] និងផ្តួចផ្តើមការអនុវត្តកម្មវិធី និងសេវាទាំងនេះនៅដំណាក់កាលដំបូងបង្អស់នៃប្រតិបត្តិការសង្គ្រោះ និង ស្តារឡើងវិញ ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់ ផ្តល់ការគាំទ្រផ្នែកចិត្តសង្គម និងលើកកម្ពស់ការបន្តផ្តល់ការបណ្តុះបណ្តាល និងការអប់រំដល់ស្ត្រី និងក្មេងស្រីគ្រប់រូប។ |

97 ចំណុចនេះរួមបញ្ចូល ឧ. ការផ្តល់សេវាវេជ្ជសាស្ត្រ សេវាចិត្តសង្គម សេវាច្បាប់ និងសុវត្ថិភាព/សេវាការពារ និងលទ្ធភាពទទួលបានការថែទាំសុខភាព ជម្រក/ផ្ទះសុវត្ថិភាព ក៏ដូចជាយុត្តិធម៌ស្តារឡើងវិញ។

98 Article 1, ASEAN Convention Against Trafficking in Persons, Especially Women and Children, 2015.

99 ចំណុចនេះបំពេញបន្ថែមលើសកម្មភាពដែលមានរៀបរាប់ក្នុង ASEAN Workplan to Prevent and Counter the Rise of Radicalisation and Violent Extremism, p. 12។

100 ដូចការលើកឡើងក្នុង ASEAN Regional Framework on Protection, Gender and Inclusion in Disaster Management (2021-2025)។

## តារាងស្ដីពីការអនុវត្ត ការសម្របសម្រួល ការរាយការណ៍ ការពិនិត្យតាមដាន និងវាយតម្លៃ

លទ្ធផលយុទ្ធសាស្ត្រទី ៦ ៖ បង្កើត និងដំណើរការហេដ្ឋារចនាសម្ព័ន្ធ និងយន្តការសម្រាប់ការអនុវត្ត ការសម្របសម្រួល ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីគាំទ្រដល់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អមជាមួយនឹងវិធានការជាក់លាក់ដើម្បីកែសម្រួល និងផ្លាស់ប្តូរដោយផ្អែកលើការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងលទ្ធផលរកឃើញពីរបាយការណ៍វឌ្ឍនភាព ការវាយតម្លៃ និងទិន្នន័យស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

សូចនាករលទ្ធផលចុងក្រោយ ៖

- ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងការអនុវត្ត ការសម្របសម្រួល ផែនការពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានអនុម័តដោយគណៈកម្មាធិការស្ត្រី អាស៊ាន ក្រោមការពិគ្រោះយោបល់ជាមួយស្ថាប័នតាមវិស័យរបស់អាស៊ាន។
- របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត ត្រូវបានដាក់ជូនស្ថាប័នអនុម័តរបស់អាស៊ាន និងបោះពុម្ពផ្សាយជាប្រចាំ[101]។
- ចំនួនវិធានការដែលបានធ្វើឡើងដើម្បីបង្កើនការអនុវត្ត ការសម្របសម្រួល និង/ឬផែនការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ដោយផ្អែកតាមព័ត៌មានដែលផ្តល់ដោយសង្គមស៊ីវិល និងអង្គការស្ត្រី។
- ចំនួនវិធានការដែលបានធ្វើឡើងដើម្បីផ្លាស់ប្តូរសកម្មភាពអនុវត្ត ដោយផ្អែកលើរបាយការណ៍វឌ្ឍនភាព ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និង/ឬយន្តការផ្តល់ព័ត៌មានត្រឡប់ផ្សេងទៀត។

លទ្ធផលរំពឹងទុក ៦.១ ៖ បង្កើតរចនាសម្ព័ន្ធ និងយន្តការថ្នាក់តំបន់សម្រាប់ការសម្របសម្រួល និងការពិនិត្យតាមដានវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្រោមការពិគ្រោះយោបល់ជាមួយស្ថាប័នតាមវិស័យសំខាន់ៗរបស់អាស៊ាន។

សកម្មភាពអាទិភាព ៦.១.១ ៖ សម្រេចបញ្ចប់ និងអនុម័តរចនាសម្ព័ន្ធនៃការអនុវត្ត និងការសម្របសម្រួល (រួមទាំងលក្ខខណ្ឌយោងសម្រាប់ស្ថាប័នអនុវត្ត) ក្រោមការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គណៈកម្មាធិការស្ត្រីអាស៊ាន គណៈកម្មការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ និងស្ថាប័ន និងអង្គភាពតាមវិស័យរបស់អាស៊ាន។

សកម្មភាពអាទិភាព ៦.១.២ ៖ ផ្តល់ជំនួយបច្ចេកទេស និងការណែនាំសម្រាប់ការបង្កើត និងការអនុវត្តយន្តការសម្របសម្រួល ពិនិត្យតាមដាន រាយការណ៍ និងវាយតម្លៃ ក្នុងស្ថាប័ន និងអង្គភាពរបស់អាស៊ាន ដើម្បីគាំទ្រដល់ការបំពេញទំនួលខុសត្រូវរបស់ពួកគេ ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

សកម្មភាពអាទិភាព ៦.១.៣ ៖ បញ្ជាក់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីបង្គោលយេនឌ័រនៅក្នុងស្ថាប័ន អង្គភាព និងទីភ្នាក់ងាររបស់អាស៊ាន (ដែលមានជាស្រេច ឬត្រូវបានស្នើឡើង)[102] ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីទាញប្រយោជន៍ពីកម្លាំងផ្តួប និងបញ្ចៀសភាពត្រួតគ្នា។

សកម្មភាពអាទិភាព ៦.១.៤ ៖ រិះរកលទ្ធភាពនៃការរៀបចំកិច្ចប្រជុំកំពូលជាប្រចាំមួយ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាមួយស្ថាប័នអនុវត្តសំខាន់ៗទាំងអស់ និងសង្គមស៊ីវិល និងរិះរកវិធីទាញប្រយោជន៍ពីកិច្ចប្រជុំដែលមានស្រាប់ (ដូចជា កិច្ចប្រជុំរួមប្រចាំឆ្នាំរវាងគណៈកម្មាធិការស្ត្រីអាស៊ាន និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ) ដើម្បីប្រើប្រាស់ជាយន្តការជាប់លាប់មួយសម្រាប់ការធ្វើបច្ចុប្បន្នភាពស្តីពីការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ និងពង្រឹងភាពពាក់ព័ន្ធរវាងគំនិតផ្តួចផ្តើមក្នុងមូលដ្ឋាន និងអ្នកតាក់តែងគោលនយោបាយ[103]។

សកម្មភាពអាទិភាព ៦.១.៥ ៖ កំណត់លក្ខខណ្ឌយោងសម្រាប់ទីប្រឹក្សា ឬមុខតំណែងផ្អែកតាមគម្រោង ដែលគាំទ្រដល់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

Continued

101 ស្ថាប័នត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាព ក៏ដូចជាក្របខណ្ឌពេលវេលាសម្រាប់ការរាយការណ៍ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការវាយតម្លៃផលប៉ះពាល់ចុងក្រោយ នឹងត្រូវបានកំណត់នៅអំឡុងឆ្នាំទី ១។ ស្ថាប័ននេះមិនគួរជាដៃគូអនុវត្តនោះទេ និងគួរតែមានឯករាជ្យភាព។ សូមមើល ផ្នែកទី ២ (ព័ត៌មានបន្ថែម) នៃឯកសារនេះសម្រាប់ការពិភាក្សាបន្ថែមទៀតស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ។

102 ដូចការពិភាក្សាក្នុង ASEAN Gender Mainstreaming Strategic Framework, 2021-2025, p. 8។

103 ទាំងនេះជាការលើកឡើងដោយក្រុមការងារបច្ចេកទេសទទួលបន្ទុកការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២២។

| |
|---|
| សកម្មភាពអាទិភាព ៦.១.៦ ៖ បញ្ជាក់ពីបណ្តាញទំនាក់ទំនងដែលមានប្រសិទ្ធភាព ដូចជាការប្រើប្រាស់វេទិកាផ្ញើសារបែបនិម្មិត ដើម្បីសម្រួលដល់ការឆ្លើយឆ្លងប្រកបដោយប្រសិទ្ធផលស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោម និងរវាងភាគីពាក់ព័ន្ធសំខាន់ៗ និងរៀបចំកាលវិភាគសម្រាប់កិច្ចប្រជុំជាប់លាប់ ក៏ដូចជាបទដ្ឋាន ឬគោលការណ៍ណែនាំ សម្រាប់ការចែករំលែកព័ត៌មានបច្ចុប្បន្នភាព ស្តីពីសកម្មភាពអនុវត្ត បញ្ហាប្រឈម ការអនុវត្តល្អបំផុត ។ល។ |
| |
| លទ្ធផលរំពឹងទុក ៦.២ ៖ រៀបចំផែនការពិនិត្យតាមដាន រាយការណ៍ និងវាយតម្លៃសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[104] រួមទាំងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល (ដូចជា អង្គការស្ត្រី ក្រុមជនជាតិដើមភាគតិច បណ្តាញផ្សព្វផ្សាយ និងវិស័យឯកជន) និងក្របខណ្ឌពេលវេលាសម្រាប់ការរាយការណ៍ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការវាយតម្លៃចុងក្រោយ។ |
| សកម្មភាពអាទិភាព ៦.២.១ ៖ កំណត់ភាពចាំបាច់នៃការកសាងសមត្ថភាព និងការបណ្តុះបណ្តាលបច្ចេកទេសដើម្បីអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខប្រកបដោយប្រសិទ្ធភាព (ដូចជា ពាក់ព័ន្ធនឹងការពិនិត្យតាមដាន និងវាយតម្លៃ) និងផ្តល់ការបណ្តុះបណ្តាលដើម្បីលុបបំបាត់គម្លាតចំណេះដឹង និងជំនាញ។ |
| សកម្មភាពអាទិភាព ៦.២.២ ៖ បង្កើតវិធីសាស្ត្រ និងឧបករណ៍សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ដូចជាយុទ្ធសាស្ត្រសម្រាប់ការទទួលបាន និងការប្រមូលទិន្នន័យបែងចែកតាមភេទ និងអថេរផ្សេងទៀត (អាយុ ពូជសាសន៍ ជាតិពន្ធុ-ល-។) ប្រកបដោយក្រមសីលធម៌ និងស៊ីសង្វាក់គ្នានឹងការអនុវត្តល្អបំផុត (ដូចជា ទិន្នន័យមុនធ្វើអន្តរាគមន៍ និងទិន្នន័យក្រោយធ្វើអន្តរាគមន៍)។ |
| សកម្មភាពអាទិភាព ៦.២.៣ ៖ សម្របសម្រួលដំណើរការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ដូចជា អង្គការធ្វើការពាក់ព័ន្ធនឹងស្ត្រីយុវជន ស្ត្រីជនជាតិដើមភាគតិចជាដើម និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដើម្បីពិនិត្យឡើងវិញលើរបាយការណ៍វឌ្ឍនភាព និងការវាយតម្លៃប្រចាំឆ្នាំ ជំរុញការផ្តល់ព័ត៌មានត្រឡប់ និងធ្វើការកែលម្អដោយផ្អែកលើការរាយការណ៍ និងការពិនិត្យតាមដានចន្លោះពេល។ |
| សកម្មភាពអាទិភាព ៦.២.៤ ៖ ផ្តល់ទម្រង់ និងគំរូឯកសារដែលមានស្តង់ដារសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ដែលមានប្រសិទ្ធភាព និងផ្តល់ភាពងាយស្រួល បូករួមនឹងការបណ្តុះបណ្តាលស្តីពីរបៀបបំពេញគំរូឯកសារទាំងនេះ។ |
| សកម្មភាពអាទិភាព ៦.២.៥ ៖ បង្កើត និងកែសម្រួលគំរូឯកសាររាយការណ៍ និងក្របខណ្ឌពេលវេលា និងពង្រឹងសមត្ថភាពរបស់រដ្ឋជាសមាជិកអាស៊ាន និងអាស៊ានក្នុងការរាយការណ៍ពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ ពិចារណាពីក្របខណ្ឌពេលវេលានៃលក្ខខណ្ឌរាយការណ៍ផ្សេងទៀតដែលតម្រូវដោយ អាស៊ាន ជាពិសេសលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសិទ្ធិស្ត្រី ដើម្បីទាញប្រយោជន៍ពីកម្លាំងផ្គួប និងបង្កើនប្រសិទ្ធភាព ជាជាងធ្វើការងារត្រួតគ្នា និងរាយការណ៍ច្រំដែល។ |
| |
| លទ្ធផលរំពឹងទុក ៦.៣ ៖ បង្កើតផែនការទំនាក់ទំនង និងស្វែងរកមតិគាំទ្រដើម្បីបង្កើនភាពលេចធ្លោរ និងការយល់ដឹងនៅថ្នាក់សកល ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានស្តីពីផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (រួមទាំងក្នុងពេលអនុវត្ត) និងបង្កើនភាពជា ដៃគូ និងពង្រឹងការកៀរគរធនធានដើម្បីគាំទ្រដល់ការអនុវត្ត។ |
| សកម្មភាពអាទិភាព ៦.៣.១ ៖ បង្កើតគេហទំព័រសម្រាប់ផ្សព្វផ្សាយពីស្ត្រី សន្តិភាព និងសន្តិសុខ[105] ដែលដើរតួនាទីជាបណ្តុំចំណេះដឹង[106] សម្រាប់តំបន់អាស៊ាន និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| សកម្មភាពអាទិភាព ៦.៣.២ ៖ បង្កើតយុទ្ធសាស្ត្រសម្រាប់ការកៀរគរធនធានដើម្បីគាំទ្រ និងធានានិរន្តរភាពនៃការផ្តល់មូលនិធិដល់សកម្មភាព និងកម្មវិធីស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។ |

Continued ▼

104 សូមអានផ្នែកទី ២ (ព័ត៌មានបន្ថែម) នៃឯកសារនេះ សម្រាប់ខ្លឹមសារលម្អិតស្តីពីរបៀបអនុវត្ត និងគាំទ្រដល់សកម្មភាពនេះ (ទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការគាំទ្រផ្នែកបច្ចេកទេស)។

105 គេហទំព័រនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព និងគ្រប់គ្រងក្រោមមុខតំណែងអ្នកសម្របសម្រួល ASEAN WPS ដែលបានលើកមកពិភាក្សាក្នុងតារាងនេះ (៥.១.៥)។

106 អាចប្រើប្រាស់គេហទំព័រនេះសម្រាប់អនុវត្ត និងចងក្រងសារតារសកម្មភាពដែលមានលើកឡើងក្នុង RPA WPS ដូចជា ការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទិន្នន័យបែងចែកតាមភេទស្តីពីប្រធានបទស្ត្រី សន្តិភាព និងសន្តិសុខ (ដូចជា តុល្យភាពយេនឌ័រក្នុងស្ថានភាពសន្តិសុខផ្សេងៗ តុល្យភាពយេនឌ័រក្នុងការចរចាសន្តិភាព) នៅទូទាំងរដ្ឋសមាជិកអាស៊ានផ្សេងៗ ដោយមានពិពណ៌នាពីអ្នកដឹកនាំ និងភ្នាក់ងារផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងតំបន់អាស៊ាន និងការចែករំលែកការអនុវត្តល្អបំផុត/ការអនុវត្តថ្មីៗស្តីពីគោលនយោបាយ និងកម្មវិធីសន្តិភាព និងសន្តិសុខដែលឆ្លើយតបនឹងយេនឌ័រ មធ្យោបាយសម្រាប់ការបណ្តុះបណ្តាលស្តីពីយេនឌ័រ និងឯកសារជំនួយស្មារតី/គោលការណ៍ណែនាំ។ល។

| |
|---|
| សកម្មភាពអាទិភាព ៦.៣.៣ ៖ ផ្តល់ធាតុចូល និងអនុសាសន៍ដល់ផលិតផលពីការផ្សព្វផ្សាយជាយុទ្ធសាស្ត្ររបស់អាស៊ានស្តីពីសន្តិភាព និងសន្តិសុខ ដើម្បីរួមបញ្ចូលភាពជាតំណាង និងភាសាដែលមានយុត្តិធម៌យេនឌ័រ និងគូសបញ្ជាក់ពីអាទិភាពដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ បង្កើតសារ សំខាន់ៗពាក់ព័ន្ធនឹងអាទិភាពស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់អាស៊ាន ដើម្បីបង្កើនភាពស៊ីសង្វាក់គ្នាក្នុងការបង្ហាញសារជារួមនៅទូទាំងតំបន់អាស៊ាន ក៏ដូចជាផ្តល់ឱកាសសម្រាប់ការកែសម្រួលការអនុវត្ត ទៅតាមបរិបទក្នុងមូលដ្ឋាន។ |
| |
| លទ្ធផលរំពឹងទុក ៦.៤ ៖ បង្កើតយុទ្ធសាស្ត្រសម្រាប់ផ្តល់ការគាំទ្រដល់យន្តការ និងផែនការជាតិសម្រាប់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំ/ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ក្នុងករណីពាក់ព័ន្ធ) ក្របខណ្ឌគោលនយោបាយជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងគំនិតផ្តួចផ្តើមនានាដើម្បីគាំទ្រភាពជាម្ចាស់ការ និងការចូលរួមរបស់សហគមន៍ និងស្ថាប័ននៅមូលដ្ឋាន (ថ្នាក់ក្រោមជាតិ) ក្នុងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| សកម្មភាពអាទិភាព ៦.៤.១ ៖ រៀបចំឯកសារជំនួយស្មារតីដែលលម្អិតពីវិធីអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅតាមបរិបទមូលដ្ឋាន និងរៀបចំសិក្ខាសាលានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីជួយដល់ការកំណត់បញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និង សន្តិសុខ និងបញ្ជាក់ពីវិធានការដែលត្រូវការចាំបាច់ក្នុងការអនុវត្តអាទិភាពស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ ដោយផ្អែកតាមបរិបទសង្គម-នយោបាយ បរិបទសេដ្ឋកិច្ច និងបរិបទវប្បធម៌។ |
| សកម្មភាពអាទិភាព ៦.៤.២ ៖ បង្កើតគោលការណ៍ណែនាំដើម្បីគាំទ្រដល់អាជ្ញាធរមូលដ្ឋាន និងដៃគូអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អមជាមួយនឹងការពិគ្រោះយោបល់ដែលមានការចូលរួម និងការសម្របសម្រួល ពាក់ព័ន្ធនឹងការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| |
| លទ្ធផលរំពឹងទុក ៦.៥ ៖ បង្កើនសមត្ថភាពនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ក្នុងការប្រើប្រាស់ការរៀបចំផែនការ និងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រសម្រាប់គំនិតផ្តួចផ្តើមសន្តិភាព និងសន្តិសុខ។ |
| សកម្មភាពអាទិភាព ៦.៥.១ ៖ វាយតម្លៃតម្រូវការ និងកសាងសមត្ថភាពក្នុងការរៀបចំផែនការ និងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ សម្រាប់គំនិតផ្តួចផ្តើម និងកម្មវិធីស្តីពីសន្តិភាព និងសន្តិសុខរបស់អាស៊ាន។ |
| សកម្មភាពអាទិភាព ៦.៥.២ ៖ បង្កើតគោលការណ៍ណែនាំដើម្បីឆ្លើយតបនឹងសំណើរបស់រដ្ឋជាសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធផ្សេងទៀតឱ្យដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងការរៀបចំផែនការ និងការរៀបចំថវិកាស្តីពីសន្តិភាព និងសន្តិសុខ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ |
| សកម្មភាពអាទិភាព ៦.៥.៣៖ គាំទ្រដល់ការបណ្តុះបណ្តាលស្តីពីគំរូហិរញ្ញប្បទានថ្មីសម្រាប់ការអនុវត្តគំនិតផ្តួចផ្តើមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការរៀបចំថវិកាដែលមានការចូលរួម និងឆ្លើយតបនឹងយេនឌ័រ សម្រាប់កម្មវិធីស្តីពីសន្តិភាព និងសន្តិសុខ។ |
| |
| លទ្ធផលរំពឹងទុក ៦.៦ ៖ បង្កើតកម្មវិធី/គំនិតផ្តួចផ្តើមឈានមុខចំនួន២ របស់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលត្រូវប្រកាសអនុវត្ត/ប្រកាសផ្សព្វផ្សាយក្នុងផ្នែកមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[107]។ |
| សកម្មភាពអាទិភាព ៦.៦.១ ៖ រៀបចំ ពិនិត្យឡើងវិញ និងទទួលយកសំណើសម្រាប់ការប្រកាសផ្សព្វផ្សាយគំនិតផ្តួចផ្តើមឈានមុខគេចំនួន២ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[108]។ |

107 សនិទានភាពសម្រាប់គំនិតផ្តួចផ្តើមឈានមុខនេះ ចែកជា ២ ផ្នែក ៖ ១) ការផ្សព្វផ្សាយ និងការកសាងការយល់ដឹងពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ គំនិតផ្តួចផ្តើមទាំងនេះនឹងបង្កើនចំណាប់អារម្មណ៍ និងក្តីរំភើបចំពោះ RPA WPS តាមរយៈការដាក់ចេញគំនិតផ្តួចផ្តើមថ្នាក់តំបន់ ១ ឬ ២ (ឧ. ការរក្សាសន្តិភាព អំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ ការកសាងសន្តិភាព) និង ២) កសាងសមត្ថភាពក្នុងការអនុវត្ត និងរក្សាចលនការ ក្រោយការអនុម័ត RPA WPS។

108 ឧទាហរណ៍នៃគំនិតផ្តួចផ្តើមដែលអាចយកមកពិចារណា ៖ "គំនិតផ្តួចផ្តើមអាស៊ានដើម្បីលុបបំបាត់អំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ ពីតំបន់អាស៊ាន" "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការរក្សាសន្តិភាព" "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការកសាងសន្តិភាព" ឬ "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការដោះមីន"។ គំនិតផ្តួចផ្តើមទាំងនេះអាចពាក់ព័ន្ធនឹងការស្រាវជ្រាវ/ការប្រមូល/ការចងក្រងសារតារស្តីពីការអនុវត្តល្អបំផុត ការប្រមូលទិន្នន័យ ការបណ្តុះបណ្តាល កម្មវិធីសាកល្បង។ល។

# ២.ព័ត៌មានបន្ថែម

## ២.១ ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ ការសម្របសម្រួល ការរាយការណ៍ ការពិនិត្យតាមដាន និងវាយតម្លៃ

### ២.១.១ គោលការណ៍ណែនាំសម្រាប់ការអនុវត្ត

មានគោលការណ៍រួមជាច្រើនដែលផ្តល់មូលដ្ឋានព័ត៌មានដល់យន្តការអនុវត្ត និងសម្របសម្រួលផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (RPA WPS)។ ទីមួយ គឺការកត់សម្គាល់តម្រូវការជាចាំបាច់ក្នុងតំបន់អាស៊ាននូវ "អភិក្រម គ្រប់ជ្រុងជ្រោយសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខ" ដែលគ្របដណ្តប់លើសសរស្តម្ភចម្រុះ និងអន្តរវិស័យ។ ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី ៥៣ រដ្ឋមន្ត្រីការបរទេស "ទទូចឱ្យមានកិច្ចសហការ និងកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងយ៉ាងសំខាន់ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងចំណោមស្ថាប័នតាមវិស័យពាក់ព័ន្ធរបស់អាស៊ាន"។ គោលដៅរបស់អាស៊ានគឺការលើកកម្ពស់សន្តិភាព វិបុលភាព និងសង្គតិភាពសង្គមប្រកបដោយនិរន្តរភាព ក្នុងបរិបទនៃបញ្ហាសន្តិសុខដ៏ស្មុគស្មាញដែលទាមទារឱ្យមានអភិក្រមពហុវិស័យ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ឆ្លើយតបនឹងការអំពាវនាវនេះ តាមរយៈការកំណត់ផែនការសកម្មភាពមួយដែលខិតខំដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងសកម្មភាពទាំងអស់របស់អាស៊ាន ដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ។

ទីពីរ បញ្ហាប្រឈមពាក់ព័ន្ធនឹងយេនឌ័រ សន្តិភាព និងសន្តិសុខ មានភាពស្មុគស្មាញ និងប្រែប្រួលឥតឈប់ឈរ។ ផែនការអនុវត្តនេះមានគោលបំណងធានាថាមានការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព និងការប្រមូលទិន្នន័យជាប្រព័ន្ធដើម្បីឱ្យផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅតែមានប្រសិទ្ធភាពក្នុងការសម្រេចបានលទ្ធផល នៅពេលមានការប្រែប្រួលស្ថានការណ៍។

ទីបី គឺភាពចាំបាច់នៃអភិក្រមបែបបរិយាបន្ន។ ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទាមទារទាំងការសម្របសម្រួលទូទាំងសសរស្តម្ភ និងស្ថាប័នតាមវិស័យរបស់អាស៊ាន ក៏ដូចជាការចូលរួមរបស់សង្គមស៊ីវិល[109] អ្នកឆ្លើយតបជួរមុខទៅនឹងជម្លោះ គ្រាអាសន្ន និងគ្រោះមហន្តរាយ និងអ្នកដែលមិនទទួលបានការយកចិត្តទុកដាក់ជាច្រើនលើកច្រើនសា[110] និងអសន្តិសុខ ដែលជាញឹកញាប់ មានសភាពកាន់តែធ្ងន់ធ្ងរក្នុងពេលមានជម្លោះ និងវិបត្តិ។ អភិក្រមបែបបរិយាបន្នមានគោលបំណងផ្តល់ ឬបង្កើតលទ្ធភាព និងឱកាសសម្រាប់អ្នកដែលត្រូវបានគេមើលរំលង ឬមិនអើពើជារឿយៗ និងលុបបំបាត់ឧបសគ្គ ដូចជា ការរើសអើង និងភាពលម្អៀងដែលបង្កផលប៉ះពាល់លើការចូលរួមយ៉ាងពេញលេញ និងប្រកបដោយអត្ថន័យរបស់មនុស្សគ្រប់រូបក្នុងវិស័យសន្តិភាព និងសន្តិសុខ[111]។

ទីបួន ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបនឹងអាទិភាពរួម និងបរិបទជាក់លាក់ក្នុងតំបន់អាស៊ាន។ សកម្មភាពអនុវត្ត និងសម្របសម្រួល ដែលបានធ្វើឡើងក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានគោលបំណងរក្សាតុល្យភាពសមស្របរវាងការធានាថា ការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ ឆ្លើយតបនឹងតម្រូវការ និងអាទិភាពក្នុងមូលដ្ឋាន និងកត់សម្គាល់ថា បញ្ហាសន្តិសុខ ដូចជា ជំងឺរាតត្បាត ភាពជ្រុលនិយម ការប្រែប្រួលអាកាសធាតុ និងការគំរាមកំហែងលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាជម្លោះ មិនបានកត់សម្គាល់ ឬបញ្ចប់នៅចំណុចព្រំដែននោះទេ។ ផ្ទុយទៅវិញ បញ្ហាទាំងនេះបានលេចឡើង និងបង្កផលវិបាកនៅទូទាំងតំបន់អាស៊ាន និងសាយភាយទៅក្រៅតំបន់ និងទាមទារឱ្យមានការឆ្លើយតបដោយមានការសម្របសម្រួល ដែលរួមបញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខ។

---

109 មានការយល់ឃើញផ្សេងៗគ្នាពាក់ព័ន្ធនឹងពាក្យ "សង្គមស៊ីវិល"។ នៅពេលនិយាយដល់ "សង្គមស៊ីវិល" ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ សំដៅលើអង្គការដែលចងសម្ព័ន្ធភាពដោយផ្ទាល់ជាមួយ ឬជាផ្នែកមួយនៃអង្គភាព/ស្ថាប័នរដ្ឋាភិបាល ដូចជា បណ្តាញ និងអង្គការនានា (ជនជាតិដើមភាគតិច ស្ត្រី យុវជន។ល។) ក្រុមតស៊ូមតិ សាលារៀន ស្ថាប័នសាសនា សាកលវិទ្យាល័យ បណ្តាញផ្សព្វផ្សាយឯករាជ្យ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់។ វិស័យឯកជនក៏ត្រូវបានចាត់ទុកជាផ្នែកមួយនៃសង្គមស៊ីវិលនៅក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផងដែរ។

110 ក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ពាក្យនេះសំដៅលើ "ក្រុមងាយរងគ្រោះ" ដើម្បីគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការធានាសន្តិភាព និងសន្តិសុខសម្រាប់ "តំបន់អាស៊ានទាំងមូល" រួមទាំងប្រជាជនក្នុងតំបន់អាស៊ានដែលប្រឈមនឹងបញ្ហាសន្តិសុខដ៏ក្តៅគគុក ឬចម្រុះ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានគោលបំណងផ្តល់មូលដ្ឋានដល់អាស៊ានក្នុងការសម្រេចគោលបំណងនេះ តាមរយៈការអនុវត្តអភិក្រមបែបប្រសព្វគ្នាសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខដែលទទួលស្គាល់ថា ស្ត្រី និងបុរសអាចមានបទពិសោធន៍ តម្រូវការ និងការព្រួយបារម្ភខុសៗគ្នាពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដោយសារអថេរជាច្រើន និងរបៀបដែលអថេរទាំងនេះ "ប្រសព្វគ្នា" ដែលនាំឱ្យពួកគេទទួលរងការលំបាក និងការផាត់ចេញក្នុងទម្រង់ចម្រុះ និងជារឿយៗ ក្នុងកម្រិតកាន់តែខ្លាំង។ អថេរទាំងនេះរួមមានពូជសាសន៍ វណ្ណៈ ជាតិពន្ធុ យេនឌ័រ ពិការភាព សាសនា អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពជាជនជាតិដើមភាគតិច ស្ថានភាពទេសន្តរប្រវេសន៍ និងកត្តាផ្សេងទៀត។

111 ការសន្មតជាមូលដ្ឋានក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គឺសន្តិភាព និងសន្តិសុខអាចសម្រេចទៅបានតែតាមរយៈដំណើរការបរិយាបន្នប៉ុណ្ណោះ។ វិបត្តិកូវីដ-១៩ បានរំលេចចំណុចនេះកាន់តែច្បាស់ ព្រោះអ្នកដែលមិនអាចទទួលបានវិធានការសុខភាពសាធារណៈ និងវ៉ាក់សាំង មិនត្រឹមតែធ្វើឱ្យពួកគាត់ងាយប្រឈមនឹងហានិភ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអ្នកដទៃមិនសូវមានសុវត្ថិភាព និងបរាជ័យក្នុងការបញ្ឈប់ការឆ្លងរាលដាលជំងឺនេះថែមទៀតផង។

ទីប្រាំ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានគោលបំណងទាញប្រយោជន៍ពីជំនាញផ្សេងៗនៅក្នុងតំបន់ពាក់ព័ន្ធនឹងការអនុវត្តយន្តការស្ត្រី សុខភាព និងសន្តិសុខ។ ការពិភាក្សាក្នុងរបាយការណ៍អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ លើកឡើងថា "រដ្ឋជាសមាជិកអាស៊ានមានការផ្តោតសំខាន់ខុសគ្នាលើផ្នែកផ្សេងៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ រដ្ឋជាសមាជិកមួយចំនួន ដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន ផ្តោតសំខាន់លើតួនាទីរបស់ស្ត្រីក្នុងការទប់ស្កាត់ជម្លោះ រួមទាំងការទប់ស្កាត់ និងប្រឆាំងអំពើហិង្សាជ្រុលនិយម។ ប្រទេសមួយចំនួនទៀត ដូចជា កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម ផ្តោតលើការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការរក្សាសន្តិភាព ខណៈពេលដែលហ្វីលីពីនផ្តោតសំខាន់លើការចូលរួមរបស់ស្ត្រីក្នុងដំណើរការកសាងសន្តិភាព"។ ទន្ទឹមនឹងការកត់សម្គាល់អាទិភាពផ្សេងៗទាំងនេះ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់អាស៊ាន ក្នុងការសម្រេចបានវឌ្ឍនភាពទូទាំងតំបន់អាស៊ានលើអាទិភាពដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ និងការកសាងសមត្ថភាពដែលត្រូវការចាំបាច់ ប្រព័ន្ធ និងយន្តការសម្របសម្រួលដើម្បីទ្រទ្រង់វឌ្ឍនភាពនេះ។ ផ្អែកតាមជំនាញក្នុងតំបន់អាស៊ានក្នុងការអនុវត្តសកម្មភាពនវានុវត្តន៍ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខិតខំចងក្រងករណីសិក្សាទាំងនេះ និងការអនុវត្តល្អបំផុត ដើម្បីឱ្យបទពិសោធន៍ទាំងនោះអាចផ្តល់មូលដ្ឋានព័ត៌មាន និងជំរុញឱ្យមានការរៀបចំកម្មវិធីស្តីពីស្ត្រី សន្តិភាព និងសន្តិសុខបន្ថែមទៀត។

## ២.១.២ ស្ថាប័នអនុវត្ត តួនាទី និងការទទួលខុសត្រូវ

ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ក្នុងនាមជាក្រុមការងារដែលចូលរួមដោយតំណាងមកពីគណៈកម្មាធិការស្ត្រីអាស៊ាន និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ នៃរដ្ឋជាសមាជិកអាស៊ានចំនួន ៥ (ឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី វៀតណាម និងកម្ពុជា) ដើម្បីដឹកនាំការរៀបចំការសិក្សាក្នុងតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ការបង្កើតក្រុមការងារនេះ អនុវត្តតាមអនុសាសន៍នៃសន្និសីទស្ត្រី សន្តិភាព និងសន្តិសុខ អាស៊ានលើកទី ១ ដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ ២០១៨។

ក្នុងខែ មករា ឆ្នាំ ២០២១ មានការពង្រីកក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងមានការកែសម្រួលលក្ខខណ្ឌយោងរបស់ក្រុមប្រឹក្សានេះ។ ការពង្រីកសមាជិកភាព និងវិសាលភាព ត្រូវបានចាត់ទុកជាគន្លឹះនៃការជំរុញការចូលរួមរបស់ស្ថាប័នតាមវិស័យនៅអាស៊ាន នៅទូទាំងសហគមន៍អាស៊ានទាំង ៣ និងជានាការចូលរួមអន្តរវិស័យ និងកិច្ចសន្ទនាអន្តរសសរស្តម្ភដើម្បីលើកកម្ពស់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់តំបន់។ ដោយសាររបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានភាពទូលំទូលាយ និងទាមទារកិច្ចសហការទូទាំងសហគមន៍ទាំង ៣ ការចូលរួមយ៉ាងសកម្មរបស់ស្ថាប័នតាមវិស័យពាក់ព័ន្ធរបស់អាស៊ាន ជាពិសេសសហគមន៍សេដ្ឋកិច្ចនិងសហគមន៍នយោបាយ-សន្តិសុខអាស៊ាន មានសារៈសំខាន់ណាស់ក្នុងការធានាភាពជាម្ចាស់ការ និងការអនុវត្តផែនការសកម្មភាពអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នាពេលអនាគត។

ដើម្បីទាញប្រយោជន៍ពីចលនការនៃការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងបង្កើតក្រុមការងារបច្ចេកទេសទទួលបន្ទុកការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (TWG-WPS)[112] ដែលមានប្រទេសកម្ពុជាធ្វើជាប្រធាន (ដែលបច្ចុប្បន្ន ធ្វើជាប្រធានអាស៊ាន និងជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ)។

ក្រុមការងារបច្ចេកទេសអាស៊ានទទួលបន្ទុកការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងបំពេញការងារដូចខាងក្រោម សម្រាប់ឆ្នាំដំបូងនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយទទួលបានជំនួយបច្ចេកទេសពីលេខាធិការដ្ឋានអាស៊ាន (ASESC) អង្គការ UN Women គម្រោង USAID-PROSPECT និងដៃគូផ្សេងទៀត ដែលបានកំណត់ ឬត្រូវការចាំបាច់ ៖

១. ការរៀបចំលក្ខខណ្ឌយោង (តួនាទី/ការទទួលខុសត្រូវ) សម្រាប់ទីភ្នាក់ងារ/អង្គភាព/ស្ថាប័នសំខាន់ៗក្នុងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងមន្ត្រីបង្គោលយេនឌ័រអាស៊ាន[113]។

២. ការបញ្ជ្រាបរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទូទាំងសហគមន៍អាស៊ានទាំង ៣ និងស្ថាប័នតាមវិស័យដែលពាក់ព័ន្ធ។

112 ដើម្បីទាញប្រយោជន៍ពីចលនការ ក្រុមការងារនេះគួរចូលរួមដោយសមាជិកនៃក្រុមការងារបច្ចេកទេសរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលរួមមាន ACW, ACWC, ASEAN-IPR, AICHR, SOMTC, AWEN និងលេខាធិការដ្ឋានអាស៊ាន បូករួមនឹងតំណាងមកពីគម្រោង PROSPECT របស់អាស៊ាន-USAID និងអង្គការ UN Women។

113 មន្ត្រីបង្គោលយេនឌ័រត្រូវបានស្នើឡើងដោយក្របខណ្ឌយុទ្ធសាស្ត្រនៃក្របខណ្ឌបញ្ជ្រាបយេនឌ័រអាស៊ាន ២០២១-២០២៥។

៣.	ការកំណត់ភាពចាំបាច់នៃការប្រមូល និងវិភាគទិន្នន័យដើមគ្រាបន្ថែមទៀត និងធ្វើការសិក្សាដើម្បីលុបបំបាត់គម្លាតក្នុងទិន្នន័យដើមគ្រា[114]។

៤.	ពង្រាង និងសម្រេចបញ្ចប់ក្របខណ្ឌ និងផែនការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខដែលត្រូវអនុម័តដោយ គណៈកម្មាធិការស្ត្រីអាស៊ាន។

៥.	ការបញ្ជាក់/ការកំណត់ហេដ្ឋារចនាសម្ព័ន្ធ និងយន្តការសម្រាប់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តួនាទី និងការទទួលខុសត្រូវ និងតម្រូវការ។ ផ្អែកតាមគោលបំណងនៃសមាហរណកម្មស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ យន្តការទាំងនេះគួរប្រើប្រាស់ (និងប្រសិនបើចាំបាច់ កសាងសមត្ថភាព) ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញសម្របសម្រួលដែលមានស្រាប់របស់អាស៊ាន។ ទោះជាយ៉ាងណា ប្រហែលជាចាំបាច់ត្រូវមាន យន្តការ/ហេដ្ឋារចនាសម្ព័ន្ធថ្មីៗសម្រាប់ការអនុវត្ត។

ខាងក្រោមនេះជាជម្រើសដែលត្រូវពិចារណា ៖

- ការបង្កើតមុខតំណែងទីប្រឹក្សា ឬមុខតំណែងផ្អែកតាមគម្រោង ដែលមានការផ្តល់មូលនិធិ[115] ក្នុងតំបន់អាស៊ានដើម្បីសម្របសម្រួលអង្គភាពដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ លក្ខខណ្ឌយោងសម្រាប់មុខតំណែងនេះ អាចរួមមាន៖ ១) ការដើរតួនាទីជាមន្ត្រីបង្គោលទទួលបន្ទុកស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងតំបន់អាស៊ាន; ២) ការបង្កើត និងធ្វើបច្ចុប្បន្នភាពគេហទំព័រស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ; ៣) ការទទួល និងប្រមូលទិន្នន័យ ការអនុវត្តល្អបំផុត និងករណីសិក្សាពីរដ្ឋជាសមាជិក អាស៊ាន អង្គការសង្គមស៊ីវិល និងអ្នកផ្សេងទៀតដែលធ្វើការងារពាក់ព័ន្ធនឹងការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន និងបោះពុម្ពផ្សាយទិន្នន័យ ការអនុវត្តល្អបំផុត និងករណីសិក្សាទាំងនោះក្នុងគេហទំព័រ; ៤) ការបំពេញមុខងារជាមន្ត្រីបង្គោល និងអន្តរការីសម្រាប់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ាន ក៏ដូចជាសង្គមស៊ីវិល បណ្តាញ ផ្សព្វផ្សាយ វិស័យឯកជន-ជាដើម; ៥) ការត្រួតពិនិត្យការអនុវត្ត និងសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងក្រុមការងារបច្ចេកទេស។
- ការកំណត់ចំនួនមន្ត្រីបង្គោលយេនឌ័រដែលត្រូវបានស្នើឡើង បង្កើតឡើង និង/ឬដើរតួនាទីសកម្មនៅទូទាំងស្ថាប័នតាមវិស័យពាក់ព័ន្ធរបស់អាស៊ាន និងសសរស្តម្ភ ដែលអាចត្រូវបានជំរុញឱ្យមានការចូលរួមបន្ថែមទៀតក្នុងអាទិភាពដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ដែលជាផ្នែកមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

៦.	ប្រសិនបើពាក់ព័ន្ធ រៀបចំសំណើ និងជំនួយមូលនិធិសម្រាប់ការប្រកាសអនុវត្តគំនិតផ្តួចផ្តើមឈានមុខ ២ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[116]។ សនិទានភាពសម្រាប់គំនិតផ្តួចផ្តើមដំបូងៗទាំងនេះ គឺវានឹងជួយជំរុញការអនុវត្ត តាមរយៈការកសាងសមត្ថភាពក្នុងការអនុវត្តយន្តការស្ត្រី សន្តិភាព និងសន្តិសុខ និងការទាក់ទាញចំណាប់អារម្មណ៍ និងការចូលរួមបន្ថែមទៀត។ គំនិតផ្តួចផ្តើមទាំងនេះ នឹងទាញប្រយោជន៍ពី សន្ទុះស្មារតីនៃការប្រកាសអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីសម្រេចវឌ្ឍនភាពជាក់លាក់លើបញ្ហាដែលមានការគាំទ្រទូលំទូលាយផ្នែកនយោបាយរួចជាស្រេច តាមរយៈការបង្កើនការរៀនសូត្រ ក្តីរំភើប និងការយកចិត្តទុកដាក់លើផែនសកម្មភាពតំបន់អាស៊ានក្នុងដំណាក់កាលដំបូងៗ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

៧.	ការបង្កើតសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលចូលរួមដោយ "រដ្ឋាភិបាលវិស័យសន្តិសុខ អ្នកជំនាញខាងសិក្សាស្រាវជ្រាវ អង្គការសង្គម ស៊ីវិល[117] ដូចជា ក្រុមស្ត្រី និងក្រុមយុវជន និងមានការពិគ្រោះយោបល់ជាមួយពួកគេ អមជាមួយនឹងការបង្កើតកាលវិភាគ ឬយន្តការសម្រាប់ការពិគ្រោះយោបល់ជាប្រចាំ។

---

114 សំដៅលើទិន្នន័យមុនការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

115 ការលើកឡើងមួយក្នុងចំណោមនោះ គឺការបង្កើតឱ្យមានមុខតំណែងទីប្រឹក្សាចំនួន ២ ដើម្បីចាប់ផ្តើម និងណែនាំដល់ការអនុវត្តផែនការសកម្មភាពថ្នាក់តំបន់ ដោយមុខតំណែងមួយផ្តោតលើការផ្តល់ការគាំទ្រសំខាន់ៗ និងការគាំទ្រផ្នែកបច្ចេកទេស (ដូចជា ការពិនិត្យកែសម្រួល និងបោះពុម្ពផ្សាយការអនុវត្តល្អបំផុត ការកំណត់តម្រូវការទិន្នន័យ ការប្រមូលទិន្នន័យដែលមានស្រាប់ ការពង្រឹងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការរៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃ) និងមុខតំណែងមួយទៀតផ្តោតលើការសម្របសម្រួល និងរដ្ឋបាល។

116 ឧទាហរណ៍នៃលទ្ធភាពនានា (អាចមានច្រើន ប៉ុន្តែទាំងនេះគឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ) ៖ "គំនិតផ្តួចផ្តើមអាស៊ានដើម្បីលុបបំបាត់អំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ ពីតំបន់អាស៊ាន" "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការរក្សាសន្តិភាព" "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការកសាងសន្តិភាព" ឬ "គំនិតផ្តួចផ្តើមអាស៊ានស្តីពីស្ត្រី និងការដោះមីន" ដែលអាចរួមបញ្ចូលការប្រមែប្រមូលការអនុវត្តល្អបំផុត ការបណ្តុះបណ្តាល កម្មវិធីសាកល្បងបែបនវានុវត្តន៍។ល។

117 អនុសាសន៍ពី ASEAN Report on WPS, p.2។

៨.	ការរៀបចំកិច្ចប្រជុំកំពូលស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ានរៀងរាល់ ២ ឆ្នាំម្តង ដើម្បីសម្រួលដល់ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ ចែករំលែកការអនុវត្តល្អបំផុត និងគាំទ្រដល់ការសម្របសម្រួល និងការបង្កើតបណ្តាញក្នុងចំណោមស្ថាប័នតាមវិស័យដែលពាក់ព័ន្ធគណៈកម្មាធិការស្ត្រីអាស៊ាន គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ដៃគូសន្ទនា និងអង្គការសង្គមស៊ីវិល។

ក្នុងអំឡុងពេលអនុវត្តនៅឆ្នាំដំបូង ភាគីសំខាន់ៗដែលទទួលខុសត្រូវលើការអនុវត្តសកម្មភាពអាទិភាព នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានកំណត់ និងបញ្ជាក់ច្បាស់ ហើយក្រោមការសម្របសម្រួលជាមួយក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងលេខាធិការដ្ឋាន អាស៊ាន ពួកគេបានចងក្រងព័ត៌មានខាងក្រោមដែលពាក់ព័ន្ធនឹងផែនការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់ពួកគេ ៖

- ការប៉ាន់ប្រមាណតម្រូវការបច្ចេកទេស និងតម្រូវការហិរញ្ញវត្ថុ
- តួនាទី និងការទទួលខុសត្រូវក្នុងស្ថាប័នរបស់ពួកគេ និងក្នុងចំណោមដៃគូ
- ក្របខណ្ឌពេលវេលា និងបង្គោលចរ ជាមួយចំណុចដៅ និងលទ្ធផលច្បាស់លាស់
- ការដាក់ស្នើរង្វាស់ប្រសិទ្ធភាព និងមធ្យោបាយប៉ាន់ប្រមាណដែលយ៉ាងហោចណាស់ លម្អិតពីការចូលរួមរបស់ពួកគេទាំងមុនពេលធ្វើអន្តរាគមន៍ និងក្រោយពេលធ្វើអន្តរាគមន៍។

យន្តការអនុវត្តនៅថ្នាក់ជាតិ ៖ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ផ្តល់ក្របខណ្ឌរួម គោលការណ៍ គោលបំណង និងសកម្មភាពអាទិភាព ប៉ុន្តែមានគោលបំណងជានាថា រដ្ឋជាសមាជិកអាស៊ានអាចកែសម្រួលការអនុវត្តទៅតាមតថភាពបរិបទរបស់ខ្លួន និងឆ្លើយតបជាយុទ្ធសាស្ត្រទៅនឹងបរិបទជាតិ និងបរិបទមូលដ្ឋាន។

ក្នុងការអនុវត្តនៅឆ្នាំដំបូង នឹងមានការជំរុញឱ្យរដ្ឋជាសមាជិកអាស៊ានធ្វើសកម្មភាពដូចខាងក្រោម ៖

- ការប្រកាសអនុវត្ត ឬរៀបចំផែនការសកម្មភាពជាតិ ឬក្របខណ្ឌគោលនយោបាយបន្ថែមទៀត ដើម្បីកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធនឹងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន លើការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- ការរៀបចំផែនការអនុវត្តដែលត្រូវបានកែសម្រួលតាមបរិបទ ដែលរួមបញ្ចូលកិច្ចការដែលមានលើកឡើងខាងលើ ដូចជា ការប៉ាន់ប្រមាណតម្រូវការបច្ចេកទេស និងតម្រូវការហិរញ្ញវត្ថុ ការរៀបរាប់ពីដំណើរការ/គោលនយោបាយ/យន្តការដែលត្រូវអភិវឌ្ឍបន្ថែមនិងការកំណត់ក្របខណ្ឌពេលវេលា
- ការបង្កើតផែនការពិនិត្យតាមដាន រាយការណ៍ និងវាយតម្លៃ រួមទាំងសូចនាករផ្អែកតាមបរិបទ (ដោយប្រើប្រាស់ ឬកែសម្រួលសូចនាករដែលមានរៀបរាប់ក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ) ដើម្បីវាស់វែងវឌ្ឍនភាព និងលទ្ធផល ដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែង និងអន្តរាគមន៍នានា។ ជានាថា សកម្មភាពទាំងនេះបន្សុីគ្នានឹងវដ្តនៃការរាយការណ៍ និងការទទួលខុសត្រូវផ្សេងទៀត (ដូចជា រាយការណ៍ពីអនុសញ្ញា CEDAW) ដើម្បីធានាឱ្យមានភាពក្តោបរួមក្នុងការរាយការណ៍ និងបញ្ចៀសភាពត្រួតគ្នា និងអប្រសិទ្ធភាព។
- ការបង្កើតយុទ្ធសាស្ត្រកៀរគរធនធាន ដែលអាចរួមបញ្ចូលនូវទម្រង់ហិរញ្ញប្បទានថ្មី[118]។ អាចប្រើប្រាស់ការរៀបចំផែនការ និងការរៀបចំថវិការឆ្លើយតបនឹងយេនឌ័រ ដើម្បីបង្កើនគណនេយ្យភាព និងវិភាជធនធានហិរញ្ញវត្ថុសម្រាប់ក្របខណ្ឌគោលនយោបាយជាតិស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ ដូចជា ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ការប្រើប្រាស់ការគាំទ្រដែលផ្តល់ដោយមន្ត្រីបង្គោលយេនឌ័រអាស៊ាន និងអង្គភាពជាក់លាក់ផ្សេងទៀតដែលទទួលបន្ទុកស្ត្រី

118 ហិរញ្ញប្បទានបែបនវានុវត្តន៍សម្រាប់ការអភិវឌ្ឍ សំដៅលើគំនិតផ្តួចផ្តើមដែលមានគោលបំណងរៃអង្គាសមូលនិធិថ្មីសម្រាប់ការអភិវឌ្ឍ ឬប្រើប្រាស់ប្រភពមូលនិធិបែបប្រពៃណីឱ្យអស់ពីលទ្ធភាព។ គំនិតផ្តួចផ្តើមទាំងនោះមានគោលដៅលុបបំបាត់គម្លាតរវាងធនធានដែលត្រូវការចាំបាច់ដើម្បីសម្រេចរបៀបវារៈឆ្នាំ ២០៣០ និងធនធានដែលមានជាក់ស្តែង។ ខណៈដែលមិនមាននិយមន័យជារួមនៃហិរញ្ញប្បទានបែបនវានុវត្តន៍សម្រាប់ការអភិវឌ្ឍ គេអាចបែងចែកគំនិតផ្តួចផ្តើមដែលមានស្រាប់ជាគំនិតផ្តួចផ្តើមដែលមានគោលបំណងរៃអង្គាសមូលនិធិថ្មីសម្រាប់ការអភិវឌ្ឍ ("នវានុវត្តន៍នៃការកៀរគរមូលនិធិពីប្រភពខាងក្រៅ") និងគំនិតផ្តួចផ្តើមដែលប្រើប្រាស់ប្រភពមូលនិធិបែបប្រពៃណីឱ្យអស់ពីលទ្ធភាព ("នវានុវត្តន៍នៃការចំណាយ") ដូចជា តាមរយៈការពង្រឹងយន្តការពិនិត្យតាមដាន។ ជម្រើសដែលត្រូវពិចារណាសម្រាប់នវានុវត្តន៍នៃការកៀរគរមូលនិធិពីប្រភពខាងក្រៅ រួមមាន ៖

- សញ្ញាបណ្ណអនិកជន ៖ ជាឧបករណ៍បំណុលដែលចេញដោយប្រទេសមួយ ដើម្បីកៀរគរ និងទាញប្រយោជន៍ពីប្រាក់សន្សំរបស់អនិកជនសម្រាប់ការអភិវឌ្ឍ ពីប្រជាជនរបស់ខ្លួនដែលរស់នៅបរទេស។
- ពន្ធលើសំបុត្រយន្តហោះ ៖ រដ្ឋសមាជិកអាស៊ានអាចយកពន្ធមួយចំនួនលើសំបុត្រយន្តហោះ (ឧ. ៥ ដុល្លារ) ដើម្បីគាំទ្រដល់ហិរញ្ញប្បទានសកម្មភាពជាក់លាក់ ដូចមានចែងក្នុងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ បច្ចុប្បន្ន បណ្តាប្រទេសនៅជុំវិញពិភពលោក ដូចជា បេណាំង កាមេរូន ម៉ាលី មូរីទូស នីហ្គែរ បានកៀរគរថវិកាជាង ១,៥ ពាន់លានដុល្លារដោយប្រើប្រាស់មធ្យោបាយនេះ។
- មូលនិធិផ្គូរផ្គង (matching fund) ៖ រដ្ឋសមាជិកអាស៊ានអាចពិចារណាបង្កើតមូលនិធិផ្គូរផ្គងតាម ៣ វិធី ដែលម្ចាស់ជំនួយផ្គូរផ្គងភាគទានពីសាជីវកម្ម មូលនិធិ និងអង្គការ/ស្ថាប័នផ្សេងទៀត រួមទាំងអង្គការសហប្រជាជាតិ។

សន្តិភាព និងសន្តិសុខ ក៏ដូចជាសហគមន៍អាស៊ានសម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីទទួលបានជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុ។

- ការចូលរួមក្នុងគំនិតផ្តួចផ្តើមឈានមុខរបស់អាស៊ាន ដែលត្រូវបានផ្តួចផ្តើមឡើងក្នុងការប្រកាសអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងករណីពាក់ព័ន្ធ។

## ២.២ ការពិនិត្យតាមដាន ការរាយការណ៍ និងការវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ ជាសមាសភាគដ៏សំខាន់ក្នុងការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ វាជាការចាំបាច់ក្នុងការបង្កើតសូចនាករដែលពាក់ព័ន្ធនឹង បរិការណ៍ជាក់ស្តែង និងការប្រមូលទិន្នន័យដែលអាចជឿជាក់បាន ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត ក៏ដូចជាកំណត់រក និង ដោះស្រាយបញ្ហាប្រឈមនានា។ ទិន្នន័យក៏មានសារៈសំខាន់ផងដែរសម្រាប់ការស្វែងរកមតិគាំទ្រ ការកសាងការយល់ដឹង ការធានាគណនេយ្យភាព និងការពង្រឹងការអនុវត្តនាពេលអនាគត។

ប្រព័ន្ធពិនិត្យតាមដាននឹងត្រូវបានបង្កើត ដើម្បីអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីប្រមូល វិភាគ និងប្រើប្រាស់ព័ត៌មានស្តីពីការប្រកាសអនុវត្ត និងវឌ្ឍនភាពនៃសកម្មភាពនានា ក្នុងគោលបំណងតាមដានវឌ្ឍនភាពនៃផែនការសកម្មភាពនោះ។ នៅឆ្នាំដំបូងនៃការ អនុវត្តផែនការសកម្មភាព គួររៀបចំជាស្រេចនូវយន្តការពិនិត្យតាមដាន និងរាយការណ៍ និងបង្កើតផែនការវាយតម្លៃ[119]។ កិច្ចការនេះគួរធ្វើឡើងក្រោមកិច្ចសហការជាមួយទីភ្នាក់ងារអនុវត្តសំខាន់ៗ ដើម្បីកំណត់ពីតម្រូវការរបស់ពួកគេពាក់ព័ន្ធនឹងការពិនិត្យតាមដាន និងវាយតម្លៃ និងធានាថា ពួកគេទទួលបានការគាំទ្រដែលត្រូវការចាំបាច់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពដែលពួកគេជាអ្នកទទួលខុសត្រូវ ឬផ្តួចផ្តើមឡើង ក្នុងផែនការសម្មភាពតំបន់អាស៊ាន។

ប្រព័ន្ធពិនិត្យតាមដាន គួរត្រូវបានសម្រេច/អនុម័តដោយក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងដៃគូអនុវត្តសំខាន់ៗផ្សេងទៀត ដោយផ្អែកលើ និងការរៀនសូត្រពីប្រព័ន្ធពិនិត្យតាមដាន និងរាយការណ៍ផ្សេងៗសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានដទៃទៀតដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ឬបញ្ហាសិទ្ធិស្ត្រី ដូចជា ក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រអាស៊ាន ដើម្បីប្រមែប្រមូលកម្លាំងផ្តួប និងបង្កើនការរាយការណ៍ ជាជាងអនុវត្តការងារត្រួតគ្នា។ ឧ. (និងស៊ីសង្វាក់គ្នានឹងការពិនិត្យតាមដានផែនការសកម្មភាពតំបន់អាស៊ានផ្សេងទៀត) ផ្នែកលុបបំបាត់ភាពក្រីក្រ និងយេនឌ័រ(PEGD) ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន(ACC) និង អគ្គនាយកដ្ឋានពិនិត្យតាមដាននៃលេខាធិការដ្ឋានអាស៊ាន ក្រោមកិច្ច សហការជាមួយក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងស្ថាប័នសំខាន់ៗផ្សេងទៀតដែលអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អាចទទួលខុសត្រូវលើការសម្របសម្រួល និងការរៀបចំរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំសម្រាប់ដាក់ជូន AGMSC[120]/កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រី អនុម័ត។ ក្រៅពីនេះ អាស៊ានគួរធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើក្របខណ្ឌយុទ្ធសាស្ត្រនេះ នៅឆ្នាំ ២០២៦ ដើម្បីប៉ាន់ប្រមាណវឌ្ឍនភាព ក៏ដូចជាកំណត់រក និងដាក់បញ្ចូលមេរៀនពីការអនុវត្តក្នុងរយៈពេល ៣ ឆ្នាំដំបូង។

ការវាយតម្លៃផលប៉ះពាល់នៃផែនការសកម្មភាពតំបន់អាស៊ាន អាចធ្វើឡើងក្រោយរយៈពេល ៥ ឆ្នាំ និងនៅពេលបញ្ចប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ការវាយតម្លៃគួរផ្តោតលើការវាស់វែងផលប៉ះពាល់នៃអ្វីដែលគេអាចចាត់ទុកជាអន្តរាគមន៍ ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា កម្មវិធីបណ្តុះបណ្តាល ការផ្លាស់ប្តូរ ឬការអនុវត្តគោលនយោបាយ ឧ. សម្រាប់សេវាសុខភាព សេវាអប់រំ ឬសេវាសំខាន់ៗមួយចំនួន។ ដើម្បីសម្រួលដល់ការពិនិត្យតាមដាន ការរាយការណ៍ និងការវាយតម្លៃ តារាងសកម្មភាពអាទិភាពស្តីពីការការពារ ការទប់ស្កាត់ ការចូលរួម និងការសង្គ្រោះ និងស្តារឡើងវិញខាងលើ បានបញ្ជាក់ពី "លទ្ធផលចុងក្រោយ" និង "លទ្ធផលរំពឹងទុក" ក៏ដូចជា "សកម្មភាពអាទិភាព"។ ការបញ្ជាក់នីមួយៗមានមុខងារជាក់លាក់ក្នុងក្របខណ្ឌសមស្រប និងផ្អែកតាមលទ្ធផលដូចខាងក្រោម ៖

លទ្ធផលចុងក្រោយ ៖ លទ្ធផលចុងក្រោយទាំងនេះបញ្ជាក់ពីលទ្ធផលរំពឹងទុកនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងរួមបញ្ចូលការផ្លាស់ប្តូរដែលអាចវាស់វែងបានជាច្រើនសម្រាប់អ្នកទទួលផល និងភាគីពាក់ព័ន្ធសំខាន់ៗ (ដូចជា ការបង្កើនការការពារសិទ្ធិស្ត្រី)។ លទ្ធផលចុងក្រោយទាំងនេះក៏អាចរួមបញ្ចូលផងដែរនូវការផ្លាស់ប្តូរក្នុងស្ថាប័ន ដូចជា គោលនយោបាយ ការអនុវត្ត និងអាកប្បកិរិយាដែលគេចាត់ទុកថាមានសារៈសំខាន់សម្រាប់ការអនុវត្តយន្តការស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ ដូចជា

---

119 គោលដៅមួយក្នុងចំណោមគោលដៅសំខាន់ៗនៃការពិនិត្យតាមដាន គឺដើម្បីអាចឱ្យមានការកែតម្រូវក្នុងពេលអនុវត្ត។ ទីភ្នាក់ងារអនុវត្តគួរផ្លាស់ប្តូរ ឬវាយតម្លៃឡើងវិញថាតើមិនមានការអនុវត្តសកម្មភាព ឬសកម្មភាពត្រូវបានអនុវត្តខុសពីទិសដៅនៃការសម្រេចបានលទ្ធផលដែលចង់បាន ឬទេ និងគួរចងក្រងឯកសារស្តីពីការរៀនសូត្រ និងផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំផែនការ និងការអនុវត្តនាពេលអនាគត។ គោលបំណងនៃការពិនិត្យតាមដាន មិនមែនដើម្បីបង្ហាញពីលទ្ធផលនោះទេ ប៉ុន្តែគឺដើម្បីស៊ើបអង្កេត និងយល់ពីសកម្មភាពដែលបានធ្វើឡើង អ្វីដែលពិបាកអនុវត្ត និងមូលហេតុ ពិចារណាពីរបៀបដោះស្រាយបញ្ហា និងពិចារណាពីចំណុចដែលមានប្រសិទ្ធភាព និងមូលហេតុ។

120 ASEAN Gender Mainstreaming Steering Committee

គោលនយោបាយដែលបានអនុវត្ត ឬច្បាប់ដែលត្រូវបានអនុម័ត និងភស្តុតាងនៃការផ្លាស់ប្តូរឥរិយាបថ ឬការប្រែប្រួលសមត្ថភាព/ជំនាញរបស់អ្នកឆ្លើយតបជួរមុខ ដែលអាចវាស់វែងបាន/ចងក្រងជាឯកសារ ជាដើម។

ទោះបីជាការប្រែប្រួលគោលនយោបាយ អាចជាលទ្ធផលដ៏សំខាន់ ឬជាលទ្ធផលដែលចង់បានក៏ដោយ ប៉ុន្តែគេនៅតែចាំបាច់ត្រូវធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើផលប៉ះពាល់ ដើម្បីកំណត់ថាតើ "លទ្ធផលចុងក្រោយទាំងនេះ" (សូម្បីតែនៅពេលទទួលបានជោគជ័យ ដូចជា គោលនយោបាយកាន់តែប្រសើរស្តីពីអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ) បង្កផលប៉ះពាល់ដែលចង់បានលើអ្នកទទួលផលចុងក្រោយ ឬអ្នកទទួលផលដែលបានកំណត់ ឬទេ (ដូចជា ស្ត្រី ស្ត្រីវ័យក្មេង បុរស ឬអ្នកដែលមកពីក្រុមងាយរងគ្រោះអាស្រ័យលើសកម្មភាពអាទិភាព)។

ខ. អាចមានកត្តាអន្តរាគមន៍ ឬវិបត្តិដែលនាំឱ្យសម្រេចបានលទ្ធផលចុងក្រោយប៉ុន្តែមិនសម្រេចបានផលប៉ះពាល់ដែលចង់បាន ឬប្រហែលជាមានការសន្មតខុស ហើយសកម្មភាពដែលចង់បានអាចមិនសម្រេចបានផលប៉ះពាល់ដែលចង់បាន[121]។

លទ្ធផលរំពឹងទុក ជាលទ្ធផលបណ្តោះអាសន្នសំខាន់ៗដែលច្រើនតែត្រូវបានចាត់ទុកថាមានសារៈសំខាន់ក្នុងការសម្រេចគោលដៅ និងលទ្ធផលចុងក្រោយដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ លទ្ធផលទាំងនេះពាក់ព័ន្ធនឹងសកម្មភាពដែលមិនហួសពីសមត្ថភាពរបស់ទីភ្នាក់ងារអនុវត្ត (ឧ. វគ្គបណ្តុះបណ្តាល របាយការណ៍ ការកសាងសមត្ថភាព ការព្រាងច្បាប់ និងគោលនយោបាយ និងការប្រកាសផ្សព្វផ្សាយកម្មវិធី ការស្រាវជ្រាវ ការតស៊ូមតិ យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ។ល។)។

កម្រងសូចនាករលទ្ធផលចុងក្រោយ មានរៀបរាប់ក្នុងតារាងទាំងនេះ ដែលបង្កើតបានជាចំណុចដៅចាំបាច់សម្រាប់ការកំណត់វឌ្ឍនភាពនៃការសម្រេចបានលទ្ធផលចុងក្រោយនីមួយៗ។ គេអាចបង្កើត សូចនាករលទ្ធផលរំពឹងទុក ដោយសហការជាមួយទីភ្នាក់ងារអនុវត្ត (ដែលដឹកនាំសកម្មភាពអាទិភាព) ដើម្បីវាស់វែងថាតើសកម្មភាពទាំងនេះពិតជាបានធ្វើឡើងឬទេ និងសម្រាប់ជាមគ្គុទេសក៍នៃការរាយការណ៍ពីស្ថានភាពនៃការអនុវត្តសកម្មភាពទាំងនោះ។

## ឧបសម្ព័ន្ធ ១ ៖ សមាជិកនៃក្រុមប្រឹក្សាស្ត្រីអាស៊ាន សន្តិភាព និងសន្តិសុខ

| ល.រ | ស្ថាប័ន/អង្គភាពតាមវិស័យរបស់អាស៊ាន | ឈ្មោះ និងមុខតំណែង |
|---|---|---|
| ១ | មន្ត្រីបង្គោលគណៈកម្មាធិការស្ត្រីអាស៊ាន ៖ ប្រទេសកម្ពុជា | លោកជំទាវ ខេង សំវ៉ាដា<br>រដ្ឋលេខាធិការប្រចាំការនៃក្រសួងកិច្ចការនារី<br>ជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ |
| ២ | មន្ត្រីបង្គោលគណៈកម្មាធិការស្ត្រីអាស៊ាន ៖ ប្រទេសវៀតណាម | បណ្ឌិត Ha Thi Minh Duc<br>អគ្គនាយករង<br>នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការងារ ជនពិការ និងសង្គមកិច្ច (MOLISA) |
| ៣ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសឥណ្ឌូនេស៊ី | បណ្ឌិត Sri Danti Anwar<br>ទីប្រឹក្សាជាន់ខ្ពស់ខាងការអភិវឌ្ឍគ្រួសារនៃក្រសួងបង្កើនភាពអង់អាចដល់ស្ត្រី និងការពារកុមារ |

Continued

121 ការប៉ាន់ប្រមាណផលប៉ះពាល់ អាចមានការលំបាកផ្នែកបច្ចេកទេស និងចំណាយច្រើន។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ស្នើឱ្យមានការប៉ាន់ប្រមាណផលប៉ះពាល់ដែលអាចពិចារណាបាន (ក្នុងករណីសមស្រប) ដូចជា ការសាកល្បងដោយមានការគ្រប់គ្រងតាមបែបចៃដន្យ (RCT) ដើម្បីប្រៀបធៀបក្រុមបានទទួលអន្តរាគមន៍ ដូចជា ការកែប្រែគោលនយោបាយ ការបណ្តុះបណ្តាល ឬកម្មវិធី និងក្រុមពុំបានទទួលអន្តរាគមន៍ ដូចជា ការកែប្រែគោលនយោបាយ ការបណ្តុះបណ្តាល ឬកម្មវិធី (ប្រសិនបើជោគជ័យ កម្មវិធីនោះនឹងត្រូវបានអនុវត្តចំពោះក្រុមដែលពុំបានទទួលអន្តរាគមន៍)។ ជារឿយៗ ការសាកល្បងដោយមានការគ្រប់គ្រងតាមបែបចៃដន្យ (RCT) ត្រូវបានចាត់ទុកជា "ស្តង់ដារមាស" នៃការវាយតម្លៃ ប៉ុន្តែ RCT មិនសុទ្ធតែអាចអនុវត្តបាន ឬសុទ្ធតែសមស្របនោះទេ និងមានវិធីផ្សេងទៀតក្នុងការវាយតម្លៃ និងការប៉ាន់ប្រមាណផលប៉ះពាល់ដែលល្អិតល្អន់ និងមានប្រសិទ្ធភាពលើអ្វីដែលអាចចាត់ទុកជា "អន្តរាគមន៍" ដែលត្រូវបានធ្វើឡើងក្នុងផ្នែកមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នៅកម្រិតទស្សនាទាន សម្រាប់ការវាយតម្លៃផលប៉ះពាល់ គួរសួរថា ៖ តើយើងរំពឹងថានឹងមានអ្វីកើតឡើង ឬជាបញ្ហាចោទ ប្រសិនបើមិនមានផែនការសកម្មភាពតំបន់ដែលអនុវត្តសកម្មភាព x? ឧ. ចុះបើមិនមានសកម្មភាព ឬអន្តរាគមន៍ពីផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តើនឹងមានអ្វីកើតឡើង? (តើស្ថានភាពអាចប្រហាក់ប្រហែលគ្នា ឬទេ? ប្រសើរជាងមុន ឬទេ? យ៉ាប់យ៉ឺនជាងមុន ឬទេ? ដោយរបៀបណា?)

| | | |
|---|---|---|
| ៤ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសម៉ាឡេស៊ី | បណ្ឌិត Maziah binti Che Yusoff<br>អគ្គលេខាធិការ<br>ក្រសួងស្ត្រី គ្រួសារ និងអភិវឌ្ឍន៍សហគមន៍ |
| ៥ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសហ្វីលីពីន | សាស្ត្រាចារ្យបណ្ឌិត Lourdesita Sobrevega-Chan<br>ប្រធានក្រុមប្រឹក្សាស្រាវជ្រាវសាកល<br>វិទ្យាល័យ និងជាសមាជិកនៃក្រុមប្រឹក្សា<br>ភិបាលនៃសាកលវិទ្យាល័យ Ateneo de Davao<br>ប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិ និងមន្ទីរពេទ្យនៃសាលាវេជ្ជសាស្ត្រ Davao |
| ៦ | ក្រុមការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្ម (WG-CT) នៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) | លោក Andhika Chrisnayudhanto<br>អនុប្រធានទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើភេរវកម្មថ្នាក់ជាតិ ប្រទេសឥណ្ឌូនេស៊ី<br>ប្រធាន SOMTC WG-CT |
| ៧ | កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (ADSOM) | ឧត្តមសេនីយ៍ឯក ណែម សុវត្ថិ<br>ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា<br>ទៀ បាញ់ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិកម្ពុជា<br>ប្រធាន ADSOM |
| ៨ | គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) | ឯកឧត្តម កែវ រ៉េមី<br>ប្រធាន AICHR |
| ៩ | វិទ្យាស្ថានសន្តិភាព និងការសម្រុះសម្រួលអាស៊ាន (ASEAN-IPR) | ឯកអគ្គរដ្ឋទូត I Gusti Agung Wesaka Puja<br>នាយកប្រតិបត្តិ |
| ១០ | ក្រុមការងារទប់ស្កាត់ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយអាស៊ាន (ACDM) | DG Vongkham Phanthanouvong (ឡាវ)<br>Dir. Susana Juangco (ហ្វីលីពីន)<br>Dir. Saharat Wongsakulwiwat (ថៃ)<br>សហប្រធានក្រុមការងារ ACDM ទទួលបន្ទុកការទប់ស្កាត់ និងការកាត់បន្ថយ<br>ហានិភ័យគ្រោះមហន្តរាយ |
| ១១ | បណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN) | លោកស្រី Dyah Anita Prihapsari<br>ប្រធាន AWEN |

# ឧបសម្ព័ន្ធ ២ ៖ សមាជិកនៃក្រុមការងារបច្ចេកទេសរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

| ល.រ | ស្ថាប័ន/អង្គភាពតាមវិស័យរបស់អាស៊ាន | សមាជិកនៃក្រុមការងារបច្ចេកទេស |
|---|---|---|
| ១ | មន្ត្រីបង្គោលគណៈកម្មាធិការស្ត្រីអាស៊ាន ៖ ប្រទេសកម្ពុជា | លោកជំទាវ ខេង សំវ៉ាដា<br>រដ្ឋលេខាធិការប្រចាំការនៃក្រសួងកិច្ចការនារី<br>ជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ |
| ២ | មន្ត្រីបង្គោលគណៈកម្មាធិការស្ត្រីអាស៊ាន ៖ ប្រទេសវៀតណាម | បណ្ឌិត Ha Thi Minh Duc<br>អគ្គនាយករង<br>នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការងារ ជនពិការ និងសង្គមកិច្ច (MOLISA) |
| ៣ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសឥណ្ឌូនេស៊ី | បណ្ឌិត Sri Danti Anwar<br>ទីប្រឹក្សាជាន់ខ្ពស់ខាងការអភិវឌ្ឍគ្រួសារនៃក្រសួងបង្កើនភាពអង់អាចដល់ស្ត្រី និងការពារកុមារ |
| ៤ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសម៉ាឡេស៊ី | លោក Satish Ranggayah<br>លេខារង<br>ផ្នែកទំនាក់ទំនងអន្តរជាតិ<br>ក្រសួងស្ត្រី គ្រួសារ និងអភិវឌ្ឍន៍សហគមន៍ |
| ៥ | តំណាងគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ទទួលបន្ទុកសិទ្ធិស្ត្រី ៖ ប្រទេសហ្វីលីពីន | សាស្ត្រាចារ្យបណ្ឌិត Lourdesita Sobrevega-Chan ប្រធានក្រុមប្រឹក្សាស្រាវជ្រាវសាកល<br>វិទ្យាល័យ និងសមាជិកក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ<br>Ateneo de Davao<br>ប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិ និងមន្ទីរពេទ្យនៃសាលាវេជ្ជសាស្ត្រ Davao<br><br>លោក Amerson R. Aguinaldo<br>អ្នកឯកទេសផ្នែកយេនឌ័រ និងការអភិវឌ្ឍ (GAD) នៃផ្នែកសម្របសម្រួលវិស័យ<br>គណៈកម្មការស្ត្រីហ្វីលីពីន (PCW)<br><br>លោកស្រី Avery Silk Arevalo<br>អ្នកឯកទេសជាន់ខ្ពស់ផ្នែកយេនឌ័រ និងការអភិវឌ្ឍ ផ្នែកកិច្ចការអន្តរជាតិ គណៈកម្មការស្ត្រីហ្វីលីពីន (PCW)<br><br>លោកស្រី Marianne Kristine V. Delgado<br>ប្រធានក្រុមអ្នកឯកទេសផ្នែកយេនឌ័រ និងការអភិវឌ្ឍ ផ្នែកសម្របសម្រួលវិស័យ<br>គណៈកម្មការស្ត្រីហ្វីលីពីន (PCW) |

Continued ▼

| | | |
|---|---|---|
| ៦ | ក្រុមការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្ម (WG-CT) នៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) | លោក Andhika Chrisnayudhanto<br>អនុប្រធានទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើភេរវកម្មថ្នាក់ជាតិ ប្រទេសឥណ្ឌូនេស៊ី<br><br>លោក M. Zaim A. Nasution<br>នាយកទីភ្នាក់ងារកិច្ចសហប្រតិបត្តិការតំបន់ និងពហុភាគីលើការប្រយុទ្ធប្រឆាំងអំពើភេរវកម្មថ្នាក់ជាតិ ប្រទេសឥណ្ឌូនេស៊ី<br><br>លោក Hadi Setiyono<br>ប្រធានកងអនុសេនាតូចនៃកិច្ចសហប្រតិបត្តិការពលសេនាពិសេសលេខ ៨៨ នៃកងកម្លាំងប៉ូលីសជាតិឥណ្ឌូនេស៊ីប្រឆាំងអំពើភេរវកម្ម<br><br>លោក Bangun Riyadi Girdayanto<br>មន្ត្រីអង្គការអន្តរជាតិនៃផ្នែកទំនាក់ទំនងអន្តរជាតិនៃកងកម្លាំងប៉ូលីសជាតិ<br>ឥណ្ឌូនេស៊ី<br><br>I Putu Eka Dimi A<br>អ្នកវិភាគទិន្នន័យ និងព័ត៌មាននៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការតំបន់ និងពហុភាគីលើការប្រយុទ្ធប្រឆាំងអំពើភេរវកម្មថ្នាក់ជាតិ |
| ៧ | ប្រធានកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការពារជាតិអាស៊ាន (ADSOM) | ឧត្តមសេនីយ៍ទោ សំ សុភា<br>អនុប្រធាននាយកដ្ឋានកិច្ចការអាស៊ាន ក្រសួងការពារជាតិកម្ពុជា |
| ៨ | នាយកប្រតិបត្តិនៃវិទ្យាស្ថានសន្តិភាព និងការសម្រុះសម្រួលអាស៊ាន (ASEAN-IPR) | Kartika Budhi Wijayanti<br>មន្ត្រីគ្រប់គ្រងគម្រោង |
| ៩ | ប្រធានបណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN) | លោកស្រី Cindy Chaw<br>មន្ត្រីបង្គោល AWEN (មីយ៉ាន់ម៉ា)<br><br>លោកស្រី Sinda Sutadisastra<br>លេខា AWEN<br><br>លោកស្រី Ana Bobadilla<br>មន្ត្រីបង្គោល AWEN (ហ្វីលីពីន) |

អាស៊ាន ៖ សហគមន៍ដែលនាំមកនូវឱកាសសម្រាប់ប្រជាជនទាំងអស់